ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**Ministry of Agriculture, Forestry and Fisheries**

# ផែនការយុទ្ធសាស្ត្រថវិកា

# ២០២៤-២០២៦

## BUDGET STRATEGIC PLAN 2024-2026

រៀបចំដោយ : ក្រុមការងាររៀបចំផែនការថវិកា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

រាជធានីភ្នំពេញ ខែកក្កដា ឆ្នាំ២០២៣

# មាតិកា


**មាតិកា** ..... 1
**I-សេចក្តីផ្តើម** ..... 2
**១. តួនាទី និងបេសកកម្មចម្បងៗ** ..... 3
**២. លទ្ធផលសម្រេចបានឆ្នាំ២០២២** ..... 4
ក. លទ្ធផលសម្រេចបានតាមអនុវិស័យកសិកម្មឆ្នាំ២០២២ ..... 6
ក.១ ការបង្កើនផលិតភាព និងពិពិធកម្មដំណាំកសិកម្ម ..... 6
ក.២ ការជំរុញផលិតកម្មសត្វនិងសុខភាពសត្វ ..... 8
ក.៣ ការគ្រប់គ្រងធនធានជលផល និងការអភិវឌ្ឍវារីវប្បកម្ម ..... 10
ក.៤ ការសម្រេចបានក្នុងការកែទម្រង់ផ្នែកព្រៃឈើ ..... 11
ក.៥. ការពង្រឹងសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស ..... 13
ក.៦. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ..... 13
**៣. បញ្ហាប្រឈម** ..... 14
**៤. វិធានការ** ..... 15
II. **គោលបំណងគោលនយោបាយ** ..... 18
III. **កម្មវិធី/យុទ្ធសាស្ត្រអាទិភាព** ..... 18
IV. **ការកំណត់រចនាសម្ព័ន្ធថវិកាសមិទ្ធកម្ម** ..... 35
ក. ការកំណត់សូចនាករសមិទ្ធកម្ម និងគោលដៅ ..... 35
ខ. ទម្រង់រចនាសម្ព័ន្ធថវិកាសមិទ្ធកម្ម ..... 48
V. **ការកំណត់ធនធាន** ..... 150
ក. ការគ្រោងចំណូល ..... 150
ខ. ការកំណត់តម្រូវការចំណាយ ..... 155
VI. **សេចក្តីសន្និដ្ឋាន** ..... - 181 -

## I- សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញទិសដៅជាយុទ្ធសាស្ត្រ នៃការកែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជា២០១៣-២០២០ ដែលជាទិសដៅនៃការផ្លាស់ប្តូរប្រព័ន្ធគ្រប់គ្រងថវិកាជាជំហានៗ ពីការផ្តោតលើធាតុចូលនិងមជ្ឈការទៅរកប្រព័ន្ធថវិកាថ្មី គឺការផ្តោតលើលទ្ធផលឬសមិទ្ធកម្មនិងវិមជ្ឈការ។ បន្ទាប់មក រាជរដ្ឋាភិបាលកម្ពុជាបានធ្វើបច្ចុប្បន្នភាពយុទ្ធសាស្ត្រ នៃកែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជា២០១៨-២០២៥ គឺផ្តោតលើប្រសិទ្ធភាព គណនេយ្យភាព និងតម្លាភាព។ ផ្អែកតាមទិសដៅនៃកម្មវិធីកែទម្រង់នេះ។

ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៤-២០២៦ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបានរៀបចំស្របតាមខ្លឹមសារនៃសារាចរណែនាំលេខ០៨សរ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៣ របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពី ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៤-២០២៦ និងបានគ្របដណ្តប់ថវិកាទាំងអង្គភាពបច្ចេកទេសថ្នាក់កណ្តាល គ្រឹះស្ថានសាធារណៈរដ្ឋបាល និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្តទាំង២៥។

បន្ថែមលើនេះទៀតនោះ គោលនយោបាយជាតិអភិវឌ្ឍន៍វិស័យកសិកម្ម២០២២-២០៣០ ក៏ត្រូវបានរៀបចំ និងបានដាក់ឱ្យអនុវត្តកាលពីឆ្នាំ២០២២កន្លងទៅនេះ ស្របតាមទិសដៅគោលនយោបាយតាមវិស័យនីមួយៗ ដូចមានចែងក្នុង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា។ គោលបំណងគោលនយោបាយរបស់ក្រសួងត្រូវបានកំណត់ច្បាស់លាស់ និងបង្កើតបាននូវរចនាសម្ព័ន្ធកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព រួមទាំងការកំណត់នូវសូចនាករសម្រាប់យកទៅអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់។ ផ្អែកលើមូលដ្ឋាននេះ ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៤-២០២៦ ក៏ត្រូវបានរៀបចំឱ្យមានសង្គតិភាព ជាមួយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មផងដែរ។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលនៅតែចាត់ទុកវិស័យកសិកម្មជាវិស័យអាទិភាពមួយក្នុងចំណោម វិស័យអាទិភាពសំខាន់ៗ ផ្សេងៗទៀត ហើយវិស័យនេះបាននិងកំពុងចូលរួមចំណែកយ៉ាងសំខាន់ក្នុងការជំរុញ កំណើនសេដ្ឋកិច្ចជាតិ ធានា បាននូវសន្តិសុខស្បៀង ជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជនបទ និងលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ តាមរយៈ ការបង្កើនផលិតភាពពិពិធកម្មដំណាំកសិកម្ម និងកសិ-ធុរកិច្ច ការលើកកម្ពស់ ផលិតកម្មសត្វនិងសុខភាពសត្វ ការគ្រប់គ្រងធនធានជលផល និងអភិវឌ្ឍន៍វារីវប្បកម្ម ការគ្រប់គ្រងនិងអភិវឌ្ឍន៍ ធនធានព្រៃឈើនិងសត្វព្រៃ រួមទាំងការបង្កើនប្រសិទ្ធភាពសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្សផងដែរ ជាពិសេស ក្នុងកាលៈទេសៈដែលប្រទេសជាតិ កំពុងទទួលរងនូវហានិភ័យពីវិបត្តិជាសាកលនៃជំងឺឆ្លងកូវីដ-១៩នេះ។

ដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការរៀបចំផែនការថវិកា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានកែសម្រួលនូវសមាសភាពក្រុមការងារចំនួន២ គឺៈ (១)ក្រុម ការងាររៀបចំថវិកា និង(២)ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំក្រសួង ដែលក្រុមទាំង២នេះ ដឹកនាំដោយឯកឧត្តមរដ្ឋលេខាធិការក្រសួង និងមានសមាសភាពចម្រុះពីអង្គភាពសំខាន់ៗ ពិសេសពីនាយកដ្ឋានផែនការនិងស្ថិតិ និងនាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ។

ម្យ៉ាងវិញទៀត ផ្នែកក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានបង្ហាញច្បាស់លាស់ក្នុងឯកសារនៃសារាចរណែនាំរបស់រាជរដ្ឋាភិបាល។ ទន្ទឹមនឹងនេះ ផែនការយុទ្ធសាស្ត្រថវិកា២០២៣-២០២៥ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏ត្រូវបានកសាងឱ្យមានសង្គតិភាពជាមួយគោលនយោបាយខាងលើ ដែលជាមូលដ្ឋានសម្រាប់អនុវត្តប្រកបដោយប្រសិទ្ធភាព។

រចនាសម្ព័ន្ធឯកសារផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៤-២០២៦ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងរៀបចំជា៦ផ្នែកសំខាន់រួមមានៈ

(ផ្នែកទី១)៖ គឺបង្ហាញពីតួនាទីនិងបេសកកម្មរបស់ក្រសួង វឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រថវិកាឆ្នាំកន្លងមក បញ្ហាប្រឈមនានា និងវិធានការគោលនយោបាយសំខាន់ៗ សម្រាប់រួមចំណែកអនុវត្តយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។

(ផ្នែកទី២)៖ ការកំណត់គោលបំណងគោលនយោបាយរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយបង្ហាញពីចក្ខុវិស័យរយៈពេលមធ្យមនិងវែង ផ្អែកលើគោលនយោបាយតាមវិស័យ ដែលនឹងចែងក្នុងយុទ្ធសាស្ត្រ របស់រាជរដ្ឋាភិបាល និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។

(ផ្នែកទី៣)៖ ការរៀបចំកម្មវិធីថ្មីទាំង៥របស់ក្រសួង ឱ្យឆ្លើយតបទៅនឹងគោលបំណងគោលនយោបាយរបស់ក្រសួងដូចដែលបានរៀបរាប់ក្នុងផ្នែកទី២ខាងលើ ដែលកម្មវិធីទាំង៥នេះមានលក្ខណៈសមាហរណកម្ម និងគ្របដណ្ដប់លើគម្រោង/សកម្មភាពការងារទាំងអស់ ដោយរាប់បញ្ចូលទាំងគម្រោង/សកម្មភាពការងារ ដែលផ្ដល់ហិរញ្ញប្បទានពីថវិការដ្ឋ និងថវិកាហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍នានា ហើយផ្នែកនេះក៏នឹងបង្ហាញពីតម្រូវការធនធានសម្រាប់អនុវត្តដែលរួមទាំងថវិកាជាតិ និងថវិកាដៃគូអភិវឌ្ឍន៍ផងដែរ។

(ផ្នែកទី៤)៖ ការកំណត់សូចនាករ និងគោលដៅសូចនាករ ដែលជាមូលដ្ឋានសម្រាប់ការតាមដាននិងវាយតម្លៃនៃការអនុវត្តកម្មវិធីទាំង៥របស់ក្រសួង។

(ផ្នែកទី៥)៖ ការកំណត់តម្រូវការចំណាយសម្រាប់អនុវត្តរយៈពេល៣ឆ្នាំ (២០២៤-២០២៦) តាមកម្មវិធី នីមួយៗ និងការគ្រោងចំណូលផ្អែកលើលទ្ធផល និងបទពិសោធន៍ក្នុងការអនុវត្តនៃបណ្ដាឆ្នាំកន្លងមក។

(ផ្នែកទី៦)៖ ជាផ្នែកចុងក្រោយដែលបង្ហាញពីសេចក្ដីសន្និដ្ឋាន ទៅលើការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៤-២០២៦ ការលើកទិសដៅ និងវិធានការនានា ដើម្បីសម្រេចបានតាមគោលដៅដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រថវិកានេះ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានពិនិត្យវាយតម្លៃអង្គភាពក្រោមឱវាទ តាមលក្ខខណ្ឌវិនិច្ឆ័យទាំង៧នៃអង្គភាពថវិកា និងបានកំណត់អង្គភាពថវិកាចំនួន៤៦ ដែលត្រូវយកទៅអនុវត្តកន្លងមកនេះ ក្នុងនោះ អង្គភាព ថ្នាក់កណ្ដាលចំនួន២១អង្គភាព និងថ្នាក់រាជធានី ខេត្ត (មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានីខេត្ត) ចំនួន២៥អង្គភាព។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានឯកភាពឱ្យអង្គភាពថវិកាទាំង៤៦នេះបានដំណើរការអនុវត្តការងាររបស់ខ្លួន។

## ១. តួនាទី និងបេសកកម្មចម្បងៗ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានចក្ខុវិស័យកសាង***កសិកម្មកម្ពុជាជាកសិកម្មទំនើប មានលក្ខណៈប្រកួតប្រជែង បរិយាបន្ន ធន់នឹងការប្រែប្រួលអាកាសធាតុ និងនិរន្តរភាព ដែលនឹងធ្វើឱ្យកើនឡើងប្រាក់ចំណូលគ្រួសារកសិករ វិបុលភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋកម្ពុជា***។

**បេសកកម្មរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺដើម្បី៖** ផ្ដល់សេវាគាំទ្រមាន គុណភាពខ្ពស់ មានលក្ខណៈវិទ្យាសាស្ត្របច្ចេកទេស បទដ្ឋានគតិយុត្ត និងគោលនយោបាយច្បាស់លាស់ សម្រាប់បម្រើឱ្យការអភិវឌ្ឍវិស័យកសិកម្មកម្ពុជាប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព។

ដោយឡែកអនុក្រឹត្យលេខ១៧ អនក្រ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ បានកំណត់យ៉ាងច្បាស់ពីមុខងារ និង ភារកិច្ច របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដូចតទៅ ៖

(ក)-រៀបចំនិងដាក់ឱ្យដំណើរការនយោបាយអភិវឌ្ឍន៍វិស័យកសិកម្ម ក្នុងគោលបំណងកែលម្អកម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ សម្របសម្រួលតាមដាន និងវាយតម្លៃលើការអនុវត្តនយោបាយ និងសកម្មភាពអភិវឌ្ឍន៍កសិកម្ម។

(ខ)-សិក្សាស្រាវជ្រាវនិងផ្សព្វផ្សាយអំពីវិទ្យាសាស្ត្របច្ចេកទេស និងសេដ្ឋកិច្ចក្នុងវិស័យកសិកម្មគ្រប់ផ្នែកចាំបាច់ដល់កសិករ ដើម្បីកែលម្អផលិតកម្មនិងផលិតភាពកសិកម្ម។

(គ)-ណែនាំការងារអភិវឌ្ឍន៍ដីនិងការកែលម្អគុណភាពដី ការប្រើប្រាស់ដីកសិកម្ម ពូជរុក្ខជាតិ ពូជសត្វ ជីគីមី និងថ្នាំកសិកម្មឱ្យបានសមស្របទៅតាមលក្ខណៈភូមិសាស្ត្រ អាកាសធាតុរបស់តំបន់ ដើម្បីធានាបានទិន្នផលខ្ពស់ និងរក្សាតុល្យភាពបរិស្ថានធម្មជាតិ។

(ឃ)-តាមដានការវិវត្តន៍នៃធនធានធម្មជាតិរបស់វិស័យកសិកម្ម និងសម្រួលដល់ការធ្វើអាជីវកម្មធនធានធម្មជាតិទាំងនោះ ដើម្បីបំពេញតម្រូវការរបស់ប្រទេសជាតិ និងគោរពលំនឹងអេកូឡូស៊ី កំណត់បទប្បញ្ញត្តិក្នុងការគ្រប់គ្រងថែរក្សាការពារធនធានធម្មជាតិរបស់វិស័យកសិកម្ម និងតាមដានការអនុវត្ត។

(ង)-វាយតម្លៃនិងបណ្តុះបណ្តាលធនធានមនុស្ស សម្រាប់ចូលរួមក្នុងការអភិវឌ្ឍកសិកម្ម ដោយលើកកម្ពស់កម្រិតយល់ដឹងបច្ចេកទេស និងបង្កលក្ខណៈប្រើប្រាស់ធនធាននេះឱ្យមានប្រសិទ្ធភាព។

(ច)-ប្រមូលថវិកាចូលរដ្ឋ ដោយសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការប្រមូលថវិកា។

## ២. លទ្ធផលសម្រេចបានឆ្នាំ២០២២

ក្រសួងបានជំរុញអនុវត្តវិធានការចាំបាច់នានារួមមាន ការកសាង និងកែលម្អ ហេដ្ឋារចនាសម្ព័ន្ធគាំទ្របម្រើឱ្យផលិតកម្មកសិកម្ម ការបង្កើនគុណភាពនៃការផ្តល់សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មដល់កសិករ ការជំរុញការស្រាវជ្រាវបច្ចេកទេសកសិកម្មសំដៅបង្កើនទិន្នផលដំណាំធន់នឹងការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងនិងបង្កើនប្រសិទ្ធភាពការប្រើប្រាស់ដីកសិកម្ម ការពង្រឹងសហគមន៍កសិកម្ម ការអនុវត្តកសិកម្មតាមកិច្ចសន្យាព្រមទាំងការកសាង និងការពង្រឹងសមត្ថភាពធនធានមនុស្សនិងស្ថាប័ន ដើម្បីជំរុញការអភិវឌ្ឍវិស័យកសិកម្មឱ្យមានប្រសិទ្ធភាពខ្ពស់។ ទន្ទឹមនឹងនេះ ក្រសួងបានយកចិត្តទុកដាក់លើកកម្ពស់ការចិញ្ចឹមសត្វ ផលិតកម្មចំណីសត្វ និងវារីវប្បកម្ម ព្រមទាំងបង្កើនការប្រើប្រាស់បច្ចេកទេសសមស្រប និងជំរុញការពង្រឹងការអនុវត្តច្បាប់ ដើម្បីគ្រប់គ្រង និងប្រើប្រាស់ធនធានព្រៃឈើ និងជលផលប្រកបដោយចីរភាព។

កិច្ចខិតខំប្រឹងប្រែងទាំងអស់នេះបានរួមចំណែកកាត់បន្ថយថ្លៃដើមផលិត និងបង្កើនប្រាក់ចំណូលជូនប្រជាកសិករ ព្រមទាំងបង្កើនតម្លៃបន្ថែមនៃផលិតផលកសិកម្ម ជំរុញការធ្វើកសិ-ធុរកិច្ច និងបង្កើនចំណូលជាតិ។ គួរកត់សម្គាល់ថា លទ្ធផលល្អប្រសើរនេះអាចសម្រេចទៅបាន អាស្រ័យដោយមានការគាំទ្រយ៉ាងខ្លាំងក្លាពីរាជរដ្ឋាភិបាលកម្ពុជា កិច្ចសហការល្អពីក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន អង្គការជាតិនិងអន្តរជាតិនានា រដ្ឋបាលថ្នាក់ក្រោមជាតិ និងការចូលរួមយ៉ាងសកម្មពីប្រជាកសិករ។

ក្នុងឆ្នាំ២០២២ ផលិតកម្មដំណាំសម្រេចបានចំនួន ៣៤,៧១លានតោន ក្នុងនោះ ផលិតកម្មដំណាំស្រូវបានចំនួន ១១,៦២លានតោន ផលិតកម្មដំណាំសាកវប្បកម្មចំនួន ៤,៤២លានតោន និងផលិតកម្មដំណាំឧស្សាហកម្មចំនួន ១៨,៦៧លានតោន។ កម្ពុជាបាននាំចេញជាផ្លូវការនូវផលិតផលកសិកម្មសរុបប្រមាណ ៨,៦លានតោន ទៅកាន់ទិសដៅ ៧៤ប្រទេស កើនជាង ៧,៨% ធៀបឆ្នាំ២០២១ ក្នុងនោះការនាំចេញអង្ករកើន ៣,២៣% និងកសិផលក្រៅពីស្រូវអង្ករកើន ១១,៦% ដែលមានទំហំទឹកប្រាក់ប្រមាណជាង ៤ ៩១០លានដុល្លារអាមេរិក។

ការងារបង្កបង្កើនផលក្នុងឆ្នាំ២០២២ បានជួបនូវបញ្ហាមួយចំនួនពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុពិសេស គ្រោះរាំងស្ងួត និងទឹកជំនន់ ដែលបានធ្វើឱ្យខូចខាតផលដំណាំរបស់ប្រជាកសិករតាមបណ្តារាជធានី-ខេត្តនៅទូទាំងប្រទេស។ ដើម្បីដោះស្រាយបញ្ហានេះ រាជរដ្ឋាភិបាលបានបញ្ចេញគ្រាប់ពូជស្រូវចំនួន ៦ ៧១២,២៥តោន តាមរយៈប្រព័ន្ធស្បៀងបម្រុងកម្ពុជា ចែកជូនប្រជាជនរងគ្រោះ និងអន្តរាគមន៍ស្តារឡើងវិញបានចំនួន ៧៥ ៦៦៩ហិកតា។ ទន្ទឹមនឹងនេះ ក្រសួងបានធ្វើការណែនាំដល់គ្រប់អង្គភាពក្រោមឱវាទពាក់ព័ន្ធ ព្រមទាំងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង

នៃសាទរាជធានី-ខេត្តទាំងអស់ឱ្យអនុវត្តនូវវិធានការបច្ចេកទេសចាំបាច់ សំដៅជំរុញការស្តារផលិតកម្មដំណាំស្រូវ និងដំណាំសាកវប្បកម្ម ដើម្បីធានាសន្តិសុខស្បៀងគ្រួសារ។

ចំពោះអនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វ ក្រសួងបានជំរុញការចិញ្ចឹមសត្វទាំងលក្ខណៈគ្រួសារ និងពាណិជ្ជកម្ម សំដៅធានាការផ្គត់ផ្គង់សាច់ និងផលិតផលសត្វមានគុណភាព អនាម័យ និងសុវត្ថិភាព សម្រាប់បំពេញតម្រូវការហូបចុករបស់ប្រជាពលរដ្ឋ។ ក្នុងឆ្នាំ២០២២ ផលិតកម្មសត្វសរុបមានអត្រាកំណើនចំនួន ៨,៨% ធៀបឆ្នាំ២០២១។ អត្រានៃការចិញ្ចឹមសត្វលក្ខណៈពាណិជ្ជកម្មបានកើនពី ៣៩% ក្នុងឆ្នាំ២០២១ ដល់ ៤១% នៅឆ្នាំ២០២២ និងអត្រានៃការចិញ្ចឹមសត្វលក្ខណៈគ្រួសារបានថយចុះពី ៦១% ក្នុងឆ្នាំ២០២១ មកត្រឹម ៥៩% នៅឆ្នាំ២០២២។

ក្នុងអនុវិស័យជលផល ការអភិវឌ្ឍវារីវប្បកម្មគ្រប់រូបភាពត្រូវបានបន្តជំរុញ ដើម្បីធានាបាននូវការផ្គត់ផ្គង់ កាត់បន្ថយការនាំចូល រក្សាបានតុល្យភាពតម្លៃទីផ្សារ ព្រមទាំងធានាបាននូវគុណភាព និងសុវត្ថិភាពសម្រាប់អ្នកបរិភោគ។ ជាក់ស្តែង ផលនេសាទ និងវារីវប្បកម្មសម្រេចបានចំនួនជាង ៨៦២ពាន់តោន ក្នុងឆ្នាំ២០២២ កើនឡើងប្រមាណ ០,៦៨% ធៀបឆ្នាំ២០២១។ មកទល់បច្ចុប្បន្ន សហគមន៍នេសាទចំនួន ៥១៦ ត្រូវបានបង្កើតឡើងដើម្បីចូលរួមគ្រប់គ្រង និងអភិរក្សធនធានជលផលឱ្យមាននិរន្តរភាព តាមទិសស្លោក "សហគមន៍នេសាទគ្មានបទល្មើស"។

ក្នុងអនុវិស័យព្រៃឈើ ក្រសួងបានបន្តផ្តោតការយកចិត្តទុកដាក់ខ្ពស់លើការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍធនធានព្រៃឈើឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ដោយចូលរួមសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមានសមត្ថកិច្ច និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការបង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើសនានា។ បច្ចុប្បន្ន សហគមន៍ព្រៃឈើចំនួន ៦៤៥ ត្រូវបានបង្កើតឡើង គ្របដណ្តប់លើផ្ទៃដីទំហំ ៥២២ ៨០៨ហិកតា ដើម្បីចូលរួមចំណែកគ្រប់គ្រង និងអភិវឌ្ឍធនធានព្រៃឈើ និងសត្វព្រៃ។

សមិទ្ធផលទាំងនេះបានឆ្លុះបញ្ចាំងឱ្យឃើញថា វិស័យកសិកម្មមានការរីកចម្រើនគួរឱ្យកត់សម្គាល់ និងចូលរួមចំណែកយ៉ាងសកម្មក្នុងការធានាសន្តិសុខស្បៀង លើកកម្ពស់កម្រិតជីវភាពប្រជាជន កាត់បន្ថយភាពក្រីក្រ បង្កើនការនាំចេញ និងទ្រទ្រង់កំណើនសេដ្ឋកិច្ចជាតិ។

### ការចូលរួមចំណែករបស់វិស័យកសិកម្មក្នុងសេដ្ឋកិច្ចជាតិ

វិស័យកសិកម្មបានចូលរួមចំណែកប្រមាណ ២២,២% (គិតជាតម្លៃបច្ចុប្បន្ន) ក្នុងផលិតផលសរុបក្នុងស្រុកក្នុងឆ្នាំ២០២២ ដោយបានកើនឡើងពី ២២% ដល់ ២២,៨% នៅចន្លោះឆ្នាំ២០១៨-២០២១ និងថយចុះពី ២២,៨% មកត្រឹម ២២,២% នៅចន្លោះឆ្នាំ២០២១-២០២២។

គិតជាតម្លៃថេរ វិស័យកសិកម្មបានចូលរួមចំណែកប្រមាណ ១៦,៣% នៃផលិតផលសរុបក្នុងស្រុក ដោយមានការថយចុះពី ១៨% មកត្រឹម ១៦,៣% នៅចន្លោះឆ្នាំ២០១៨-២០២២។

បើទោះជាការចូលរួមចំណែករបស់វិស័យកសិកម្មមានការប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំយ៉ាងនេះក្តី តម្លៃបន្ថែមសរុបនៃវិស័យកសិកម្ម (Gross Value Added in Agriculture) មានការកើនឡើងជារៀងរាល់ឆ្នាំ ពី ១៩ ៣៧៦ពាន់លានរៀល នៅឆ្នាំ២០១៣ ដល់ ២១ ៩១៣ពាន់លានរៀល នៅឆ្នាំ២០១៨ និងដល់ ២៦ ៩០៥ពាន់លានរៀល នៅឆ្នាំ២០២២ (គិតជាតម្លៃបច្ចុប្បន្ន)។

### សមាសភាគនៃអនុវិស័យក្នុងវិស័យកសិកម្ម

គិតជាតម្លៃថេរ កំណើនវិស័យកសិកម្មមានការប្រែប្រួលជាមធ្យម ក្នុងចន្លោះពី ១,១% ទៅ១,៦% ចាប់ពីឆ្នាំ២០១៣ ដល់ឆ្នាំ២០១៨ ដែលបញ្ជាក់ពីការចូលរួមចំណែកជាវិជ្ជមានរបស់វិស័យកសិកម្ម ក្នុងការជំរុញកំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។ នៅចន្លោះឆ្នាំ២០២០-២០២២ ដែលសកលលោកជួបវិបត្តិនៃការឆ្លងរីករាល

ជាលជំងឺកូវីដ-១៩ និងភាពមិនប្រាកដប្រជាដែលបណ្ដាលមកពីកត្តានានា រួមទាំងវិបត្តិសង្គ្រាមក្នុងប្រទេសមួយចំនួន វិស័យកសិកម្មកម្ពុជានៅតែរក្សាបាននូវកំណើនវិជ្ជមានក្នុងរង្វង់ ០,៦% ទៅ ១,១%។

### ស្ថានភាពកម្លាំងពលកម្មក្នុងវិស័យកសិកម្ម

ការចូលរួមចំណែករបស់អនុវិស័យនានាក្នុងវិស័យកសិកម្ម រួមមាន ផ្នែកដំណាំ ៥៧,១%, ផ្នែកផលិតកម្មសត្វ ១១,៣%, ផ្នែកជលផល ២៤,៧% និងផ្នែកព្រៃឈើ ៦,៩%។ ជាការកត់សម្គាល់ ផ្នែកដំណាំ និងជលផល គឺជាកម្លាំងចលករនាំមុខ និងចូលរួមច្រើនជាងគេក្នុងវិស័យកសិកម្ម នៅពេលដែលផលិតកម្មសត្វដើរតួនាទីផ្គត់ផ្គង់តម្រូវការសាច់ក្នុងស្រុក និងបម្រើឱ្យការនាំចេញ ដែលត្រូវបន្តជំរុញអភិវឌ្ឍឱ្យបានខ្លាំងក្លាបន្ថែមទៀត។

## ក. លទ្ធផលសម្រេចបានតាមអនុវិស័យកសិកម្មឆ្នាំ២០២២

### ក.១ ការបង្កើនផលិតភាព និងពិពិធកម្មដំណាំកសិកម្ម

- **ផលិតកម្មដំណាំស្រូវ**

ផ្ទៃដីដាំស្រូវសរុបទូទាំងប្រទេសសម្រេចបានចំនួន ៣,៤០លានហិកតា ក្នុងឆ្នាំ២០២២ មានការថយចុះ ១៤៩ ៥៥២ហិកតា ស្មើនឹង ៤,២១% ធៀបឆ្នាំ២០២១។ បរិមាណផលស្រូវសរុបទទួលបានចំនួន ១១,៦២លានតោន មានការថយចុះ ស្មើនឹង ៤,៧៧% ធៀបឆ្នាំ២០២១។

ទិន្នផលស្រូវជាមធ្យមប្រចាំឆ្នាំសម្រេចបាន ៣,៥២តោនក្នុងមួយហិកតា ក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ ផ្ទៃដីដាំស្រូវកើនឡើងចំនួន ០,៥% ផ្ទៃដីប្រមូលផលកើនឡើង ០,៤២% បរិមាណផលស្រូវកើនឡើង ១,៦៤% និងទិន្នផលស្រូវកើនឡើង ១,២២%។

- **ដំណាំសាកវប្បកម្ម**

ដំណាំសាកវប្បកម្មសម្រេចបាននៅលើផ្ទៃដីចំនួន ២៧៥ ៦២៥ហិកតា និងផ្ដល់ផលចំនួន ៤ ៤២១ ៣៧៥តោន ក្នុងនោះ ផ្ទៃដីដាំដំណាំសាកវប្បកម្មរយៈពេលខ្លី (បន្លែ ដំណាំហូបផ្លែ និងរុក្ខជាតិលម្អ) មានចំនួន ៧៧ ៣១៩ហិកតា កើនឡើង ២ ៤១៨ហិកតា ស្មើនឹង ៣,២៣% ធៀបឆ្នាំ២០២១ ដោយមានផ្ទៃដីប្រមូលផលចំនួន ៧៦ ៧៦៦ហិកតា និងផ្ដល់ផលសរុបចំនួន ១ ១១៧ ៨៩៥តោន លើសឆ្នាំមុនចំនួន ១០ ២៨៤តោន។ ចំណែកឯ ផ្ទៃដីដាំដំណាំសាកវប្បកម្មរយៈពេលវែងមានចំនួន ១៩៨ ៣០៦ហិកតា (ដំណាំកំពុងផ្ដល់ផលមានចំនួន ១៦៤ ១២៤ហិកតា ដោយផ្ដល់ផលបានចំនួន ៣ ៣០៣ ៤៨០តោន)។

- **ផលិតកម្មដំណាំឧស្សាហកម្ម**

ដំណាំឧស្សាហកម្មសម្រេចបាននៅផ្ទៃដីសរុបចំនួន ១ ៥៧៤ ៣៣១ហិកតា ដោយមានផ្ទៃដីប្រមូលផលចំនួន ១ ៤១៧ ២៦១ហិកតា និងទទួលផលបានចំនួន ១៨ ៦៦៨ ១០៦តោន ថយចុះចំនួន ៤៩០ ៨៨៩តោន ស្មើនឹង ២,៥៦% ធៀបឆ្នាំ២០២១ ក្នុងនោះ ផ្ទៃដីផលិតកម្មដំណាំឧស្សាហកម្មរយៈពេលខ្លីសម្រេចបានចំនួន ១ ០៥០ ៣២៥ហិកតា ដោយមានផ្ទៃដីប្រមូលផលចំនួន ១ ០០៥ ៣៣៦ហិកតា និងបរិមាណផលចំនួន ១៥ ៦៩៣ ៦៨៩តោន។ ផ្ទៃដីដាំដុះដំណាំឧស្សាហកម្មរយៈពេលវែងសម្រេចបានចំនួន ៥២៤ ០០៦ហិកតា ផ្ដល់ផលបានចំនួន ២ ៩៧៤ ៤១៦តោន ថយចុះចំនួន ៤៨៩ ៧០០តោន។

- **ការលើកកម្ពស់គុណភាព សុវត្ថិភាព និងការនាំចេញផលិតផលកសិកម្ម**

គិតត្រឹមឆ្នាំ២០២២ ការចុះបញ្ជីជាចម្ការ/កសិដ្ឋានដំណាំបន្លែ និងដំណាំហូបផ្លែ ស្ដីពីការអនុវត្តកសិកម្មល្អកម្ពុជា (CamGAP) សរុបបានចំនួន ៥៨៥ចម្ការ (ដំណាំបន្លែចំនួន ២៧០ ស្វាយចំនួន ១៦៣ មៀនប៉ៃលិនចំនួន ១៣២ ទុរេនចំនួន ១៥ ល្ហុងចំនួន ២ ចេកចំនួន ១ និងល្មើរចំនួន ១) ដោយបានបំពាក់នូវប្រព័ន្ធ QR Code។

ការនាំចេញផលិតផលកសិកម្មមានវិញ្ញាបនបត្រសរុបចំនួន ៨ ៦១៣ ១៤៤តោន ទៅកាន់ទិសដៅ ៧៤ប្រទេស ដោយកើនឡើងចំនួន ៦២៨ ៨៩២តោន ស្មើនឹង ៧,៨៨% ធៀបឆ្នាំ២០២១។

- **ការងារផលិតកម្ម និងការគ្រប់គ្រងពូជដំណាំ**

ការងារនេះសម្រេចបានលទ្ធផលដូចខាងក្រោម៖

- ផលិតគ្រាប់ពូជស្រូវវិញ្ញាបនបត្រនៅតាមសហគមន៍កសិកម្ម និងស្ថានីយកសិកម្ម (ពូជផ្ការំដួល និង សែនក្រអូប) សម្រេចបានចំនួន ២ ១៥០តោន
- ផ្តល់វិញ្ញាបនបត្រចុះបញ្ជិកាប្រភេទពូជដំណាំចំនួន ៦៥ប្រភេទ (ដំណាំស្រូវ៤ពូជ ដំណាំសាកវប្បកម្ម មានចំនួន ៣៩ពូជ និងដំណាំឧស្សាហកម្មមានចំនួន ២២ពូជ) ដល់ក្រុមហ៊ុនចំនួន ១១
- ផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំបានចំនួន ១៤៤ប្រភេទ (ដំណាំស្រូវមានចំនួន ១០ពូជ ដំណាំសាកវប្បកម្មមានចំនួន ៨៦ពូជ និងដំណាំឧស្សាហកម្មមានចំនួន ៤៨ពូជ) ក្រុមហ៊ុនចំនួន ១៣
- ផ្តល់លិខិតអនុញ្ញាតនាំចូលពូជដំណាំចំនួន ១៩ ០៧៤តោន (ដំណាំស្រូវចំនួន ៦ ៥៥០តោន ដំណាំ បន្លែចំនួន ២៨៤តោន និងដំណាំឧស្សាហកម្មចំនួន ១២ ២៤០តោន) ដល់ក្រុមហ៊ុនចំនួន ១៧
- ផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្ម ផលិត និងកែច្នៃគ្រាប់ពូជដំណាំដល់ក្រុមហ៊ុនចំនួន ៥ និងសហគមន៍ កសិកម្មផលិតពូជស្រូវចំនួន ១០សហគមន៍។

- **ការងារអភិវឌ្ឍន៍សហគមន៍កសិកម្ម**

ឆ្នាំ២០២២ សហគមន៍កសិកម្មចំនួន ៣៤ ត្រូវបានបង្កើតឡើង ក្នុងខេត្តចំនួន១២ បច្ចុប្បន្នសហគមន៍កសិកម្ម នៅទូទាំងប្រទេសមានចំនួន ១ ២៥១ និងមានម្ចាស់ភាគហ៊ុនសរុបចំនួន ១៧០ ២០៨នាក់ (ស្ត្រីចំនួន១០៧ ៣៨០នាក់) ស្មើនឹង ៦៣% នៃសមាជិកសរុប។ ដើមទុនសរុបមានចំនួន ១០៤ ៤២៧លានរៀល (២៦,១១លានដុល្លារអាមេរិក) ក្នុង នោះ ទឹកប្រាក់ចំនួន ៥១ ១៨៧លានរៀល (១២,៨លានដុល្លារអាមេរិក) ស្មើនឹង ២ ០៦៧ ២១៤ហ៊ុន គឺជាថវិកាវិនិយោគ ផ្ទាល់របស់សមាជិកសហគមន៍។ សហគមន៍កសិកម្មចំនួន ១៧៧ មានឃ្លាំងស្តុកកសិផលចំនួន ១៨៣ និងឡសម្ងួត/ លានហាលកសិផលចំនួន ៣៥។

មកដល់បច្ចុប្បន្ន សហភាពសហគមន៍កសិកម្មសរុបមានចំនួន ១៩ (ក្នុងនោះសហភាពចំនួន ៤ ត្រូវបានបង្កើត ក្នុងឆ្នាំ២០២២) ក្នុងខេត្តចំនួន ១៥ និងមានសមាជិកសរុបចំនួន ៣០៩ (សហគមន៍កសិកម្មចំនួន ៣០២ និងក្រុមហ៊ុន ឯកជនចំនួន ៧)។ សហភាពមានដើមទុនសរុបចំនួន ៣ ៣៦៦លានរៀល (៨៤១ពាន់ដុល្លារអាមេរិក) ក្នុងនោះទឹកប្រាក់ ចំនួន ១ ៨១៧លានរៀល (ប្រមាណ ៤៥៤ពាន់ដុល្លារអាមេរិក) ស្មើនឹង ១ ៧២៥ហ៊ុន បានមកពីការចូលរួមរបស់សមាជិក។

- **ការងារស្រាវជ្រាវនិងអភិវឌ្ឍន៍បច្ចេកវិទ្យាកសិកម្ម**

ក្នុងកិច្ចខិតខំប្រឹងប្រែងយ៉ាងសកម្មក្នុងការស្រាវជ្រាវ និងអភិវឌ្ឍន៍ពូជថ្មី ក្រសួងបានបញ្ចេញពូជស្រូវចំប៉ីស៧០ ដែលជាប្រភេទពូជស្រូវស្រាល (៩០-៩៧ថ្ងៃ) គ្រាប់អង្ករសថ្លា ក្លិនក្រអូបឈ្ងុយ និងផ្តល់ទិន្នផលជាមធ្យម ៣,៧-៤,៩ តោន/ហិកតា និងពូជស្រូវកក្រដៃដែលជាប្រភេទពូជស្រូវស្រាល (៨៥-៨៧ថ្ងៃ) មិនប្រកាន់រដូវ ធន់នឹងសត្វល្អិត (មមាចត្នោត បានកម្រិតមធ្យម) និងផ្តល់ទិន្នផលជាមធ្យម ៤,៧តោន/ហិកតា។

- **ការងារផលិតកម្មកសិកម្មតាមកិច្ចសន្យា**

ក្រសួងបានចូលរួមសម្របសម្រួល រៀបចំ និងផ្តល់យោបល់លើការចុះកិច្ចសន្យាផលិតកម្មកសិកម្មនៅទូទាំង ប្រទេសសរុបចំនួន ៤៦៩កិច្ចសន្យា។

- **ការអភិវឌ្ឍដំណាំកៅស៊ូ**

ផ្ទៃដីកៅស៊ូកម្ពុជាសរុបឆ្នាំ២០២២មានចំនួន ៤០៤ ៥៧៨ហិកតា កើនឡើង ៥៣៤ហិកតា ស្មើនឹង ០,១៣% ធៀបឆ្នាំ២០២១ ក្នុងនោះផ្ទៃដីកៅស៊ូកសិ-ឧស្សាហកម្មចំនួន ២៣៩ ៤២២ ហិកតា (៥៩,១៨%) និងផ្ទៃដីកៅស៊ូ

គ្រួសារចំនួន ១៦៥ ១៥៦ហិកតា (៤០,៨២%)។

**ការងារផលិតកម្មកៅស៊ូ**

ផ្ទៃដីកៅស៊ូយកផលឆ្នាំ២០២២ ចំនួន ៣១៥ ៣៣២ហិកតា កើនឡើងចំនួន ៥ ១៣៩ហិកតា ស្មើនឹង ១,៦៦% ធៀបឆ្នាំ២០២១។ ផលិតផលកៅស៊ូសម្រេចបានចំនួន ៣៨២ ០០០តោន កើនឡើងចំនួន ១៤ ០០០តោន ស្មើនឹង ៣,៨០% ធៀបឆ្នាំ២០២១។ ទិន្នផលមធ្យមចំនួន ១ ២១២គ.ក្រ./ហ.ត កើនឡើងចំនួន ២៦គ.ក្រ./ហ.ត. ស្មើនឹង ២,១៩% ធៀបឆ្នាំ២០២១។

**ការងារធុរកិច្ចកៅស៊ូ**

ការនាំចេញកៅស៊ូឆ្នាំ២០២២ សម្រេចបានចំនួន ៣៧២ ៩០០តោន គិតជាទឹកប្រាក់ចំនួន ៥២៧,៧៧លាន ដុល្លារអាមេរិក កើនឡើងប្រមាណចំនួន ៦ ៦០០តោន ស្មើនឹង ១,៨១% ធៀបឆ្នាំ២០២១ ប៉ុន្តែប្រាក់ចំណូលពីការនាំចេញកៅស៊ូបានថយចុះចំនួន ៨២,៥៥លានដុល្លារសហរដ្ឋអាមេរិក (-១៣,៥៣%) ដោយសារតម្លៃកៅស៊ូនៅលើទីផ្សារអន្តរជាតិធ្លាក់ចុះ ដោយសារតម្រូវការមានកម្រិតទាបជាងការផ្គត់ផ្គង់។ កៅស៊ូនាំចេញមានតម្លៃ ១ ៤១៥ដុល្លារអាមេរិកក្នុងមួយតោន ថយចុះ ២៥១ដុល្លារអាមេរិក (-១៥,០៦%) ធៀបឆ្នាំ២០២១។

**ការងារពិសោធន៍ស្រាវជ្រាវកៅស៊ូ**

ការងារនេះសម្រេចបានលទ្ធផលដូចខាងក្រោមៈ

- ស្រង់ និងបញ្ចូលទិន្នន័យចម្ការពិសោធន៍ក្នុងនិងក្រៅស្ថានីយបានចំនួន ២៣ចម្ការពិសោធន៍
- ថែទាំច្បារពូជកៅស៊ូទំហំ ៨,៦០ហិកតា និងបើកមុខចៀរចម្ការពិសោធន៍ក្លូនចំនួន ៤ចម្ការ
- ស្រាវជ្រាវ និងអភិវឌ្ឍធនធានសេនេទិចកៅស៊ូលេចធ្លោចំនួន ២០ និងបានដាំនៅចម្ការពិសោធន៍ក្លូន
- កូនកៅស៊ូជាលិកាចំនួន ២៥០០កូន ពីបណ្ឌិតសភាវិទ្យាសាស្ត្រកសិកម្មត្រូពិកចិន (CATAS-China)
- ធ្វើតេស្តកៅស៊ូសន្លឹក (RSS) និងកៅស៊ូដុំ ដើម្បីពិនិត្យគុណភាព នៃការកែច្នៃតាមស្តង់ដារ CSR
- ចុះបញ្ជិកាទទួលស្គាល់ និងសិទ្ធិប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជាចំនួន ៦ ក្នុងនោះ រោងចក្រកែច្នៃកៅស៊ូTSR ចំនួន៣ និងមន្ទីរពិសោធន៍ចំនួន ៣។

## ក.២ ការជំរុញផលិតកម្មសត្វនិងសុខភាពសត្វ

### ផលិតកម្មសត្វទូទាំងប្រទេស

ជារួម ផលិតកម្មសត្វគ្រប់ប្រភេទ មានការកើនឡើងគួរឱ្យកត់សម្គាល់ គឺចាប់ពីចំនួន ៤៤,៣៧លានក្បាល ក្នុងឆ្នាំ២០១៨ ដល់ចំនួន ៦៥,២០លានក្បាល នៅឆ្នាំ២០២២។ ដោយឡែក ក្នុងឆ្នាំ២០២២ គោមានចំនួន ៣,០២លានក្បាល ក្របីចំនួន ៤៤៧,៩៤ពាន់ក្បាល ជ្រូកចំនួន ៣,៤៣លានក្បាល បក្សីចំនួន ៥៨,១៥លានក្បាល សេះចំនួន ២,៥៤ពាន់ក្បាល ចៀមចំនួន ៥,៥២ពាន់ក្បាល ពពែចំនួន ៤៩,១៦ពាន់ក្បាល ដំរីចំនួន ៤៩ក្បាល ស្វាចំនួន ៨៩,៩៦ពាន់ក្បាល និងទន្សាយចំនួន ២,១៩ពាន់ក្បាល។ ធៀបឆ្នាំ២០២១ ផលិតកម្មសត្វមានកំណើន ៨,៨%។

**ការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ**

ការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារក្នុងឆ្នាំ២០២២ មានចំនួនសរុប ៣៨,៦៥លានក្បាល ក្នុងនោះ គោចំនួន ៣,០១លានក្បាល ក្របីចំនួន ០,៤៤លានក្បាល ជ្រូកចំនួន ១,២២លានក្បាល បក្សីចំនួន ៣៣,៩១លានក្បាល សេះចំនួន ២,៥២ពាន់ក្បាល ចៀមចំនួន ៣,៦២ពាន់ក្បាល ពពែចំនួន ៤៨,១០ពាន់ក្បាល និងដំរីចំនួន ៤៩ក្បាល។

ធៀបឆ្នាំ២០២១ ការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារមានកំណើន ៥,៧% ក្នុងនោះ គោកើន ២% ក្របីកើន ៣,៦% បក្សីកើន ៦,៣% ចៀមកើន ៤៥,៤% និងពពែកើន ១៣,២% ប៉ុន្តែជ្រូកថយចុះ ២,៤% និងសេះថយចុះ ២៩,៤%។

**ការចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្ម**

សត្វចិញ្ចឹមជាលក្ខណៈពាណិជ្ជកម្មក្នុងឆ្នាំ២០២២ មានចំនួនសរុប ២៦,៥៦លានក្បាល ក្នុងនោះគោ-ក្របី ចំនួន ១៥,៨៨ពាន់ក្បាល ជ្រូកចំនួន ២,២១លានក្បាល បក្សីចំនួន ២៤,២៤លានក្បាល ចៀមចំនួន ១,៩៣ពាន់ក្បាល ពពែចំនួន ១,០៥ពាន់ក្បាល និងស្វាចំនួន ៨៩,៦៨ពាន់ក្បាល។

ធៀបឆ្នាំ២០២១ ការចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្មមានកំណើន ១៣,៦% ក្នុងនោះ គោ-ក្របីកើន ៧,៣% ជ្រូកកើន ២៥% បក្សីកើន ១២,៦% ចៀមកើន ៥,៦% និងស្វាកើន ៣១,៩%។

**កម្មវិធីកែលម្អពូជ**

ការបង្កាត់គោដោយសិប្បនិម្មិតត្រូវបានអនុវត្តចំនួន ២ ៦១៥ក្បាល និងបង្កើតកូនបានចំនួន ១ ២៧៦ក្បាល (ញី៦២៨ក្បាល) ស្មើនឹង៤៩% នៃមេដែលបានបង្កាត់សិប្បនិម្មិត។ ការបង្កាត់ជ្រូកសិប្បនិម្មិតត្រូវបានអនុវត្តលើជ្រូកមេចំនួន ២២ ៧១៦ក្បាល និងបង្កើតកូនបានចំនួន ១៨៨ ២២១ក្បាល (ញី៩៣ ៦៤០ក្បាល)។

## ការលើកកម្ពស់សុខភាពសត្វ

ក្រសួងបានចាក់វ៉ាក់សាំងការពារជំងឺឆ្លងលើសត្វគោក្របីចំនួន ១ ២៦៧ ៧៤២ក្បាល (ជំងឺអុតក្តាម បូសខ្យល់ សារទឹក និងជំងឺដុំពកស្បែក) ជ្រូកចំនួន ១ ៩៣៨ ៨៤៥ក្បាល បក្សីបានចំនួន ២២ ៦៩៥ ៤៦០ក្បាល និងសត្វឆ្កែឆ្មា ចំនួន ២៧ ២២៧ក្បាល។

លើសពីនេះ ក្រសួងបានចាត់វិធានការជីវសុវត្ថិភាព ផ្សព្វផ្សាយ និងអនុវត្តផ្ទាល់នៅសត្តឃាតដ្ឋាន ទីផ្សារលក់សត្វ កសិដ្ឋានចិញ្ចឹមសត្វ កន្លែងចិញ្ចឹមសត្វ មធ្យោបាយដឹកជញ្ជូនសត្វនិងផលិតផលសត្វ និងកន្លែងផ្ទុះជំងឺសត្វសរុប ចំនួន ២២៣ ២១៩លើក។

បច្ចុប្បន្ននេះ ក្រសួងមានភ្នាក់ងារសុខភាពសត្វភូមិទូទាំងប្រទេសចំនួន ៩ ២៦២នាក់ (ស្ត្រី ៧២២នាក់)។

**ការនាំចេញសត្វ និងផលិតផលសត្វ**

ក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ កម្ពុជាបាននាំចេញគោ-ក្របីចំនួន ៩០,៩០ពាន់ក្បាល ជ្រូកសាច់ចំនួន ៨,៤៥ពាន់ក្បាល ជ្រូកពូជ (មេ,បា,កូន) ចំនួន ៦,៦២ពាន់ក្បាល ស្វាក្តាមចំនួន ៩៨,៧២ពាន់ក្បាល សាច់គោចំនួន ១២តោន ទឹកដោះគោចំនួន ១៤,៤០ពាន់តោន ចំណីឆ្កែចំនួន ១៧,៣២ពាន់តោន រោមសត្វចំនួន១៥២,៥តោន និងស្បែកគោ-ក្របី-ជ្រូកចំនួន ២៥,៨៩ពាន់តោន។ ដោយឡែកនៅឆ្នាំ២០២២ កម្ពុជាបាននាំចេញគោ-ក្របីចំនួន ១៣,៤៥ពាន់ក្បាល ជ្រូកសាច់ចំនួន ៨,៤៥ពាន់ក្បាល ស្វាក្តាមចំនួន ២៥ពាន់ក្បាល ទឹកដោះគោចំនួន ២,៤៧ពាន់តោន ចំណីឆ្កែចំនួន ៧,៦៦ពាន់តោន រោមសត្វចំនួន ១០៥,៧តោន និងស្បែកគោ-ក្របី-ជ្រូកចំនួន ២០,៦៨ពាន់តោន។

**តម្រូវការសត្វ និងសាច់**

ផ្អែកតាមការវាយតម្លៃឆ្នាំ២០២២ ប្រជាជនកម្ពុជាម្នាក់ៗទទួលទានសាច់ជាមធ្យមប្រមាណ ១៨,៥គីឡូក្រាម ក្នុងមួយឆ្នាំ រួមមាន សាច់គោ-ក្របី ៥,១២គីឡូក្រាម សាច់ជ្រូក ៩,៥០គីឡូក្រាម សាច់បក្សីចំនួន ៣,៨៥គីឡូក្រាម និងសាច់ចៀម-ពពែចំនួន ០,០៣គីឡូក្រាម។

ក្នុងឆ្នាំ២០២២ តម្រូវការសាច់មានចំនួនសរុប ៣២២ពាន់តោន ក្នុងនោះ សាច់គោ-ក្របី ៨៩ពាន់តោន សាច់ជ្រូក ១៦៥,៥ពាន់តោន សាច់បក្សី ៦៧ពាន់តោន និងសាច់ចៀម-ពពែឬសាច់ផ្សេងទៀត ០,៥ពាន់តោន។ ផលិតកម្មសត្វក្នុងស្រុកអាចផ្គត់ផ្គង់សាច់បានប្រមាណ ៣០៦ពាន់តោន ឬស្មើនឹង ៩៥% នៃតម្រូវការសរុប ក្នុងនោះសាច់គោ-

ក្របី ៨៩ពាន់តោន (៨១៥ពាន់ក្បាល) សាច់ជ្រូក ១៥២ពាន់តោន (៣ ០៤៩ពាន់ក្បាល) សាច់បក្សី ៦៤ពាន់តោន (៥៣ ៧៣៥ពាន់ក្បាល)។

**ក.៣ ការគ្រប់គ្រងធនធានជលផល និងការអភិវឌ្ឍវារីវប្បកម្ម**

**ផលនេសាទ និងវារីវប្បកម្ម**

ផលនេសាទ និងវារីវប្បកម្មអនុវត្តបានចំនួន ៨៦២ ២០០តោន កើនឡើងចំនួន ៥ ៨០០តោន ស្មើនឹង ០,៦៨% ធៀបឆ្នាំ២០២១ ក្នុងនោះមាន៖

- ផលនេសាទទឹកសាបចំនួន ៤០៦ ៤០០តោន កើនឡើង ២៣ ៣៥០តោន ស្មើនឹង ៦,១០%
- ផលនេសាទសមុទ្រចំនួន ១២៥ ២០០តោន កើនឡើង ២០០តោន ស្មើនឹង ០,១៦%
- ផលវារីវប្បកម្មចំនួន ៣៣០ ៦០០តោន ថយចុះ ១៧ ៧៥០តោន ស្មើនឹង ៥,១០%។

**ការអភិវឌ្ឍន៍វារីវប្បកម្ម**

ការងារនេះសម្រេចបានលទ្ធផលដូចខាងក្រោម៖

- ចិញ្ចឹមត្រីបានចំនួន ៣៣០ ៦០០តោន ថយចុះចំនួន ១៧ ៧៥០តោន ស្មើនឹង ៥% ធៀបឆ្នាំ២០២១
- ចិញ្ចឹមក្រពើបានចំនួន ៣៩១ ៤១៤ក្បាល កើនឡើងចំនួន ៩៩ ៣១៤ក្បាល ស្មើនឹង ៣៤%
- ភ្ញាស់កូនត្រីពូជបានចំនួន ២៨៣លានក្បាល ថយចុះ ៤០លានក្បាល
- បង្កាត់ភ្ញាស់ក្តាមស្រែបានចំនួន ៥ ២២០ក្បាល
- បម្រុងមេពូជត្រីរាជបានចំនួន ៦ក្បាល និងត្រីគល់រាំងចំនួន ២ ២១៤ក្បាល សម្រាប់បង្កាត់ភ្ញាស់យកកូនត្រីទៅលែងក្នុងដែនធម្មជាតិ
- បង្កើតស្រះជម្រកត្រីសហគមន៍បានចំនួន ៩២៩កន្លែង ក្នុងនោះខេត្តកំពង់ស្ពឺមានចំនួនច្រើនជាងគេរហូតដល់ ១៨០កន្លែង
- បង្កើតបណ្តុំវារីវប្បករបានចំនួន ៣៣១កន្លែង មានសមាជិកចំនួន ១០ ៨០៦នាក់ (ស្ត្រី ២ ៩១២នាក់)
- បណ្តុះបណ្តាលការអនុវត្តវារីវប្បកម្មល្អដល់កសិដ្ឋានចំនួន ៨
- ចេញលិខិតអនុញ្ញាតឱ្យធ្វើវារីវប្បកម្មបានចំនួន ៣៥ច្បាប់។

**ការងារបច្ចេកវិទ្យាកែច្នៃ និងគុណភាព**

ក្រសួងបានចុះធ្វើអធិការកិច្ចលើទីតាំងខ្សែច្រវាក់តម្លៃជលផលចំនួន ៦០ទីតាំង នៅក្នុងខេត្តគោលដៅចំនួន ១០ ដោយបានប្រមូលសំណាកសរុបចំនួន ២៥០សំណាក និងបានចេញវិញ្ញាបនបត្រសុខភាពចំនួន ៣៦ ដល់ក្រុមហ៊ុនចំនួន ៥ ដើម្បីនាំចេញផល ផលិតផលជលផលចំនួន ១ ៤៤០តោន ទៅកាន់ទីផ្សារប្រទេសថៃ។

**ការអភិរក្ស និងគ្រប់គ្រងធនធានជលផល**

- កន្លែងអភិរក្សធនធានជលផលទូទាំងប្រទេសមានចំនួន ៦៤២កន្លែង (៥៧៧កន្លែង ក្នុងសហគមន៍នេសាទ និង ៦៥កន្លែង ក្នុងតំបន់អភិរក្សជលផល) ។
- បោះបង្គោលបេតុងកំណត់ព្រំប្រទល់កន្លែងអភិរក្សជលផលចំនួន ៣០បង្គោល បង្គោលឈើក្នុងកន្លែងអភិរក្សជលផលចំនួន ១ ០០០បង្គោល សាងសង់ស្លាក់ការល្បាតចំនួន ៤ខ្នង និងទម្លាក់ប្រអប់បេតុងចំនួន ១០០ប្រអប់
- បោះបង្គោលព្រំប្រទល់ការពារព្រៃលិចទឹកចំនួន១៩០បង្គោល និងដាំព្រៃលិចទឹកបានទំហំ១ ៣៤០ហិកតា
- ផ្សព្វផ្សាយពីសារសំខាន់ព្រៃលិចទឹក និងរៀបចំផែនទីព្រៃលិចទឹកដល់អាជ្ញាធរមូលដ្ឋានបានចំនួន ១៥វគ្គ មានអ្នកចូលរួមចំនួន ៦៥០នាក់
- បង្ក្រាបបទល្មើសធនធានជលផលប្រភេទកំពុងរងគ្រោះចំនួន ៤១ករណី។

**ការអភិវឌ្ឍន៍សហគមន៍នេសាទ**

សហគមន៍នេសាទទូទាំងប្រទេសមានចំនួន ៥១៦ ដែលមានសមាជិកសរុបចំនួន ៣៣២ ១៦៨នាក់ (ស្ត្រី ៣៥%) ស្មើនឹង ១៨៧ ៥១៨គ្រួសារ ក្នុងនោះសហគមន៍នេសាទទឹកសាបចំនួន ៤៧៥ និងសហគមន៍នេសាទសមុទ្រចំនួន ៤១។ សហគមន៍នេសាទចំនួន ៤៨៧ ត្រូវបានក្រសួងចុះបញ្ជីទទួលស្គាល់ ហើយសហគមន៍នេសាទចំនួន ១៧ទៀត កំពុងរៀបចំចុះបញ្ជី។

**ការងារបង្ក្រាបបទល្មើសជលផល**

ក្រសួងបានចងក្រងសំណុំរឿងបទល្មើសជលផលចំនួន ២ ៧៧៨ករណី (សមុទ្រ ១៧៧ករណី) ថយចុះចំនួន ៤៥៣ករណី ធៀបឆ្នាំ២០២១ ដោយបានបំផ្លាញវត្ថុតាងចំនួន ២ ៥៦០ករណី ពិន័យអន្តរការណ៍ចំនួន ៩០ករណី ប្រមូលបានថវិកាចំនួន ២៩៥ ៥៨០ ០០០រៀល។

**ការងារសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផល**

ក្រសួងបានសិក្សាស្រាវជ្រាវ ជីវសាស្ត្រវារីសត្វ សិក្សាតាមដានផលនេសាទតាមដាយត្រី តាមដានប្រភេទកូនត្រី សិក្សា DNA ប្រភេទត្រីទឹកសាប សិក្សាស្រាវជ្រាវការធ្វើចរាចរណ៍នឹងការពងកូនរបស់ត្រីនៅតំបន់មេគង្គលើ និងសិក្សាតាមដានសុខភាពអេកូឡូស៊ីនៅកម្ពុជា និងបានបោះពុម្ពផ្សាយសៀវភៅលទ្ធផលស្រាវជ្រាវជាច្រើនពាន់ក្បាល។

### គ.៤ ការសម្រេចបានក្នុងការកែទម្រង់ផ្នែកព្រៃឈើ

**សហគមន៍ព្រៃឈើ**

គិតត្រឹមឆ្នាំ២០២២ សហគមន៍ព្រៃឈើមានចំនួន ៦៤៥ គ្របដណ្តប់លើផ្ទៃដីសរុប ៥២២ ៨០៨ហិកតា និងមានសមាជិកចំនួន ១៧០ ៦៥៨គ្រួសារ ក្នុងនោះ ក្រសួងបានប្រកាសទទួលស្គាល់ចំនួន ៥៣៨សហគមន៍ (ផ្ទៃដី ៤៥០ ០០៩ហិកតា) បានចុះកិច្ចព្រមព្រៀងបង្កើតព្រៃសហគមន៍ចំនួន ៤៥៥ (ផ្ទៃដី ៣៧៩ ១៤៩ហិកតា) និងបានរៀបចំផែនការគ្រប់គ្រងព្រៃសហគមន៍ចំនួន ១០៦ (ផ្ទៃដី ៧២ ៦២១ហិកតា)។

**ការងារបកស្រាយគម្របព្រៃឈើ**

ក្រសួងបានបញ្ចប់ការវាយតម្លៃផ្ទៃដីគម្របព្រៃឈើឆ្នាំ២០១៨ ដែលមានទំហំ ៨ ៥២៩ ៣៧២ហិកតា ស្មើនឹង ៤៦,៩៧% នៃផ្ទៃដីសរុបទូទាំងប្រទេស និងកំពុងបន្តបកស្រាយគម្របព្រៃឈើឆ្នាំ២០២២ ដោយប្រើរូបភាពផ្កាយរណប និងបានចុះប្រមូលព័ត៌មាននៅទីវាលជាក់ស្តែង តាមចំណុចនិយាមកាសរុបចំនួន ២ ១៥១ចំណុច ក្នុងខេត្តចំនួន ៦ ដើម្បីធ្វើការផ្ទៀងផ្ទាត់។

**ការគ្រប់គ្រងដីស្ថានីយដាំឈើ និងដីព្រៃសហគមន៍**

- ដាំឈើចម្ការឈើថ្មីទំហំ ៣ ២៤៧ហិកតា ក្នុងនោះ ដាំដោយរដ្ឋទំហំ ១២៥ហិកតា ដាំដោយក្រុមហ៊ុនដៃគូសហការ និងប្រជាជនទំហំ ៣ ០៨៩ហិកតា និងដាំរុក្ខទិវារាជធានី-ខេត្ត ទំហំ ៣៣ហិកតា
- បង្កើតស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើចំនួន ៣កន្លែង ក្នុងខេត្តពោធិ៍សាត់ និងក្រចេះ ដែលមានផ្ទៃដីទំហំ ២២ ៥៦៦ហិកតា
- សិក្សាទីតាំងថ្មីសម្រាប់បង្កើតស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើឡើងវិញ ក្នុងខេត្តពោធិ៍សាត់ចំនួន ២កន្លែង ដែលមានផ្ទៃដីសរុបទំហំ ១១២ហិកតា
- ថែទាំចម្ការឈើសរុបទំហំ ៧៤៧ហិកតា ក្នុងនោះចម្ការពូជឈើទំហំ ៩៤ហិកតា ឡូត៍បង្ហាញកសិ-រុក្ខកម្មទំហំ ៣៩ហិកតា ចម្ការឈើដាំទំហំ ៥៨៤ហិកតា និងចម្ការរុក្ខទិវា ៩កក្កដា ទំហំ ៣០ហិកតា នៅខេត្តកំពត កណ្តាល ព្រះសីហនុ កំពង់ធំ កំពង់ឆ្នាំង និងខេត្តក្រចេះ
- ដាំកូនឈើសរុបចំនួន ១៣ ៩៤០ដើម (ធ្នង់ ៤ ៦៨៩ដើម ច្រេស ១ ៥០០ដើម គីនីន ២ ០០០ដើម គ្រញូង ៣ ២០០ដើម ឈើទាល ១៤០ដើម ម៉ៃសាក់ ៦០០ដើម និងប្រេងខ្យល់ ១ ៨១១ដើម) ក្នុងព្រះរាជពិធីរុក្ខទិវា ថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២២ នៅខេត្តបាត់ដំបង

- ទទួលវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុចំនួន ៦ប័ណ្ណ ដែលមានផ្ទៃដីទំហំ ៣៧២ហិកតា ក្នុងនោះ ស្ថានីយផ្សព្វផ្សាយ និងស្ថាព្រៃឈើអូរបឹងរូងចំនួន ៥ប័ណ្ណ ស្មើផ្ទៃដីទំហំ ៣៥៨ហិកតា និងសួនអាពាហ៍ពិពាហ៍វល្លិយាវ ចំនួន ១ប័ណ្ណ ស្មើផ្ទៃដីទំហំ ១៤ហិកតា នៅខេត្តកំពង់ធំ
- បណ្តុះកូនឈើគ្រប់ប្រភេទសរុបចំនួន ៤៧០ ៣៧២ដើម ព្រមទាំងបានពិសោធន៍អាកាស្យា និងប្រេងខ្យល់សរុបចំនួន ៧០ ០០០ដើម ដោយកាត់ត្រួយពីដើមមេ (clone bank)

**ការងារឧស្សាហកម្ម ពាណិជ្ជកម្មព្រៃឈើ និងសហប្រតិបត្តិការអន្តរជាតិ**

- ចេញប្រកាសអនុញ្ញាតឱ្យបង្កើត/ពន្យារសុពលភាពរោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើប្រភេទធំ (ច្រកចេញចូលតែមួយ) ចំនួន ១៦កន្លែង និងរោងម៉ាស៊ីនអារកែច្នៃឈើចំនួន ១៩កន្លែង
- ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញ ជូនក្រុមហ៊ុនចំនួន ១០ ដែលមានបរិមាណឈើកែច្នៃចំនួន ១ ៦៩៦ ម៉ែត្រត្រីគុណ ចំណាំងកម្ទេចឈើចំនួន ១៣ ៥០០តោន គ្រឿងសង្ហារឹមឫស្សីកែច្នៃចំនួន ៦១តោន ជ័រទឹកចំនួន ១៧៧តោន និងធ្យូងអាកាស្យាចំនួន ៨៨តោន
- ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចូល ជូនក្រុមហ៊ុនចំនួន ៣ ដែលមានបរិមាណឈើកែច្នៃចំនួន ២ ៦២១ម៉ែត្រត្រីគុណ
- បន្តអនុវត្តគម្រោងក្រោមកិច្ចសហប្រតិបត្តិការអន្តរជាតិ រវាងរដ្ឋបាលព្រៃឈើ ជាមួយប្រទេសផ្តល់ជំនួយ និងដៃគូអភិវឌ្ឍន៍ចំនួន ១៣គម្រោង ដែលមានទឹកប្រាក់សរុបចំនួន ១១ ៧៩៦ ៣៣៦ដុល្លារអាមេរិក

**ការងារសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ និងសត្វព្រៃ**

- ដំឡើងម៉ាស៊ីនថតរូបស្វ័យប្រវត្តិចំនួន ១៩គ្រឿង ក្នុងតំបន់រេជបូកទំរីង ខេត្តកំពង់ធំ និងខេត្តក្រចេះ ដើម្បីតាមដានវត្តមានសត្វព្រៃ និងកត្តាគំរាមកំហែងសត្វព្រៃ
- ធ្វើសារពើភណ្ឌភ្លុកដំរីដែលមានទម្ងន់សរុប ៦ ៩៨៣,៨៧គីឡូក្រាម ដើម្បីយកទៅរក្សាទុកក្នុងឃ្លាំងសុវត្ថិភាពរបស់ធនាគារជាតិនៃកម្ពុជា
- ប្រមូលសំណាករស់កេសរកូល (អ័រគីដេព្រៃ) បានចំនួន ៤២១ (១៤អំបូរ)
- ចេញលិខិតអនុញ្ញាតដឹកជញ្ជូនសត្វព្រៃចំនួន៦២ច្បាប់៖ ស្វាក្តាម២៧ ៣៣៩ក្បាល (ក្នុងស្រុក ៥ ៣៤៣ក្បាល និងក្រៅស្រុក ២១ ៩៩៦ក្បាល) ដំរីអាស៊ី២ក្បាល ខ្លាធំ២ក្បាល និងសត្វព្រៃផ្សេងទៀត ២២ក្បាល
- នៅរាជធានីភ្នំពេញ (សម្រេចបាន ៧០%) និងសួនអភិរក្សសេនេទិចពូជឈើលើផ្ទៃដីទំហំ១០០ហិកតា នៅស្រុកសូត្រនិគម ខេត្តសៀមរាប (សម្រេចបាន ៤០%) ដោយមានការគាំទ្រថវិកាពីអង្គការ APFNet
- ចងក្រង និងបោះពុម្ពឯកសារបទពិសោធន៍ និងបច្ចេកទេសចំនួន ៥០០ច្បាប់។

**ការគ្រប់គ្រងឧទ្យានសួនសត្វ ព្រៃការពារ និងសួនរុក្ខជាតិ "ភ្នំតាម៉ៅ"**

- ចិញ្ចឹមថែរក្សាសត្វព្រៃចំនួន ១ ៧៤៧ក្បាល
- សង្គ្រោះសត្វព្រៃថ្មីចំនួន ៩៨១ក្បាល ព្យាបាលចំនួន ៤៥៩ក្បាល និងលែងចូលព្រៃវិញចំនួន ៦៨៦ក្បាល
- សាងសង់ទ្រុងសត្វថ្មីទំហំ ៣ ០៤៤ម៉ែត្រការ៉េ និងជួសជុលទ្រុងសត្វទំហំ ១ ៣៤៨ម៉ែត្រការ៉េ
- ដាំកូនឈើចំនួន ១៥៧ ៩៥១ដើម លើផ្ទៃដី ៥៣០ហិកតា សាងសង់របងលួសបន្លា ៥០ ២៨០ម៉ែត្រ និងជីកអាងតម្កល់ទឹកចំនួន ៣កន្លែង។

**ការងារអនុវត្តច្បាប់ស្តីពីព្រៃឈើ**

- ចងក្រងសំណុំរឿងបទល្មើសព្រៃឈើចំនួន ៨៤១ករណី ក្នុងនោះ ពិន័យអន្តរការណ៍ចំនួន ២៥០ករណី និងបញ្ជូនទៅតុលាការចំនួន ៥៩១ករណី
- រៀបចំសេចក្តីព្រាងច្បាប់ស្តីពីព្រៃឈើ កម្រិតក្រុមការងារបច្ចេកទេសអន្តរក្រសួង បច្ចុប្បន្នកំពុងពិនិត្យ និងផ្តល់យោបល់លើផ្នែកទោសប្បញ្ញត្តិនៅក្រសួងយុត្តិធម៌

- អនុវត្តករណីបទល្មើសលាងសម្អាតប្រាក់ចំនួន ៤ករណី និងរៀបចំសិក្ខាសាលាពាក់ព័ន្ធនឹងការលាងសម្អាតប្រាក់ចំនួន ១៦វគ្គ ដោយមានអ្នកចូលរួមចំនួន ៩៩៨នាក់

### គ.៥. ការពង្រឹងសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានមន្ត្រីរាជការសរុបចំនួន ៥ ៩០៦នាក់ (ស្ត្រី ១ ៤៧១នាក់ ស្មើនឹង ២៤,៨៧%) ក្នុងនោះ អង្គភាពថ្នាក់កណ្តាលចំនួន ២ ៩៩៨នាក់ (ស្ត្រី ៨៦៩នាក់ ស្មើនឹង ២៨,៩១%) ថ្នាក់រាជធានី-ខេត្តចំនួន ២ ៩០៨នាក់ (ស្ត្រី ៦០២នាក់ ស្មើនឹង ២០,៧០%)។

ក្រសួងបានផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីរាជការចំនួន ២ ៧៨០នាក់ (ស្ត្រី ៧៥៣នាក់) ក្នុងប្រទេសរយៈពេលខ្លី និងមធ្យមចំនួន ២ ៥៩១នាក់ (ស្ត្រី ៧១៥នាក់) និងរយៈពេលវែងចំនួន ១នាក់ និងក្រៅប្រទេសមានចំនួន ១៨៨នាក់ (ស្ត្រី ៣៨នាក់)។

នៅតាមគ្រឹះស្ថានអប់រំកសិកម្មទាំងបី មាននិស្សិតកំពុងសិក្សាសរុបចំនួន ៤ ៩០២នាក់ (ស្ត្រី ១ ៩០០នាក់) និងនិស្សិតបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររង និងបរិញ្ញាបត្រសរុបចំនួន ១១ ៥៥៣នាក់ (ស្ត្រី ៥ ០៦២នាក់)។

ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រសួងបានទទួលកញ្ចប់ថវិកាសម្រាប់ចំណាយក្នុងឆ្នាំ២០២២ សរុបចំនួន ២៥៨ ៣២៧លានរៀល (ប្រមាណ ៦៣,៧៨លានដុល្លារអាមេរិក) ក្នុងនោះ ថវិកាសម្រាប់រដ្ឋបាលកណ្តាលចំនួន ១៦២ ៤២១ លានរៀល និងមន្ទីររាជធានី-ខេត្តចំនួន ៩៥ ៩០៦លានរៀល និងអនុវត្តសម្រេចបានចំនួន ២៥៤ ៦៨០លានរៀល ស្មើនឹង ៩៨,៦% ធៀបនឹងច្បាប់ហិរញ្ញវត្ថុ។ ទន្ទឹមនឹងនេះ ក្រសួងបានប្រមូលចំណូលមិនមែនសារពើពន្ធចំនួន ៤៣ ១៧២,៩លានរៀល ស្មើនឹង ១១៦,២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២ (៣៧ ១៤៤,៨ លានរៀល) បង់ចូលថវិការដ្ឋ។

ក្រសួងមានកិច្ចសហប្រតិបត្តិការល្អប្រសើរ និងស្អិតរមួតជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ស្ថានទូត អង្គការអន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន។ ក្រសួងបានចុះកិច្ចព្រមព្រៀង/អនុស្សារណៈយោគយល់សរុបចំនួន ២៧ ដែលមានទឹកប្រាក់សរុប ១១២,៦២លានដុល្លារអាមេរិក ក្នុងគម្រោងក្រោមក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការទ្វេភាគី ពហុភាគី និងអង្គការអន្តរជាតិ។

ជាមួយគ្នានេះ ក្រសួងបាននិងកំពុងសហការជាមួយដៃគូអភិវឌ្ឍន៍ រួមមាន ADB, IFAD, AFD, EU និង WB ក្នុងការអនុវត្តគម្រោងចំនួន ១០ ដែលមានថវិកាសរុប ៤១២លានដុល្លារអាមេរិក។

គម្រោងសម្បទានដីសេដ្ឋកិច្ចសរុបមានចំនួន ២៣២គម្រោង ស្ថិតក្នុងខេត្តចំនួន ១៩ ដែលផ្ទៃដីតាមកិច្ចសន្យាមានទំហំ ១ ១៥២ ០៦០ហិកតា ក្នុងនោះផ្ទៃដីអាជីវកម្មទំហំ ៨៨២ ០០៨ហិកតា។

### គ.៦. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ការពិនិត្យតាមដាន និងវាយតម្លៃ គឺជាតម្រូវការចាំបាច់ ដើម្បីធានាដល់ការអនុវត្តគម្រោងសកម្មភាពនិងសូចនាករនានា សម្រាប់ផ្ទៀងផ្ទាត់ជាមួយនឹងលទ្ធភាពសម្រេចបាន ដែលបានកំណត់យ៉ាងសមស្របនៅក្នុងការធ្វើផែនការ និងការរៀបចំគម្រោងសកម្មភាពនីមួយៗ។ ដូច្នេះ ការពិនិត្យតាមដាននិងវាយតម្លៃ គឺជាឧបករណ៍ដ៏ស័ក្តិសិទ្ធិសម្រាប់ផ្ទៀងផ្ទាត់រាល់សូចនាករលទ្ធផល (Outcomes & Outputs) នៅពាក់កណ្តាលអាណត្តិ និងពេញអាណត្តិ នៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៩-២០២៣ និងដើម្បីជាមូលដ្ឋានសម្រាប់វាយតម្លៃការអនុវត្តគោលនយោបាយតាមផ្នែកក៏ដូចជា គោលនយោបាយថ្នាក់ជាតិ។ ទោះបីយ៉ាងណាក៏ដោយ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៩-២០២៣ ក៏នឹងត្រូវបង្ហាញ និងបញ្ជាក់នូវសូចនាករជាច្រើន សម្រាប់ធ្វើការផ្ទៀងផ្ទាត់លទ្ធផលនៃការអនុវត្តផងដែរ។

ដើម្បីធានាដល់ការអនុវត្តយ៉ាងពេញលេញ នូវការពិនិត្យតាមដាននិងវាយតម្លៃ នាយកដ្ឋានផែនការនិងស្ថិតិ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបំពេញតួនាទីយ៉ាងសំខាន់ ក្នុងការអនុវត្តសកម្មភាពតាមដាន និងវាយតម្លៃនេះ។ របាយការណ៍លទ្ធផលការងារសម្រាប់គម្រោងទាំងនោះ ត្រូវរៀបចំឡើងក្នុងអំឡុងពេលអនុវត្ត និងវាយតម្លៃក្រោយពេលអនុវត្ត។ បណ្តានាយកដ្ឋានអង្គភាពជំនាញនានាដែលពាក់ព័ន្ធក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រ នេះបានរាយការណ៍ជូនក្រសួង (**នាយកដ្ឋានផែនការ និងស្ថិតិ**) ពីលទ្ធផលសម្រេចបានឱ្យបានទៀងទាត់ តាមរយៈការផ្តល់របាយការណ៍ប្រចាំត្រីមាស និងប្រចាំឆ្នាំ។ របាយកាណ៍អនុវត្ត និងសមិទ្ធផលសម្រេចបានក្នុងការអនុវត្តនេះ ត្រូវបានរៀបចំបូកសរុបដោយនាយកដ្ឋានផែនការ និងស្ថិតិ ហើយត្រូវរាយការណ៍ជូនក្រសួងពិនិត្យនិងសម្រេច។ ផ្អែកលើរបាយការណ៍ ខាងលើនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ធ្វើការបូកសរុបរបាយការណ៍ រួចរាយការណ៍ជូនទៅក្រសួងផែនការ និងក្រសួងសេដ្ឋកិច្ចនិងហរិញ្ញវត្ថុ ដើម្បីជាមូលដ្ឋានរាយការណ៍ជូន រាជរដ្ឋាភិបាលកម្ពុជា។

## ៣. បញ្ហាប្រឈម

វិស័យកសិកម្មនៅមានសក្តានុពលច្រើនណាស់ ដែលយើងពុំទាន់បានប្រើប្រាស់ឱ្យអស់លទ្ធភាពនៅឡើយ។ ការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម កន្លងមក គឺត្រូវបានវាយតម្លៃថា សម្រេចបានលទ្ធផលគួរជាទីពេញចិត្ត។ ទោះបីជាយ៉ាងនេះក្តី ក៏យើងនៅជួបប្រទះបញ្ហាប្រឈមមួយចំនួនមានជាអាទិ៍៖

ទោះបីជាវិស័យកសិកម្មកម្ពុជាសម្រេចបានការរីកចម្រើនគួរឱ្យកត់សម្គាល់ក្តី ក៏វិស័យនេះជួបប្រទះបញ្ហាប្រឈមមួយចំនួនដែលទាមទារឱ្យមានការយកចិត្តទុកដាក់ដោះស្រាយ។ ជាក់ស្តែង ផលិតភាពនៃផលិតកម្មដំណាំនៅមានកម្រិតទាប ការផ្ទេរបច្ចេកទេសនៅមិនទាន់ឆ្លើយតបតាមតម្រូវការរបស់កសិករ ហេដ្ឋារចនាសម្ព័ន្ធគាំទ្រផលិតកម្ម (ប្រព័ន្ធស្រោចស្រពក្នុងកសិដ្ឋានដោយសន្សំសំចៃទឹក ផ្ទះសំណាញ់ ប្រព័ន្ធស្តុកទុក ឃ្លាំងសម្ងួត ឃ្លាំងត្រជាក់) នៅមិនទាន់មានគ្រប់គ្រាន់សម្រាប់ការធ្វើកសិកម្ម និងកសិ-ពាណិជ្ជកម្ម ការវិនិយោគលើការកែច្នៃកសិផលនៅមានទំហំតូច និងការប្រកួតប្រជែងទីផ្សារពុំទាន់ត្រូវបានដោះស្រាយឱ្យបានល្អប្រសើរ។

ផលិតភាពនៃផលិតកម្មសត្វសម្រាប់កសិករខ្នាតតូចនៅមានកម្រិតទាប ជាមួយនឹងថ្លៃដើមផលិតកម្មខ្ពស់ (ថ្លៃចំណីសត្វ ពូជសត្វ និងថ្នាំការពារ ព្យាបាលសត្វ) ដែលធ្វើឱ្យការប្រកួតប្រជែងទីផ្សារសាច់សត្វជួបការលំបាក។ ទន្ទឹមនឹងនេះ កម្លាំងពលកម្មសម្រាប់ការចិញ្ចឹមសត្វនៅជនបទបានថយចុះ ដែលទាមទារឱ្យមានការជំរុញការចិញ្ចឹមសត្វលក្ខណៈពាណិជ្ជកម្ម។ ការធ្វើផែនការផលិតកម្មសត្វដើម្បីផ្គត់ផ្គង់ក្នុងស្រុក និងនាំចេញនៅមិនទាន់គ្រប់ជ្រុងជ្រោយ។ ប្រព័ន្ធគ្រប់គ្រងអនាម័យ និងភូតគាមអនាម័យនៅមានកម្រិត ការនាំចូលសត្វ និងផលិតផលសត្វខុសច្បាប់នៅតែបន្តកើតមាន។

ការគ្រប់គ្រងធនធានជលផលនៅមានបញ្ហាប្រឈមមួយចំនួន ដូចជា ការរំលោភទន្រ្ទានកាន់កាប់ដីព្រៃលិចទឹក ព្រៃកោងកាង និងការធ្វើនេសាទខុសច្បាប់នៅតែមានបន្ត។ ការធ្វើវារីវប្បកម្មចំណាយថ្លៃដើមខ្ពស់ ជាហេតុនាំឱ្យពិបាកក្នុងការប្រកួតប្រជែងទីផ្សារ រួមទាំងការកង្វះហេដ្ឋារចនាសម្ព័ន្ធក្រោយពេលប្រមូលផល សម្រាប់គាំទ្រដល់ការរក្សាគុណភាព និងការអនុវត្តអនាម័យល្អ។ ការការពារកន្លែងអភិរក្សជលផល ការគ្រប់គ្រងកិច្ចការនេសាទ ការចូលរួមរបស់សហគមន៍នេសាទ សមត្ថភាពមន្ទីរពិសោធន៍សម្រាប់វិភាគគុណភាព សុវត្ថិភាពផល ផលិតផលជលផល និងការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រជលផល នៅមានកម្រិតនៅឡើយ។

នៅក្នុងផ្នែកព្រៃឈើ កំណើនប្រជាពលរដ្ឋ ការរីកលូតលាស់ផ្នែកសេដ្ឋកិច្ចកសិកម្ម និងកំណើននៃតម្រូវការដីសម្រាប់ធ្វើកសិកម្ម គឺជាហេតុផលចម្បងដែលនាំឱ្យមានការធ្លាក់ចុះនូវផ្ទៃដីគ្របដណ្តប់ដោយព្រៃឈើ និងការកើនឡើងនូវបទល្មើសកាប់រានទន្រ្ទានយកដីព្រៃឈើ។ តុល្យភាពរវាងការអនុវត្តច្បាប់ និងផលប្រយោជន៍ប្រជាជនពីការពឹងអាស្រ័យលើព្រៃឈើ នៅតែជាវិញ្ញាសារមួយដ៏ស្មុគស្មាញដែលទាមទារឱ្យមានការគិតគូរយកចិត្តទុកដាក់ខ្ពស់ ដល់ការបង្កើនលទ្ធភាពផ្តល់ការគាំទ្រ និងជម្រើសដល់ប្រជាពលរដ្ឋឱ្យចាប់យកមុខរបរកសិ-រុក្ខកម្ម ឬមុខរបរផ្សេង ព្រមទាំងការជំរុញឧស្សាហកម្មឈើដាំ និងការសម្រួលការនាំចូលឈើ ដើម្បីកាត់បន្ថយសម្ពាធមកលើធនធានព្រៃឈើ។

ការចូលទន្រ្ទានកាន់កាប់ដីជាកម្មសិទ្ធិដែលធ្វើឱ្យដំណើរការចុះបញ្ជីដីរដ្ឋមានភាពស្មុគស្មាញ វិបត្តិជំងឺកូវីដ-១៩ និងភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចសកល ដែលនាំឱ្យក្រុមហ៊ុនអនុវត្តគម្រោងមួយចំនួនមានបញ្ហាដើមទុនវិនិយោគការកើនឡើងនៃថ្លៃឈ្នួលពលកម្ម និងកង្វះកម្លាំងពលកម្មបម្រើក្នុងខ្សែច្រវាក់ផលិតកម្ម រួមទាំងកត្តាមួយចំនួនផ្សេងទៀតសុទ្ធតែជាបញ្ហាប្រឈមចម្បងនៃដំណើរការអនុវត្តគម្រោងសម្បទានដីសេដ្ឋកិច្ច។

## ៤. វិធានការ

### វិធានការគោលនយោបាយសម្រាប់រួមចំណែកអនុវត្តអាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល

គោលនយោបាយជាតិអភិវឌ្ឍន៍កសិកម្មរបស់រាជរដ្ឋាភិបាល ត្រូវបានកំណត់ច្បាស់លាស់លើការលើកកម្ពស់វិស័យកសិកម្មឱ្យក្លាយទៅជាផ្នែកនាំមុខមួយ ដែលអាចផ្តល់ចលករបន្ថែមដល់កំណើនសេដ្ឋកិច្ច និងអាចចូលរួមវិភាគទាន យ៉ាងសំខាន់ដល់ការកាត់បន្ថយភាពក្រីក្រ។ ក្នុងទិសដៅនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងបង្កើន ការអនុវត្តប្រពលវប្បកម្មកសិកម្ម ការបង្កើនសមត្ថភាពបច្ចេកទេសកសិកម្មដល់កសិករ សហគមន៍កសិកម្ម ផ្តល់ហេដ្ឋារចនា សម្ព័ន្ធបម្រើឱ្យផលិតកម្មកសិកម្ម សម្របសម្រួល ដោះស្រាយបញ្ហាទីផ្សារ និងបង្កើនការកែច្នៃកសិផល ជាពិសេស ការកែច្នៃសម្រាប់ការនាំចេញ។

ជាមួយគ្នានេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏បានផ្តោតការយកចិត្តទុកដាក់លើវិស័យអាទិភាពដែលពាក់ព័ន្ធនឹងការអភិវឌ្ឍវិស័យកសិកម្ម មានដូចខាងក្រោម៖

ទី១-បន្តលើកកម្ពស់ការស្រាវជ្រាវដើម្បីអភិវឌ្ឍន៍បច្ចេកវិទ្យា និងបច្ចេកទេសកសិកម្មទំនើប ក្នុងទិសដៅបង្កើនបរិមាណ គុណភាព អាហារូបត្ថម្ភ និងពិពិធកម្មផលិតផលកសិកម្មប្រកបដោយនិរន្តរភាពធន់នឹងការប្រែប្រួលអាកាសធាតុ ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការទីផ្សារក្នុង និងក្រៅប្រទេស។ យកចិត្តទុកដាក់អភិវឌ្ឍធនធានមនុស្ស និងជាពិសេសបង្កើនចំនួនអ្នកស្រាវជ្រាវ និងអ្នកវិទ្យាសាស្រ្តកសិកម្មឱ្យបានច្រើន ដោយផ្តល់ការលើកទឹកចិត្តដល់អ្នកស្រាវជ្រាវ និង អ្នកវិទ្យាសាស្រ្តជាចាំបាច់។ ត្រូវធ្វើកសិកម្មចម្រុះប្រកបដោយភាពវៃឆ្លាត មិនត្រូវធ្វើតែដំណាំស្រូវមួយមុខ ឬការធ្វើតាមគ្នាដោយមិនបានវិភាគឱ្យបានស៊ីជម្រៅនោះឡើយ។ ទន្ទឹមនឹងនេះ ត្រូវយកចិត្តទុកដាក់ជំរុញការប្រើប្រាស់បច្ចេកវិទ្យាកសិកម្មថ្មីៗ ប្រកបដោយនវានុវត្តន៍ មានជាអាទិ៍ ការអនុវត្តកសិកម្មល្អ ការកែលម្អការគ្រប់គ្រង និងប្រើប្រាស់ធនធានដីប្រកបដោយចីរភាព ការកែលម្អប្រព័ន្ធស្រោចស្រព និងការគ្រប់គ្រងទឹក ការប្រើប្រាស់យន្តូបនីយកម្មកសិកម្ម និងបច្ចេកវិទ្យាក្រោយប្រមូលផល ការបង្កើនភាពធន់នឹងអាកាសធាតុ និងគ្រោះ ធម្មជាតិ ការលើកកម្ពស់គុណភាពនៃការផ្តល់សេវាផ្សព្វផ្សាយកសិកម្ម ឱ្យបានទៅដល់សហគមន៍កសិកម្ម ព្រមទាំងពង្រឹង ការគ្រប់គ្រង និងត្រួតពិនិត្យពូជដំណាំកសិកម្ម និងធាតុចូលកសិកម្មរួមទាំង ការកែលម្អពូជសត្វ ការពង្រឹងសមត្ថភាព មន្ទីរពិសោធន៍ជាតិ កសិដ្ឋានផលិតពូជ ស្ថានីយ និងមជ្ឈមណ្ឌល

ស្រាវជ្រាវ និងផ្សព្វផ្សាយកសិកម្មឱ្យបានល្អប្រសើរ។ ត្រូវជំរុញការរៀបចំកសាងលិខិតបទដ្ឋានគតិយុត្ត និងច្បាប់ពាក់ព័ន្ធនឹងវិស័យកសិកម្ម ព្រមទាំងផែនការយុទ្ធសាស្ត្រ អភិវឌ្ឍន៍តាមអនុវិស័យនីមួយៗ។

ទី២- ពង្រឹងសមត្ថភាពសហគមន៍កសិកម្ម និងសហគមន៍អ្នកចិញ្ចឹមសត្វដែលបានចុះបញ្ជីរួចហើយ ឱ្យមានលក្ខណៈជាពាណិជ្ជកម្ម ដោយជំរុញឱ្យអនុវត្តបច្ចេកវិទ្យាសមស្រប ការផ្គត់ផ្គង់និងសន្សំសំចៃទឹកនៅតាមសហគមន៍ កសិកម្ម និងអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា ព្រមទាំងលើកកម្ពស់ការចូលរួមវិនិយោគពីវិស័យឯកជនក្នុងគ្រប់ខ្សែច្រវាក់តម្លៃកសិកម្ម តាមអភិក្រមភាពជាដៃគូរវាង "រដ្ឋ-ឯកជន និងផលិតករ" ឱ្យមានលក្ខណៈប្រទាក់ក្រឡាគ្នាក្នុងការរកទីផ្សារបន្ថែមសម្រាប់ផលិតផលកសិកម្មជាអាទិភាព។ លើសពីនេះទៀត ត្រូវពិនិត្យមើលលទ្ធភាពធ្វើយ៉ាងណាឱ្យសហគមន៍អាចទទួលបានផលប្រយោជន៍ និងមានចំណូលសម្រាប់ដំណើរការអភិវឌ្ឍរបស់ខ្លួនប្រកបដោយភាពម្ចាស់ការ។ ទន្ទឹមនឹងនេះ ត្រូវបន្តសហការជាមួយដៃគូអភិវឌ្ឍន៍នានា និងស្វែងរកដៃគូថ្មីៗទៀត ដើម្បីអនុវត្តគម្រោងបណ្តុះបណ្តាលសមត្ថភាពដល់មន្ត្រីជំនាញ និងបង្កើនសកម្មភាពសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍សហគមន៍ ព្រមទាំងជំរុញនិងរួមគ្នាធ្វើការអប់រំ ផ្សព្វផ្សាយបណ្តុះបណ្តាល បំពាក់បំប៉នដល់សហគមន៍មូលដ្ឋានឱ្យយល់ដឹងជាសាធារណៈ អំពីការអភិវឌ្ឍវិស័យកសិកម្ម។

ទី៣- ពង្រឹង និងពង្រីកសហគមន៍កសិករកៅស៊ូគ្រួសារ ដើម្បីបង្កើនកាលានុវត្តភាពក្នុងការការពារផលប្រយោជន៍របស់កសិករ ទាំងការដាំដុះ ការយកផល ការកែច្នៃ ព្រមទាំងអំណាចនៃការចរចាថ្លៃនៅពេលលក់ផលិតផលទាំងនោះ។ ជំរុញការវិនិយោគលើការកែច្នៃផលិតផលកៅស៊ូ ដើម្បីបង្កើនតម្លៃបន្ថែម បង្កើតការងារ ចូលរួមកាត់បន្ថយភាពក្រីក្រនៅជនបទ។ ជាមួយគ្នានេះ ត្រូវពិនិត្យ និងរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដើម្បីអភិវឌ្ឍន៍ឧស្សាហកម្មកៅស៊ូធម្មជាតិប្រកបដោយនិរន្តរភាព។

ទី៤- ជំរុញការធ្វើពិពិធកម្មកសិកម្មទៅរកផលិតផលដែលមានតម្លៃបន្ថែមខ្ពស់ និងមានសក្តានុពលលើដំណាំ ការចិញ្ចឹមសត្វ វារីវប្បកម្ម ផលិតផលឈើដាំ និងការវិនិយោគលើការកែច្នៃកសិផលសំខាន់ៗ ដោយត្រូវបន្តលើកកម្ពស់គុណភាព និងសុវត្ថិភាពផលិតផលកសិកម្ម ការកែច្នៃវេចខ្ចប់ និងពង្រឹងសមត្ថភាពពិសោធន៍ ស្តង់ដារគុណភាព ក៏ដូចជាពង្រឹងវិធានការការពារដំណាំ អនាម័យ និងភូតគាមអនាម័យ (SPS) តាមរយៈការចរចាជាមួយបណ្តាប្រទេសដែលទិញផលិតផលកសិកម្មពីកម្ពុជា ការរៀបចំពិធីសារស្តីពីការនាំចេញផលិតផលកសិកម្មកម្ពុជាទៅកាន់ទីផ្សារអន្តរជាតិ។

ទី៥- ជំរុញការចិញ្ចឹមសត្វរបស់កសិករឱ្យទៅជាការចិញ្ចឹមជាលក្ខណៈពាណិជ្ជកម្ម ជាពិសេសការចិញ្ចឹមគោពូជកូនកាត់ ដើម្បីបង្កើនប្រាក់ចំណូល ព្រមទាំងលើកទឹកចិត្តដល់ការចិញ្ចឹមសត្វខ្នាតតូច មធ្យម និងខ្នាតធំដែលមានផលិតភាពខ្ពស់ ប្រកបដោយគុណភាព សុវត្ថិភាព និងប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់ ដើម្បីផ្គត់ផ្គង់តម្រូវការក្នុងស្រុក និងបង្កើនសមត្ថភាពប្រកួតប្រជែងសម្រាប់ការនាំចេញ។ គ្រប់គ្រងការធ្វើអាជីវកម្មសត្វរស់ ផលិតផលសត្វ ចំណីសត្វបសុឱសថ និងធាតុចូលផ្សេងៗ ដោយមិនឱ្យមានការធ្វើអាជីវកម្មផ្តាច់មុខដែលប៉ះពាល់ដល់តម្លៃ និងបញ្ហាទីផ្សារ។ ត្រូវជំរុញការកែច្នៃផលិតផលសាច់ ដោយត្រូវគ្រប់គ្រងសត្តឃាតដ្ឋាន កន្លែងពិឃាតសត្វ និងកន្លែងកែច្នៃ ឱ្យអនុវត្តតាមបទដ្ឋានបច្ចេកទេសបសុព្យាបាល និងមានការត្រួតពិនិត្យអនាម័យសាច់ និងផលិតផលសត្វ ធានាបាននូវគុណភាពអនាម័យ និងសុវត្ថិភាពសាច់សម្រាប់ធានាតម្រូវការក្នុងស្រុក និងឆ្ពោះទៅរកការនាំចេញទៅបរទេស។ ជាមួយគ្នានេះត្រូវពង្រឹងការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលសត្វ ដើម្បីបង្ការការពារជំងឺឆ្លងរាលដាលសត្វ ផលិតផលសត្វប្រកបដោយសុវត្ថិភាព និងគ្រប់គ្រងហានីភ័យជំងឺរាតត្បាតនានាជាយថាហេតុ។ ព្រមជាមួយនោះ ត្រូវពង្រឹងការអនុវត្តច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ និងត្រូវរៀបចំកសាងលិខិតបទដ្ឋានក្រោមច្បាប់ឱ្យមានប្រសិទ្ធភាពខ្ពស់។

ទី៦- បង្កើតស្ថានីយ៍ចត្តាឡីស័ក ដំណាំ សត្វ និងជលផល នៅតាមតំបន់សំខាន់ៗ ដើម្បីទប់ស្កាត់ការឆ្លងរាលដាលសមាសធាតុចង្រៃ ជំងឺសត្វ និងជំងឺស៊ូណូស ជំងឺត្រី និងទប់ស្កាត់ការនាំចូល នាំចេញ ឆ្លងកាត់នូវផលិតផលកសិកម្មខូចគុណភាព ដែលនាំឱ្យប៉ះពាល់ដល់សុខភាពសាធារណៈ និងខូចទីផ្សារក្នុងស្រុក និងនាំចេញ។

ជំរុញឱ្យក្រសួងស្ថាប័នពាក់ព័ន្ធ ពិសេសរដ្ឋបាលខេត្តនៅជាប់ព្រំដែន ត្រូវសហការឱ្យមានលក្ខណៈប្រទាក់ក្រឡាគ្នាក្នុងការគ្រប់គ្រង ឱ្យមានប្រសិទ្ធភាព ព្រមទាំងក្តាប់ឱ្យបាននូវព័ត៌មាន និងទិន្នន័យនៃការនាំចូល និងនាំចេញផលិតផលកសិកម្ម ពីបណ្ដាប្រទេសជិតខាង ដើម្បីធានានូវការគ្រប់គ្រងផលស្តុកក្នុងស្រុក និងផលប៉ះពាល់ទីផ្សារក្នុងតំបន់ក្នុងស្មារតីទទួលខុសត្រូវខ្ពស់។

ទី៧-ពង្រឹងសមត្ថភាពរបស់សហគមន៍នេសាទឱ្យបានរឹងមាំ ក្លាយជាសហគមន៍នេសាទគ្មានបទល្មើសជលផល ទាំងទឹកសាបនិងសមុទ្រ។ ជាមួយគ្នានេះ ត្រូវជំរុញការអភិវឌ្ឍវារីវប្បកម្មគ្រប់ប្រភេទទៅតាមស្ថានភាពជាក់ស្តែង ព្រមទាំង ត្រូវបន្តពង្រឹងការគ្រប់គ្រង និងការពារកន្លែងអភិរក្សជលផលឱ្យមានប្រសិទ្ធភាពខ្ពស់ ពិសេសត្រូវថែរក្សាការពារព្រៃលិច ទឹក និងព្រៃកោងកាងឱ្យបានគង់វង្ស ដែលជាជម្រកដ៏សំខាន់របស់មច្ឆជាតិ។ លើសពីនេះទៀត បន្តចូលរួមធ្វើវិសោធនកម្ម ច្បាប់ស្តីពីជលផល និងត្រូវខិតខំរៀបចំលិខិតបទដ្ឋានគតិយុត្ត ជំរុញការអនុវត្តអនុសញ្ញាអន្តរជាតិពាក់ព័ន្ធ ដើម្បីប្រយុទ្ធប្រឆាំងការនេសាទល្មើសច្បាប់ គ្មានការអនុញ្ញាត និងគ្មានរបាយការណ៍ (IUU Fishing) ដោយត្រូវបង្កើតយន្តការ ថ្នាក់ជាតិឱ្យមានលក្ខណៈប្រទាក់ក្រឡាគ្នា ជាមួយអន្តរស្ថាប័នស្របតាមនីតិវិធីជាធរមាន។

ទី៨- ត្រូវបន្តពង្រឹងសហគមន៍ព្រៃឈើ ដោយជួយប្រជាសហគមន៍ជនបទឱ្យបង្កើនចំណូល លើកកម្ពស់ជីវភាពរស់នៅតាមរយៈប្រព័ន្ធកសិ-រុក្ខកម្ម។ ក្នុងគោលដៅពង្រីកគម្របព្រៃឈើ ត្រូវបន្តជំរុញការស្តារដាំដុះព្រៃឈើឡើងវិញនៅលើដីព្រៃរេចរិល ដីព្រៃរងការធ្វើអាជីវកម្ម ដីទំនេររបស់រដ្ឋ និងដីព្រៃដែលបានដកហូតពីសម្បទានដីសេដ្ឋកិច្ច ដោយសហការ ជាមួយវិស័យឯកជន ដៃគូអភិវឌ្ឍន៍ ព្រមទាំងបង្កើនការបណ្តុះកូនឈើគ្រប់ប្រភេទនៅតាមស្ថានីយសម្រាប់ចែកចាយ ជូនប្រជាពលរដ្ឋដាំដុះ។ ជាមួយគ្នានេះ ត្រូវរៀបចំបង្កើតសួនរុក្ខសាស្ត្រ (Botanical Garden) នៅតាមតំបន់អេកូឡូស៊ីរុក្ខជាតិកម្ពុជា ក្នុងគោលបំណងអប់រំបណ្តុះបណ្តាល និងផ្សព្វផ្សាយនូវប្រភេទរុក្ខជាតិមានដោយកម្រ និង ជិតផុតពូជ ព្រមទាំងដាក់តាំងបង្ហាញនូវសំណាកប្រភេទរុក្ខជាតិសំខាន់ៗ ប្រភេទគ្រួសារ និងអំបូរដទៃទៀត ដោយ ប្រើប្រាស់ប្រភពថវិកាមូលនិធិអភិវឌ្ឍន៍ព្រៃឈើជាតិ និងពីប្រភពផ្សេងៗទៀត។ សហការជាមួយគណៈបញ្ជាការ ឯកភាពរាជធានី ខេត្ត ដើម្បីចូលរួមឱ្យបានល្អ ក្នុងការស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើ និងការកាប់រាន ដីព្រៃឈើឱ្យមានប្រសិទ្ធភាព។ តំបន់សម្បទានសេដ្ឋកិច្ច ដែលនៅសេសសល់ពីមុនមកនឹងត្រូវស្ថិតនៅក្រោមការត្រួត ពិនិត្យដ៏តឹងរឹង ដើម្បីធានាថា ដំណើរការដីសម្បទានសេដ្ឋកិច្ចទាំងនោះប្រព្រឹត្តទៅប្រកបដោយចីរភាព និងប្រសិទ្ធភាពខ្ពស់។ ព្រមជាមួយនោះ ត្រូវចូលរួមធ្វើវិសោធនកម្មច្បាប់ស្តីពីព្រៃឈើ និងរៀបចំកសាងលិខិតបទដ្ឋានក្រោមច្បាប់ ព្រមទាំងពង្រឹងការអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាពខ្ពស់។

ទី៩- បន្តចុះស្រាវជ្រាវ រុករក និងបង្ក្រាបបទល្មើសព្រៃឈើ ជលផល ការកាប់រាន ដុត ឈូសឆាយដីព្រៃឈើ និងព្រៃលិចទឹកយកដីធ្វើកម្មសិទ្ធិតាមគ្រប់រូបភាព ដោយប្រើប្រាស់កម្លាំងចម្រុះ អាជ្ញាធរដែនដី កងកម្លាំងប្រដាប់អាវុធ អង្គភាពពាក់ព័ន្ធ និងតុលាការ ព្រមទាំងបន្តយកចិត្តទុកដាក់ជំរុញការបោះបង្គោលព្រំព្រៃឈើ និងព្រៃលិចទឹកឱ្យបានឆាប់រហ័ស ដើម្បីទប់ស្កាត់ និងកាត់បន្ថយឱ្យបានជាអតិបរមានូវការរំលោភបំពានលើដីព្រៃឈើ និងព្រៃលិចទឹកជាដើម។

ទី១០- ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជិតខាង និងបណ្តាប្រទេសដៃគូអភិវឌ្ឍន៍នានា ទាំងក្នុងក្របខ័ណ្ឌទ្វេភាគី ពហុភាគី និងកិច្ចសហប្រតិបត្តិការថ្នាក់តំបន់និងអន្តរជាតិ ដើម្បីស្វែងរកជំនួយហិរញ្ញវត្ថុ និងជំនួយបច្ចេកទេសថ្មីៗ សម្រាប់ការធ្វើទំនើបភាវូបនីយកម្មកសិកម្ម ធ្វើការចរចាដើម្បីស្វែងរកទីផ្សារសម្រាប់ការនាំចេញផលិតផលកសិកម្មឱ្យបានទូលំទូលាយជាមួយប្រទេសនានា។ លើកទឹកចិត្តដល់អ្នកវិនិយោគទុនពីខាងក្នុង និងក្រៅប្រទេស បង្កើនទុនវិនិយោគក្នុងវិស័យកសិកម្មលើគ្រប់ខ្សែច្រវាក់តម្លៃកសិកម្ម ពិសេសការកែច្នៃផលិតផលកសិកម្ម ដើម្បីផ្សារភ្ជាប់កសិករ ឬសហគមន៍កសិកម្ម ទៅនឹងទីផ្សារតាមអភិក្រមភាពជាដៃគូរវាងរដ្ឋ ឯកជន និងអ្នកផលិត។ ទន្ទឹមនឹងនេះ ត្រូវជំរុញដល់ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ អង្គការជាតិ-អន្តរជាតិទាំងអស់ ឱ្យបន្តគាំទ្រការលើកកម្ពស់ និងជំរុញ

ការអភិវឌ្ឍវិស័យកសិកម្មតាម គ្រប់រូបភាព ដើម្បីធានាឱ្យមានសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ទាំងនៅក្នុងកម្រិតគ្រួសារ សហគមន៍ និងថ្នាក់ជាតិ។ ជាមួយគ្នានេះ គោលនយោបាយ និងផែនការយុទ្ធសាស្ត្រពាក់ព័ន្ធនឹងអនុវិស័យ នៃវិស័យកសិកម្ម នឹងត្រូវជំរុញរៀបចំ និងដាក់ឱ្យអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់។

## II. គោលបំណងគោលនយោបាយ

ដើម្បីសម្រេចបាននូវគោលដៅជាយុទ្ធសាស្ត្រ និងវិស័យអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានកំណត់គោលនយោបាយរួមមួយរបស់ខ្លួន ដើម្បីចូលរួមចំណែកក្នុងកំណើនការងារ សមធម៌ និងប្រសិទ្ធភាព សំដៅសម្រេចឱ្យបាននូវគោលដៅកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់កម្រិតជីវភាពរបស់ ប្រជាពលរដ្ឋ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានគោលនយោបាយរួម គឺដូចខាងក្រោម៖

**"ជំរុញកំណើនកសិកម្ម តាមរយៈការបង្កើនផលិតភាព ការធ្វើពាណិជ្ជូបនីយកម្ម ពិពិធកម្មកសិកម្ម និងជំរុញឧីជីថលូបនីយកម្ម ប្រកបដោយភាពប្រកួតប្រជែង បរិយាបន្ន ដែលផ្តល់នូវផលិតផលមានគុណភាពខ្ពស់ មានសុវត្ថិភាព និងធានាបាននូវសន្តិសុខស្បៀង ដោយត្រូវគិតគូរខ្ពស់ដល់ការគ្រប់គ្រងដីធ្លី ទឹក ធនធានព្រៃឈើ និងជលផល"។**

| គោលបំណង គោលនយោបាយ | មុំនៃយុទ្ធសាស្ត្រចតុកោណ នៅក្នុង ផ.យ.អ.ជ | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម នៅក្នុង ផ.យ.អ.ជ |
|---|---|---|
| *" ជំរុញកំណើនកសិកម្ម តាមរយៈការបង្កើនផលិតភាព ការធ្វើពាណិជ្ជូបនីយកម្ម ពិពិធកម្មកសិកម្ម និងជំរុញឌីជីថលូបនីយកម្ម ប្រកបដោយភាពប្រកួតប្រជែង បរិយាបន្ន ដែលផ្តល់នូវផលិតផលមានគុណភាពខ្ពស់ មានសុវត្ថិភាព និងធានាបាននូវសន្តិសុខស្បៀង ដោយត្រូវគិតគូរខ្ពស់ដល់ការគ្រប់គ្រងដីធ្លី ទឹក ធនធានព្រៃឈើ និងជលផល"* | មុំទី១ នៃយុទ្ធសាស្ត្រចតុកោណ | ការលើកស្ទួយវិស័យកសិកម្ម និងអភិវឌ្ឍជនបទ |
| | មុំទី២ នៃយុទ្ធសាស្ត្រចតុកោណ | ការគ្រប់គ្រងធនធានធម្មជាតិ និងវប្បធម៌ដោយចីរភាព |
| | មុំទី៤ នៃយុទ្ធសាស្ត្រចតុកោណ | ការធានាចីរភាពបរិស្ថាន និងការរៀបចំខ្លួនឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ |

## III. កម្មវិធី/យុទ្ធសាស្ត្រអាទិភាព

## ក. កម្មវិធីនិងយុទ្ធសាស្ត្រអាទិភាព

ដើម្បីធ្វើឱ្យសម្រេចបាននូវគោលបំណងគោលនយោបាយ និងយុទ្ធសាស្ត្រអាទិភាពខាងលើ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានរៀបចំកម្មវិធីអាទិភាពសំខាន់ៗចំនួន០៥ ជាផ្នែកមួយនៃការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ សំដៅពង្រឹងការអនុវត្តថវិកាតាមកម្មវិធី និងកម្មវិធីវិនិយោគសាធារណៈ។ កម្មវិធីទាំង៥នោះរួមមាន៖

***កម្មវិធីទី-១÷ ការបង្កើនផលិតភាព ពិពិធកម្មដំណាំកសិកម្ម និងកសិធុរកិច្ច***

***កម្មវិធីទី-២÷ ការលើកកម្ពស់ផលិតកម្មសត្វ និងសុខភាពសត្វ***

***កម្មវិធីទី-៣÷ ការគ្រប់គ្រងធនធានជលផល និងការអភិវឌ្ឍវារីវប្បកម្ម***

***កម្មវិធីទី-៤÷ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានព្រៃឈើនិងសត្វព្រៃ***

***កម្មវិធីទី-៥÷ ការគ្រប់គ្រងស្ថាប័ន និងការអភិវឌ្ឍធនធានមនុស្ស***




កម្មវិធីចំនួន៥ ដោយកម្មវិធីនីមួយៗ មានគោលបំណងច្បាស់លាស់សម្រាប់តម្រង់ទិសក្នុងការអនុវត្តគោលបំណងនៃកម្មវិធីទាំង៥ នោះ ត្រូវបានកំណត់ដូចខាងក្រោម៖

### កម្មវិធីទី-១៖ ការបង្កើនផលិតភាព ពិពិធកម្មដំណាំកសិកម្ម និងកសិធុរកិច្ច

**<u>គោលបំណងកម្មវិធីទី១</u>÷** "កំណើនផលិតកម្មដំណាំក្នុងរង្វង់៥% និងបង្កើនការនាំចេញផលិតផលដំណាំកសិកម្ម ៧% ក្នុងមួយឆ្នាំ ដោយធ្វើទំនើបកម្មកសិកម្ម បង្កើនផលិតភាព ពិពិធកម្មដំណាំដែលមានសក្តានុពល និងមានការប្រកួតប្រជែងទីផ្សារខ្ពស់"។

ដើម្បីសម្រេចនូវគោលដៅសូចនាករនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងបន្តជំរុញការបង្កើនផលិតភាព គុណភាព និងពិពិធកម្ម តាមរយៈការបង្កើនការវិនិយោគប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តសិទ្ធិលើការស្រាវជ្រាវ និងការអភិវឌ្ឍពូជដំណាំដែលផ្តល់តម្លៃបន្ថែមខ្ពស់ ជាមួយនឹងបច្ចេកវិទ្យាវៃឆ្លាត ឌីជីថល និងទាន់សម័យ ការផ្សព្វផ្សាយដោយផ្ទាល់ដល់កសិករនៅទីជនបទដែលខ្វះជំនាញបច្ចេកទេស ការតភ្ជាប់រវាងសហព័ន្ធ ឬ សហគមន៍កសិកម្ម និងវិស័យឯកជន តាមរយៈយន្តការផលិតកម្មកសិកម្មតាមកិច្ចសន្យា លើកកម្ពស់ផលិតភាព និងប្រសិទ្ធភាពលើការប្រើប្រាស់ទឹក ព្រមជាមួយនឹងការពង្រីកផ្ទៃដីស្រោចស្រព ការរៀបចំយុទ្ធសាស្ត្រទ្រទ្រង់ដល់ការផ្តល់សេវាធានារ៉ាប់រងផលិតកម្មកសិកម្ម ការពង្រឹងយន្តការការអនុវត្តកសិកម្មល្អ និងការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពនៃផលិតផលកសិកម្ម។

លើសពីនេះទៀត ក្រសួងបន្តជំរុញកសិ-ឧស្សាហកម្មកែច្នៃផលិតផលកសិកម្ម តាមរយៈការលើកទឹកដល់អ្នកវិនិយោគកសិ-ចំណីអាហារ និងពង្រីកឱ្យមានការវិនិយោគឯកជនលើផលិតផលកសិកម្ម ដែលមានសក្តានុពលដូចជា ស្រូវ ពោត ដំឡូងមី ពពួក សណ្តែក បន្លែ ស្វាយ ស្វាយចន្ទី ចេក កៅស៊ូ ផលិតផលសត្វ និងផលិតផលជលផល ជាដើម ដោយបន្តផ្តល់ការលើកទឹកចិត្តផ្នែកសារពើពន្ធ ការកាត់បន្ថយថ្លៃអគ្គិសនី អត្រាការប្រាក់ និងចំណាយឡូជីស្ទីក

ពិសេសជំរុញគម្រោង សាងសង់ឃ្លាំងស្តុក និងឡសម្ងួតបន្ថែមពីគម្រោងអន្តរាគមន៍របស់រាជរដ្ឋាភិបាល តាមរយៈយន្តការនៃការវិនិយោគរួមគ្នារវាងវិស័យសាធារណៈ និងវិស័យឯកជន ឬហិរញ្ញប្បទានពីបរទេស។

➤ **ជំរុញផលិតកម្ម និងផលិតភាពដំណាំដែលមានសក្តានុពលទីផ្សារខ្ពស់**

– ការបង្កើនផលិតភាព ពិពិធកម្មកសិកម្ម លើមុខដំណាំដែលមានផលចំណេញខ្ពស់ និងមានតម្រូវការ ទីផ្សារ បង្កើនគុណភាព និងសុវត្ថិភាពនៃផលិតផលកសិកម្ម ដោយត្រូវអនុវត្តផលិតកម្មកសិកម្មសរីរាង្គ ឬការអនុវត្តកសិកម្មល្អ (Good Agriculture Practice-GAP)

– បន្តការលើកកម្ពស់យន្តនីយកម្មកសិកម្មតាមរយៈ (១)ការជំរុញការប្រើប្រាស់គ្រឿងយន្តកសិកម្ម (២)ការបង្កើតមជ្ឈមណ្ឌលថែទាំ ការអភិវឌ្ឍវិស្វកម្មកសិកម្ម ស្រាវជ្រាវ ផលិតឧបករណ៍ដើម្បីបំពាក់ ក្នុងកសិដ្ឋានគំរូ និង (៣)ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាប្រកបដោយភាពច្នៃប្រឌិតខ្ពស់នៅក្នុងគ្រប់ដំណាក់ខ្សែផលិតកម្មកសិកម្មដើម្បីធានាបាននូវគុណភាព សុវត្ថិភាព និងប្រសិទ្ធភាពខ្ពស់ កាត់បន្ថយជាអតិបរមាដល់ការហូរច្រោះ ខូចគុណភាពដី ការខ្វះខាតខ្វាយថាមពល ទឹក និងការបាត់បង់ផលដែលផលិតបាន

– បន្តជំរុញការគ្រប់គ្រងនិងប្រើប្រាស់ដីកសិកម្ម ប្រកបដោយចីរភាព តាមរយៈការទប់ស្កាត់បញ្ហាឱនភាពដី ការកំណត់តំបន់ដាំដុះ ការកែលម្អជីជាតិដី និងការបន្សាំជាមួយនឹងការប្រែប្រួលអាកាសធាតុក្នុងគោលបំណងជំរុញដំណាំទៅតាមតំបន់មានសក្តានុពល និងទាក់ទាញវិនិយោគទុន

– បន្តការអភិវឌ្ឍ ការលើកកម្ពស់គុណភាព ផលិតភាព និងបរិមាណ ព្រមទាំងស្តង់ដារូបនីយកម្មដំណាំ តាមរយៈកិច្ចសហប្រតិបត្តិការស្រាវជ្រាវជាមួយស្ថាប័នជាតិនិងអន្តរជាតិ ការផ្តល់សេវាបច្ចេកទេសដល់កសិករ និងសហគមន៍កសិកម្ម ព្រមទាំងសម្របសម្រួលនិងជំរុញលើការផលិត ឱ្យស្របតាមតម្រូវការទីផ្សារ។

➤ **លើកកម្ពស់ការការពារដំណាំ គុណភាព និងសុវត្ថិភាពផលិតផលកសិកម្ម**

– បន្តពង្រឹងសមត្ថភាពស្ថាប័ន និងអភិវឌ្ឍន៍អាជីវកម្មមុខរបរសហគមន៍កសិកម្ម ដើម្បីឱ្យក្លាយទៅជាសហគ្រាសសេដ្ឋកិច្ចកសិកម្មជនបទរឹងមាំមួយ តាមរយៈ ការពង្រឹងសមត្ថភាព ការរៀបចំវេទិកាធុរៈកិច្ច សហគមន៍កសិកម្ម ការផ្តល់អនុសាសន៍លើការងារដឹកនាំនិងគ្រប់គ្រង និងការវាយតម្លៃសមត្ថភាពសហគមន៍កសិកម្ម

– ពង្រឹងការត្រួតពិនិត្យអនាម័យ និងភូតគាមអនាម័យ (SPS) តាមរយៈការពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងពង្រឹងសមត្ថភាពមន្ត្រីភូតគាមអនាម័យនៅតាមទីស្នាក់ការត្រួតពិនិត្យភូតគាមអនាម័យ ដើម្បីធានានូវប្រសិទ្ធភាពក្នុងការត្រួតពិនិត្យ និងមានការទទួលស្គាល់ជាអន្តរជាតិ

– បន្តពង្រឹងលើការគ្រប់គ្រងធាតុចូលកសិកម្ម និងអភិវឌ្ឍសមត្ថភាពមន្ទីរពិសោធន៍ជាតិកសិកម្ម តាមរយៈការជំរុញយន្តការវិភាគគុណភាព និង សុវត្ថិភាពផលិតផលកសិកម្ម។

➤ **លើកកម្ពស់ការអភិវឌ្ឍសហគមន៍កសិកម្ម**

– ពង្រឹង និងជំរុញការអភិវឌ្ឍសហគមន៍កសិកម្ម ដើម្បីធ្វើឱ្យសហគមន៍ជាកន្លែងផលិតទ្រង់ទ្រាយធំ ដោយភ្ជាប់ជាមួយផលិតកម្មកសិកម្មតាមកិច្ចសន្យាដែលជាគន្លឹះក្នុងការដោះស្រាយទីផ្សារកសិផល

– ពង្រឹងសមត្ថភាពសហគមន៍កសិកម្មដែលបានចុះបញ្ជីរួច ឱ្យមានលក្ខណៈជាជំនាញ អាជីព ដោយជំរុញឱ្យអនុវត្តបច្ចេកវិទ្យាសមស្រប ការផ្គត់ផ្គង់ និងសន្សំសំចៃទឹកនៅតាមសហគមន៍កសិកម្មការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា និងលើកកម្ពស់ការចូលរួមវិនិយោគពីវិស័យឯកជនក្នុងគ្រប់ខ្សែច្រវាក់តម្លៃកសិកម្មតាមអភិក្រមភាពជាដៃគូរវាងរដ្ឋ ឯកជន និងសហគមន៍កសិកម្ម។

➤ **ការស្រាវជ្រាវនិងការអភិវឌ្ឍកៅស៊ូធម្មជាតិប្រកបដោយនិរន្តរភាព**

– ជំរុញការអនុវត្តលក្ខខណ្ឌការងារនៅតាមចម្ការកៅស៊ូកសិឧស្សាហកម្មឱ្យមានភាពល្អប្រសើរឡើង (ប្រាក់រង្វាន់លើកទឹកចិត្ត របបសន្តិសុខសង្គម ប្រាក់ចូលនិវត្តន៍ សុវត្ថិភាពការងារ ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត...)

- បន្តយកចិត្តទុកដាក់លើការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រស្តីពីពូជ (ទិន្នផលល្អ ធន់នឹងអាកាសធាតុ ជំងឺ) ការដាំដុះ ថែទាំកូនកៅស៊ូ ការគ្រប់គ្រងសមាសភាពចម្រៃ ការយកផល និងការកែច្នៃ
- បន្តយកចិត្តទុកដាក់លើការសិក្សាស្រាវជ្រាវ និងកសាងលិខិតគតិយុត្តពាក់ព័ន្ធនានា និងគោលនយោបាយជាតិ ស្តីពីការអភិវឌ្ឍឧស្សាហកម្មកៅស៊ូ
- សិក្សារៀបចំបង្កើតមណ្ឌលកែច្នៃនិងមណ្ឌលទីផ្សារ
- បន្តជំរុញការអនុវត្តបែបបទវិញ្ញាបនបត្របញ្ជាក់គុណភាពយថាប្រភេទកៅស៊ូកម្ពុជា (CSR)
- សម្របសម្រួលឱ្យមានការប្រើប្រាស់ផលិតផលកៅស៊ូធម្មជាតិក្នុងស្រុក តាមយៈការបង្កើតរោងចក្រកែច្នៃផលិតផលសម្រេចពីកៅស៊ូ
- បន្តកិច្ចសហប្រតិបត្តិការ ជាមួយដៃគូរអភិវឌ្ឍន៍ អង្គការជាតិនិងអន្តរជាតិ ក្នុងការស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូធម្មជាតិ

➢ **លើកកម្ពស់ការអភិវឌ្ឍកសិ-ឧស្សាហកម្ម**

- អនុវត្តយន្តការផលិតកម្មកសិកម្មតាមកិច្ចសន្យា ដោយភ្ជាប់ក្រុមផលិតករ សហគមន៍កសិកម្ម ជាមួយក្រុមអ្នកប្រមូលទិញ ឬក្រុមហ៊ុនឯកជនដែលប្រមូលទិញផលិតផលកសិកម្មសម្រាប់ការកែច្នៃ និងការនាំចេញ
- សម្របសម្រួលក្នុងការបង្កើតសួនកសិ-ឧស្សាហកម្មកែច្នៃ និងនាំចេញ ដែលគ្រប់គ្រង និងប្រតិបត្តិដោយផ្នែកឯកជន
- រៀបចំដំណើរការមន្ទីរពិសោធន៍ និងពង្រឹងសមត្ថភាពមន្ត្រីជំនាញសម្រាប់វិភាគគុណភាព និងសុវត្ថិភាពផលិតផលកសិកម្ម សហការជាមួយជំនាញពាក់ព័ន្ធតាមភារកិច្ច ឱ្យមានលក្ខណៈប្រទាក់ក្រឡាគ្នា ដើម្បីជួយសម្រួលដល់ការអនុវត្តប្រព័ន្ធតាមដាននិងត្រួតពិនិត្យគុណភាពឱ្យកាន់តែមានប្រសិទ្ធភាព
- រៀបចំ និងអនុវត្តបទដ្ឋានគតិយុត្ត សហការជាមួយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធនានា ដើម្បីទប់ស្កាត់លើការប្រើប្រាស់សារធាតុគីមីដែលហាមឃាត់ ដោយត្រូវត្រួតពិនិត្យ ដើម្បីធានាសុខុមាលភាព សាធារណៈ
- បង្កើនការសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាលអំពីបច្ចេកទេសសម្រាប់ជំរុញការអភិវឌ្ឍកសិ-ឧស្សាហកម្ម។

➢ **ការស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កសិកម្មប្រកបដោយចីរភាព**

- បំផុសគំនិតច្នៃប្រឌិតថ្មីៗ សម្រាប់បង្កើនសន្ទុះទំនើបភាវូបនីយកម្មកសិកម្មឱ្យកាន់តែមានឧត្តមភាពប្រកួតប្រជែងខ្ពស់ ដោយយកចិត្តទុកដាក់លើការស្រាវជ្រាវ អភិវឌ្ឍន៍ ផ្សព្វផ្សាយ និងប្រើប្រាស់របកគំហើញថ្មីៗ ដូចជា ប្រភេទពូជដំណាំថ្មីៗ បច្ចេកទេសផលិត កែច្នៃ បច្ចេកវិទ្យាកសិកម្មធន់នឹងការប្រែប្រួលអាកាសធាតុ ការប្រើប្រាស់ធាតុចូលកសិកម្មសមស្រប ប្រកបដោយគុណភាព សុវត្ថិភាព និងប្រសិទ្ធភាពខ្ពស់
- កៀរគរអ្នកវិនិយោគលើវិស័យកសិកម្មឱ្យមានការចូលរួមក្នុងការងារស្រាវជ្រាវ និងអភិវឌ្ឍន៍លើការពង្រឹងសមត្ថភាពស្រាវជ្រាវកសិកម្មសម្រាប់ដំណាំអាទិភាព និងការអនុវត្តកម្មវិធីស្រាវជ្រាវសម្រាប់អភិវឌ្ឍន៍ តាមរយៈភាពជាដៃគូរវាងរដ្ឋាភិបាល វិស័យឯកជន និងអ្នកផលិត។

➢ **ការកសាង និងអនុវត្តគម្រោងពាក់ព័ន្ធគោលនយោបាយអន្តរវិស័យ**

- រៀបចំកសាង អនុវត្ត តាមដាននិងវាយតម្លៃគម្រោង ផែនការសកម្មភាព ដែលមានចែងក្នុងឯកសារ យុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិផ្សេងទៀតទាក់ទងដល់ផ្នែកជំនាញ ពិសេសគម្រោងឬផែនការ សកម្មភាពក្នុងយុទ្ធសាស្ត្រកាត់បន្ថយផលប៉ះពាល់ និងបន្សាំជាមួយនឹងការប្រែប្រួលអាកាសធាតុ កម្មវិធីសកម្មភាពជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងការធ្លាក់ចុះនៃគុណភាពដី ការបញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម គោលនយោបាយជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជា។ល។

កម្មវិធីនេះ ត្រូវបានគាំទ្រដោយអនុកម្មវិធីចំនួន០៩ និងអនុវត្តដោយ (១)អគ្គនាយកដ្ឋានកសិកម្ម (២) អគ្គនាយកដ្ឋានកៅស៊ូ (៣)នាយកដ្ឋានកសិឧស្សាហកម្ម (៤)វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (៥)វិទ្យាស្ថានស្រាវជ្រាវដំណាំកៅស៊ូកម្ពុជា និង(៦)មន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ រាជធានី-ខេត្ត។

### កម្មវិធីទី-២៖ ការលើកកម្ពស់ផលិតកម្មសត្វ និងសុខភាពសត្វ

<u>គោលបំណងកម្មវិធីទី-២៖</u> "ការការជំរុញផលិតកម្មសត្វក្នុងអត្រាកំណើន៣%ក្នុងមួយឆ្នាំ តាមរយៈការគ្រប់គ្រង និងការអភិវឌ្ឍការចិញ្ចឹមសត្វ កាត់បន្ថយហានីភ័យជំងឺឆ្លងសត្វ និងពង្រឹងការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលសត្វ"។

ដើម្បីសម្រេចគោលបំណងនេះត្រូវអនុវត្តតាមគោលដៅយុទ្ធសាស្ត្រចំនួន៣សំខាន់ៗគឺ៖ (១)បង្កើនផលិតផលសាច់ឱ្យកើនដល់២៩៤៣ាន់តោននៅឆ្នាំ២០២៥ (២)បង្កើនអត្រា(%)នៃការចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្មឱ្យកើនដល់៣២%នៅឆ្នាំ២០២៥ និង(៣) កាត់បន្ថយអត្រាជំងឺឆ្លងសត្វឱ្យនៅក្រោម៥%។

អនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រដល់ការសម្រេចបាននូវគោលបំណងគោលនយោបាយដែលបានដាក់ចេញ។ អនុវិស័យនេះ មានយុទ្ធសាស្ត្រអាទិភាពសំខាន់ៗទាក់ទងទៅនឹងការបង្កើនផលិតកម្មសត្វ លើកកម្ពស់សុខភាពសត្វ ការពង្រីកទីផ្សារ សុវត្ថិភាពចំណីអាហារ សុខភាពសាធារណៈ សន្តិសុខស្បៀង និងតួនាទីរបស់វិស័យឯកជន ក្រុមកសិករ/សហគមន៍កសិកម្ម ភ្នាក់ងារសុខភាពសត្វភូមិ និងបញ្ហាអន្តរវិស័យមួយចំនួនដែលពាក់ព័ន្ធដល់ផ្នែកសុខភាពសត្វ និងផលិតកម្មសត្វ។

ដើម្បីសម្រេចបាននូវគោលដៅសូចនាករនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងជំរុញវិធានការគោលនយោបាយសំខាន់ៗមួយចំនួន ដូចខាងក្រោម៖

- **ពង្រឹងផលិតកម្មសត្វ រួមទាំងការលើកកម្ពស់ការគ្រប់គ្រង និងបង្កាត់ពូជសត្វ**
  - រៀបចំផែនការផលតកម្មប្រកបដោយប្រសិទ្ធភាពសេដ្ឋកិច្ចសម្រាប់ផ្គត់ផ្គង់ក្នុងស្រុក
  - ជំរុញការចរចារធ្វើពាណិជ្ជកម្មសត្វនិងផលិតផលសត្វ និងជំរុញផលិតកម្មជ្រូកតាមកិច្ចសន្យា
  - ជំរុញការចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្មឱ្យមានការកើនឡើងក្នុងចំណោមកសិករ សហគមន៍ និងអ្នកចិញ្ចឹមសត្វផ្សេងទៀត
  - អនុវត្តនិងផ្សព្វផ្សាយពីការអនុវត្តន៍ការចិញ្ចឹមសត្វល្អ (GAHP) ដល់អ្នកពាក់ព័ន្ធក្នុងផលិតកម្មសត្វ
  - តាមដាននិងត្រួតពិនិត្យគុណភាពចំណីសត្វដើម្បីធានានូវប្រសិទ្ធភាពនៃការចិញ្ចឹមសត្វ
  - កំណត់អត្តសញ្ញាណចុះបញ្ជី គ្រប់គ្រងទិន្នន័យសត្វ និងកសិដ្ឋានចិញ្ចឹមសត្វឱ្យបានល្អប្រសើរ
  - ជំរុញការប្រើប្រាស់បច្ចេកវិទ្យានៅក្នុងផលិតកម្មសត្វនិងការបង្កាត់ពូជសត្វតាមរយៈការបង្កើត កសិដ្ឋានបង្ហាញ និងបណ្តុះបណ្តាលបច្ចេកទេសជំនាញ
  - ជំរុញឱ្យមានការគ្រប់គ្រងកាកសំណល់ក្នុងកសិដ្ឋានចិញ្ចឹមសត្វ ការដាំដុះចំណីសត្វ សត្តឃាតដ្ឋាន និងរោងចក្រកែច្នៃ។
- **ពង្រឹងសុខភាពសត្វនិងសុខភាពសាធារណៈបសុព្យាបាល**
  - ការគ្រប់គ្រងជំងឺឆ្លងសត្វ (ជំងឺប៉េស្តជ្រូកអាហ្វ្រិក)
  - ទប់ស្កាត់ការនាំចូលផលិតផលសាច់បង្កក និងការអនុវត្តការទប់ស្កាត់ការនាំចូលសត្វ និងផលិតផលសត្វក្រៅផ្លូវការពីបរទេសចូលមកកម្ពុជា
  - ពង្រឹងការតាមដានជំងឺ ការចុះស្រាវជ្រាវនៅមូលដ្ឋាន ការធ្វើរោគវិនិច្ឆ័យនៅមន្ទីពិសោធន៍ ការបង្ការនិងទប់ស្កាត់ជំងឺសត្វ និងជំងឺឆ្លងពីសត្វទៅមនុស្ស

- កាត់បន្ថយនិងគ្រប់គ្រងជំងឺសត្វតាមរយៈការពង្រឹងការតាមដាន និងអន្តរាគមន៍បង្ការ ទប់ស្កាត់ ជំងឺឆ្លងសត្វ ពង្រឹងការត្រួតពិនិត្យចរាចរណ៍សត្វ និងផលិតផលសត្វខុសច្បាប់ ជ្រើសរើស និងបំពាក់បំប៉ន់បន្ថែមភ្នាក់សុខភាពសត្វភូមិ
- ផ្តល់ការគាំទ្រ ទាំងបច្ចេកទេសនិងហិរញ្ញវត្ថុដល់ភ្នាក់ងារសុខភាពសត្វភូមិ (VAHWs) ដើម្បីចូលរួមក្នុងសកម្មភាពបង្កើនផលិតភាពសត្វនៅតាមមូលដ្ឋាន
- គ្រប់គ្រងសត្វនិងផលិតផលមានដើមកំណើតពីសត្វ រួមទាំងការត្រួតពិនិត្យដ៏មានប្រសិទ្ធភាពនៅតាមស្ថានីយចក្តាឡីស័ក និងកន្លែងប្រមូលផ្តុំសត្វ
- លើកកម្ពស់ការអនុវត្តជីវសុវត្ថិភាពនៅក្នុងខ្សែច្រវាក់តម្លៃ។

➢ **លើកកម្ពស់ការផ្សព្វផ្សាយច្បាប់ ពង្រឹងការអនុវត្តច្បាប់ និងគោលនយោបាយនានា**

- រៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើតបសុពេទ្យ
- ជំរុញការរៀបចំការកសាង និងកែសម្រួលលិខិតបទដ្ឋានគតិយុត្តនានាក្រោមច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ ពង្រឹងការអនុវត្ត បង្កើនការយល់ដឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីពង្រឹងការគ្រប់គ្រងផ្នែកសុខភាពសត្វនិងផលិតកម្មសត្វឱ្យមានប្រសិទ្ធភាពខ្ពស់
- ជំរុញនីតិវិធីក្នុងការចុះបញ្ជី វត្ថុធាតុដើម សារធាតុបន្ថែម លាយផ្សំ និងកន្លែងតាំងលក់ផលិតផល ចំណីសត្វ បសុឱសថ និងផ្តល់លិខិតអនុញ្ញាតដល់កសិដ្ឋាន សត្តឃាតដ្ឋាន កន្លែងច្នៃ មន្ទីរពិសោធន៍ ស្ថាប័នសិក្សាស្រាវជ្រាវ និងវ៉ាក់សាំងសត្វសេវាបសុព្យាបាល
- រៀបចំនីតិវិធីក្នុងការផ្តល់វិញ្ញាបនប័ត្រដល់អ្នកផ្តល់សេវាបសុពេទ្យនិងផ្តល់ការគាំទ្រដល់ការបង្កើតគណៈបសុពេទ្យ (Veterinary Statutory Body-VSB)។

➢ **ជំរុញការស្រាវជ្រាវនិងអភិវឌ្ឍន៍សុខភាពសត្វ និងផលិតកម្មសត្វ**

- អនុវត្តនិងគ្រប់គ្រងការងារស្រាវជ្រាវសុខភាពសត្វនិងផលិតកម្មសត្វ
- ពង្រឹងសមត្ថភាពស្រាវជ្រាវសុខភាពសត្វនិងផលិតកម្មសត្វ
- សិក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍សេនេទិកពូជសត្វ កែច្នៃទឹកមេជីវិតបង្កកគោ ការបង្កាត់ពូជសត្វ ដោយសិប្បនិម្មិត
- ពង្រឹងសមត្ថភាពនិងប្រសិទ្ធភាពខ្ពស់ក្នុងការធ្វើរោគវិនិច្ឆ័យជំងឺសត្វនិងការតាមដានជំងឺសត្វ
- សិក្សាស្រាវជ្រាវគុណភាពនិងសុវត្ថិភាពបសុឱសថ ចំណីសត្វ សាច់សត្វ និងផលិតផលសត្វ
- សិក្សាស្រាវជ្រាវភាពស៊ាំទៅនឹងឱសថប្រឆាំងមេរោគ ផលិតផលបសុឱសថ និងវ៉ាក់សាំង។

➢ **បង្កើនការអភិវឌ្ឍសមត្ថភាពស្ថាប័ននិងធនធានមនុស្ស**

- ពង្រឹងសមត្ថភាពធនធានមនុស្សផ្នែកសុខភាពសត្វនិងផលិតកម្មសត្វ ខ្សែច្រវាក់តម្លៃ និងការគ្រប់គ្រងពាណិជ្ជកម្ម
- គាំទ្រនិងពង្រឹងការអប់រំក្នុងប្រព័ន្ធវេជ្ជសាស្ត្របសុព្យាបាលនិងវិទ្យាសាស្ត្រសត្វ
- ពង្រឹងសមត្ថភាពគ្រប់គ្រងរបស់មន្ត្រីសុខភាពសត្វនិងផលិតកម្មសត្វ និងមន្ត្រីការិយាល័យផលិតកម្មនិងបសុព្យាបាលរាជធានី ខេត្ត។

➢ **លើកកម្ពស់ភាពជាដៃគូរវាងវិស័យសាធារណៈនិងឯកជនក្នុងផលិតកម្មសត្វ**

- គាំទ្រដល់គំនិតផ្តួចផ្តើមនិងពង្រឹងការចែករំលែកព័ត៌មានរបស់វិស័យឯកជនក្នុងអនុវិស័យសុខភាពសត្វនិងផលិតកម្មសត្វ
- សម្របសម្រួលការពិគ្រោះយោបល់និងកិច្ចសហប្រតិបត្តិការជាមួយវិស័យឯកជន អង្គការសង្គមស៊ីវិល និងសហគមន៍ចិញ្ចឹមសត្វ

- **ពង្រឹងកិច្ចសហប្រតិបត្តិការទាំងផ្នែកសេដ្ឋកិច្ច បច្ចេកទេសកម្រិតជាតិ និងអន្តរជាតិលើអនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វ**
  - រៀបចំនិងចូលរួមនៅក្នុងសន្និសីទអំពីសុខភាពសត្វនិងផលិតកម្មសត្វនៅថ្នាក់ជាតិ អាស៊ាន និងអន្តរជាតិ
  - បង្កើតកិច្ចសហប្រតិបត្តិការភាពជាដៃគូរខាងសេដ្ឋកិច្ចនិងបច្ចេកទេសនៅថ្នាក់ជាតិ អាស៊ាន អន្តរជាតិ ពង្រឹងទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍ អង្គការស្ថាប័នទ្វេរភាគី ពហុភាគី ជុំវិញបញ្ហាពាក់ព័ន្ធអនុវិស័យសុខភាពសត្វនិងផលិតកម្មសត្វ
  - រៀបចំកសាងនិងអនុវត្តគម្រោងផែនការសកម្មភាពទាំងអស់ ដែលមានគ្រោងក្នុងឯកសារយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិផ្សេងៗ ទាក់ទងដល់ផ្នែកជំនាញ ពិសេសផែនការសកម្មភាពក្នុងយុទ្ធសាស្ត្រកាត់បន្ថយផលប៉ះពាល់ និងបន្សាំជាមួយការប្រែប្រួលអាកាសធាតុ ការបញ្ជ្រាបយេនឌ័រក្នុងអនុវិស័យសុខភាពសត្វនិងផលិតកម្មសត្វ គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជា។

កម្មវិធីនេះ ត្រូវបានគាំទ្រដោយអនុកម្មវិធីចំនួន៤ និងអនុវត្តដោយអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្ត។

## កម្មវិធីទី-៣៖ ការគ្រប់គ្រងធនធានជលផល និងការអភិវឌ្ឍវារីវប្បកម្ម

<u>**គោលបំណងកម្មវិធីទី៣៖**</u> “បង្កើនការគ្រប់គ្រងធនធានជលផលឱ្យមានប្រសិទ្ធភាពនិងនិរន្តរភាព ដោយពង្រឹង ការអនុវត្តច្បាប់ស្តីពីជលផល រក្សាការចាប់ផលនេសាទពីធម្មជាតិក្នុងរង្វង់៦០០ពាន់តោនក្នុងមួយឆ្នាំ បង្កើនផលវារីវប្បកម្ម២០%ក្នុងមួយឆ្នាំ និងធ្វើឱ្យសហគមន៍នេសាទមានកម្រិតជីវភាពកាន់តែប្រសើរឡើង”។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានកំណត់យុទ្ធសាស្ត្រសំខាន់សម្រាប់ការអនុវត្តកម្មវិធីទី៣ រួមមាន៖

- **ពង្រឹងការគ្រប់គ្រង និងអភិរក្សធនធានជលផល**
  - ពង្រឹងការគ្រប់គ្រងនិងអភិវឌ្ឍន៍សហគមន៍នេសាទ៖ បន្តពង្រឹងសហគមន៍នេសាទឱ្យក្លាយជា សហគមន៍មានភាពម្ចាស់ការ ដំណើរការល្អ រឹងមាំ និងសកម្មក្នុងការគ្រប់គ្រង និងអភិរក្សធនធានជលផលឱ្យមាននិរន្តរភាព ពិសេសជំរុញនិងគាំទ្រផ្តល់ឱកាសឱ្យសហគមន៍នេសាទអាចរកប្រាក់ចំណូលសម្រាប់ ដំណើរការសហគមន៍ និងអភិរក្សធនធានជលផលប្រកបដោយប្រសិទ្ធភាព ដោយសហការជាមួយរដ្ឋបាល ពាក់ព័ន្ធថ្នាក់ក្រោមជាតិពាក់ព័ន្ធ ដើម្បីប្រែក្លាយជា “សហគមន៍នេសាទគ្មានបទល្មើសជលផល”
  - ការគ្រប់គ្រងដែននេសាទ៖ បង្កើនកិច្ចសហការជាមួយអាជ្ញាធរដែនដីគ្រប់ថ្នាក់ ចុះទប់ស្កាត់ការទន្ទ្រានឈូសឆាយបំផ្លិចបំផ្លាញយកដីព្រៃលិចទឹកនិងព្រៃកោងកាងនៅតាមមូលដ្ឋាន ជាពិសេសយកចិត្តទុកដាក់និងទប់ស្កាត់រាល់ឧបករណ៍នេសាទដែលបំផ្លិចបំផ្លាញធ្ងន់ធ្ងរដល់ធនធានធម្មជាតិនិងកែលម្អដែននេសាទ។ រៀបចំផែនទីកំណត់ព្រំប្រទល់ដែននេសាទ តំបន់អនុញ្ញាតឱ្យដាំដុះវារីរុក្ខជាតិ តំបន់នេសាទ និងការចេញលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មនេសាទ និងការប្រើប្រាស់ទូក កាណូតនាវានេសាទ ព្រមទាំងតាមដាន និងវាយតម្លៃសភាពការណ៍អាជីវកម្មនេសាទ និងទប់ស្កាត់រាល់សកម្មភាពបទល្មើសជលផលគ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត។
- **ការពារនិងអភិរក្សធនធានជលផល៖**
  - ត្រូវបន្តគ្រប់គ្រងកន្លែងអភិរក្សធនធានជលផលទាំងអស់ ទាំងក្នុងដែននេសាទសាធារណៈ និងក្នុងកន្លែងនេសាទសហគមន៍នេសាទឱ្យខាងតែបានព្រោះដែនអភិរក្សទាំងនេះជាជម្រកត្រីមេពូជដ៏សំខាន់ សម្រាប់ថែរក្សាត្រីមេពូជឱ្យបានគង់វង្ស និងធានានិរន្តរភាពផលនេសាទ ដែលមានសារៈសំខាន់ដល់និរន្តរភាពនៃធនធានជលផល។
- **ការអភិវឌ្ឍវារីវប្បកម្មទឹកសាបនិងសមុទ្រ**

- ជំរុញការអភិវឌ្ឍវារីវប្បកម្មក្នុងកំណើន២០%/ឆ្នាំ ដើម្បីបំពេញកំណើនតម្រូវការសាច់ត្រីជាអាហារ និងកាត់បន្ថយការនេសាទហួសកម្រិតនោះ ការអភិវឌ្ឍវារីវប្បកម្មត្រូវតែជំរុញឱ្យបានខ្លាំងក្លា ទាំងខ្នាតតូច មធ្យម និងធំ ដោយធានាឱ្យបានទាំងកំណើនបរិមាណ និងទាំងគុណភាព សុវត្ថិភាពចំណីអាហារ ដោយត្រូវជំរុញការអនុវត្ត **ផែនការយុទ្ធសាស្ត្រជាតិអភិវឌ្ឍន៍វារីវប្បកម្មឆ្នាំ២០១៦-២០៣០។** ពិសេស វិធានការពង្រឹងសមត្ថភាពក្នុងការផលិតនូវកូនត្រីពូជក្នុងស្រុក សម្រាប់ជំរុញការអភិវឌ្ឍសេដ្ឋកិច្ច ដើម្បី ឆ្លើយតបនឹងតាមតម្រូវការរបស់អ្នកចិញ្ចឹម ជាពិសេសប្រភេទត្រីមានតម្លៃសេដ្ឋកិច្ចខ្ពស់ ព្រមទាំងបន្តផ្តល់នូវបច្ចេកទេសថ្មីៗ និងបច្ចេកទេសសម្រាប់ជម្រុញការបង្កាត់ពូជត្រី និងទីកន្លែងបង្កាត់ភ្ញាស់ពូជត្រី និងអនុវត្តគោលការណ៍អនុវត្តវារីវប្បកម្មល្អ។
- ជំរុញលើកទឹកចិត្តដល់វិស័យឯកជនទាំងក្នុងនិងក្រៅប្រទេស ឱ្យធ្វើការវិនិយោគលើការអភិវឌ្ឍវារីវប្បកម្ម ពិសេសការចិញ្ចឹមត្រី និងបង្កង រួមទាំងការកែច្នៃផលិតផលជលផលប្រកបដោយគុណភាព និងសុវត្ថិភាព
- កំណត់ឱ្យបានជាក់លាក់ពីតំបន់ដែលមានសក្តានុពល សម្រាប់វិនិយោគវារីវប្បកម្មពីសំណាក់អ្នកវិនិយោគ ក្នុង និងក្រៅប្រទេស ជាពិសេសចំពោះការចិញ្ចឹមត្រីឆ្តោរនិងត្រីរ៉ស់ ត្រូវផ្តល់បច្ចេកទេសបង្កាត់ពូជត្រីនិងផ្តល់នូវបច្ចេកទេសគ្រប់គ្រង និងតាមដានឱ្យមានប្រសិទ្ធភាព ដើម្បីចៀសវាងការប្រើចំណីដែល បានមកពីការប្រើឧបករណ៍នេសាទខុសច្បាប់ដូចជាស្នៃមុងចាប់កូនត្រីធ្វើជាចំណីជាដើម
- បង្កើតសមាគមន៍វារីវប្បកម្ម និងជំរុញឱ្យមានការធ្វើផលិតកម្មតាមកិច្ចសន្យា ជាមួយអ្នកប្រមូលទិញ ឬក្រុមហ៊ុនប្រមូលទិញសម្រាប់នាំចេញ
- បន្តជំរុញការងារស្រាវជ្រាវ ការអប់រំ និងអភិវឌ្ឍន៍បច្ចេកទេសវារីវប្បកម្ម និងបង្កើនការផ្សព្វផ្សាយបច្ចេកទេសបង្កាត់កូនត្រីពូជនិងចិញ្ចឹមដល់កសិករ ប្រជានេសាទ និងសហគមន៍នេសាទ
- ស្តារ និងលើកកំពស់សមត្ថភាពមន្ទីរពិសោធន៍ខាងផ្នែកជំងឺ សេនេទិកទិក និងសារធាតុចិញ្ចឹមនៅតាមវិទ្យាស្ថាន និងមជ្ឈមណ្ឌលដើម្បីគាំទ្រ និងផ្តល់សេវាជូនដល់វារីវប្បករចិញ្ចឹម និងកសិករផលិតកូនត្រីពូជបានទាន់ពេលវេលា
- ស្តារ និងអភិវឌ្ឍន៍ម៉ាស៊ីនផលិតចំណីត្រីនៅតាមវិទ្យាស្ថាន និងមជ្ឈមណ្ឌលដែលមានស្រាប់ និងជំរុញលើកទឹកចិត្តដល់វិស័យឯកជនទាំងក្នុងនិងក្រៅប្រទេសឱ្យវិនិយោគលើការផលិតចំណីត្រីដើម្បីកាត់បន្ថយការនាំចូលទាំងស្រុងពីខាងក្រៅ
- ជំរុញលើកទឹកចិត្តដល់វិស័យឯកជនក្នុង និងក្រៅប្រទេសផលិតឧបករណ៍សម្ភារវារីវប្បកម្មដើម្បីគាំទ្រនិងអភិវឌ្ឍន៍បច្ចេកវិទ្យាវារីវប្បកម្មឱ្យបានកាន់តែទំនើប និងល្អប្រសើរឆ្លើយតបទៅនឹងផែនការអភិវឌ្ឍវិស័យវារីវប្បកម្ម។

➢ **ការគ្រប់គ្រង និងអភិវឌ្ឍន៍ខ្សែច្រវាក់តម្លៃជលផល**

- អភិវឌ្ឍបច្ចេកវិទ្យាកែច្នៃ និងលើកកម្ពស់អាហារូបត្ថម្ភ រៀបចំនិងសាកល្បងគោលការណ៍ណែនាំបច្ចេកទេសកែច្នៃតាមស្តង់ដារ និងជំរុញការអនុវត្តបច្ចេកទេសកែច្នៃប្រសើរឡើង ដើម្បីបង្កើនតម្លៃបន្ថែម
- ពង្រឹងការត្រួតពិនិត្យ និងវិភាគគុណភាពផល ផលិតផលជលផល ដើម្បីការពារសុខភាពសាធារណៈ និងជំរុញការនាំចេញ
- លើកកម្ពស់ការផលិតឆ្លើយតបតាមស្តង់ដារគុណភាព និងជំរុញទីផ្សារក្នុងស្រុកនិងក្រៅស្រុក ជាពិសេសតាមរយៈការពង្រឹងសមត្ថភាពប្រព័ន្ធគ្រប់គ្រងគុណភាព និងសុវត្ថិភាព ដោយផ្តល់ការបណ្តុះបណ្តាល និងផ្សព្វផ្សាយគោលការណ៍ណែនាំបច្ចេកទេសផ្សេងៗដែលពាក់ព័ន្ធ។

➢ **ការស្រាវជ្រាវ និងអភិវឌ្ឍន៍ធនធានជលផល**

- ស្រាវជ្រាវវិទ្យាសាស្ត្រនិងបច្ចេកទេសធនធានជលផលទឹកសាបនិងសមុទ្រ

- បង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យសម្រាប់ផ្សព្វផ្សាយលទ្ធផលនៃការស្រាវជ្រាវធនធានជលផល
- ជំរុញ និងពង្រឹងកិច្ចសហការសិក្សាស្រាវជ្រាវធនធានជលផលទឹកសាប និងសមុទ្រ ជាមួយវិទ្យាស្ថានស្រាវជ្រាវ សាកលវិទ្យាល័យ នៅថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ និងស្ថាប័នពាក់ព័ន្ធដទៃទៀត
- ពង្រឹងសមត្ថភាពមន្ត្រីស្រាវជ្រាវដែលធ្វើការងារស្រាវជ្រាវវិទ្យាស្ត្រជលផលទឹកសាប និងសមុទ្រ។

➢ **ពង្រឹងសមត្ថភាពមន្ត្រីជលផល ការអនុវត្តច្បាប់ស្តីពីជលផល និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធវិស័យជលផល**

- អនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តក្នុងវិស័យជលផល និងបន្តពិនិត្យកែសម្រួលច្បាប់ លិខិតបទដ្ឋាននានាពាក់ព័ន្ធវិស័យជលផលឱ្យទាន់សភាពការណ៍ជាក់ស្តែង
- បង្កើនកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរដែនដីគ្រប់ថ្នាក់ ដើម្បីបង្ក្រាបបទល្មើសជលផលនៅក្នុង មូលដ្ឋាន ជាពិសេសយកចិត្តទុកដាក់ទប់ស្កាត់រាល់ឧបករណ៍នេសាទ ដែលបំផ្លិចបំផ្លាញធ្ងន់ធ្ងរដល់ធនធានធម្មជាតិ និងទប់ស្កាត់នូវរាល់សកម្មភាពបទល្មើសជលផល ការទន្ទ្រានយកដីព្រៃលិចទឹក ព្រៃកោងកាង និងដីដែលស្ថិតនៅក្នុងកន្លែងនេសាទសហគមន៍
- អនុវត្តផែនការសកម្មភាពជាតិស្តីពីការប្រយុទ្ធប្រឆាំង និងទប់ស្កាត់បទល្មើសនេសាទខុសច្បាប់គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត (NPOA IUU) Fishing-National Plan of Action Illegal Fishing Unreported and Unregulated) និងផែនការជាតិត្រួតពិនិត្យមោងអធិការកិច្ចសមុទ្រ និងផែនការជាតិសម្រាប់ការគ្រប់គ្រងនិងអធិការកិច្ចឱ្យស្របទៅតាមច្បាប់ជាតិ និងសន្ធិសញ្ញាអន្តរជាតិ
- ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអង្គការជាតិ និងអន្តរជាតិនានា ដើម្បីជួយគាំទ្រដល់ការអភិវឌ្ឍនិងគ្រប់គ្រងវិស័យជលផលនៅកម្ពុជាឱ្យបានខ្លាំងក្លាថែមទៀត សំដៅធានានិរន្តភាពធនធានជលផល កាត់បន្ថយភាពក្រីក្រ ធានាសន្តិសុខ និងសុវត្ថិភាពស្បៀង ព្រមទាំងចូលរួមសម្រេចឱ្យបាន "គោលដៅ អភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០"
- រៀបចំកសាង និងអនុវត្តផែនការសកម្មភាពដែលមានគ្រោងក្នុងឯកសារយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិផ្សេងទៀតទាក់ទងនឹងជលផល ពិសេសគម្រោងឬផែនការសកម្មភាពក្នុងយុទ្ធសាស្ត្រកាត់បន្ថយ ផលប៉ះពាល់ និងបន្សាំជាមួយនឹងការប្រែប្រួលអាកាសធាតុ ការបញ្ជ្រាបយេនឌ័រក្នុងអនុវិស័យជលផល និង ក្នុងគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជា។ល។
- អភិវឌ្ឍធនធានមនុស្សតាមរយៈការបណ្តុះបណ្តាលបច្ចេកទេសជំនាញ និងបទដ្ឋានគតិយុត្តិដល់មន្ត្រីជលផល និងអ្នកពាក់ព័ន្ធ

កម្មវិធីនេះ ត្រូវបានគាំទ្រដោយអនុកម្មវិធីចំនួន៤ និងអនុវត្តដោយរដ្ឋបាលជលផល និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានីខេត្ត។

## កម្មវិធីទី-៤៖ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានព្រៃឈើនិងសត្វព្រៃ

**<u>គោលបំណងកម្មវិធីទី៤៖</u>** "ពង្រីកការស្តារ ដាំដុះឈើឡើងវិញជាលក្ខណៈពាណិជ្ជកម្ម និងលើកកម្ពស់ជីវភាពសហគមន៍ព្រៃឈើ និងអភិវឌ្ឍធនធានព្រៃឈើ និងសត្វព្រៃឱ្យមាននិរន្តភាព"។

ព្រៃឈើជាប្រភពធនធានធម្មជាតិដ៏មានតម្លៃ ចូលរួមលើកកម្ពស់លើផ្នែកសេដ្ឋកិច្ច បរិស្ថាន ទេសចរណ៍ ការសិក្សាស្រាវជ្រាវប្រព័ន្ធការពារទីជម្រាល ប្រព័ន្ធការពារជីវចម្រុះ និងផ្តល់ជម្រកសម្រាប់ស្ថិរភាពនៃជីវិតរស់នៅរបស់មនុស្ស និងសត្វគ្រប់ប្រភេទ។ ការខិតខំប្រឹងប្រែងដើម្បីរួបរួមគ្នាទប់ស្កាត់គ្រោះមហន្តរាយនៃការបាត់បង់ធនធានព្រៃឈើ គឺជាកត្តាចាំបាច់បំផុត ពិសេសការពង្រឹងស្មារតីម្ចាស់ការទទួលខុសត្រូវលើកិច្ចការនេះ។ ការស្តារព្រៃឈើគឺ ជាគោលដៅសំខាន់ក្នុងការជំរុញឱ្យមានគម្របព្រៃឈើបៃតង ក៏ដូចជាផ្តល់នូវការរីកចម្រើនសេដ្ឋកិច្ចសម្រាប់ប្រទេសជាតិ និងឆ្លើយតបទៅនឹងតម្រូវការប្រើប្រាស់ឈើក្នុងស្រុកដែលកើតមានឡើងកាន់តែខ្លាំង។

ដើម្បីសម្រេចបាននូវគោលដៅសូចនាករនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងបន្តគ្រប់គ្រងធនធានព្រៃឈើ និងសត្វព្រៃប្រកបដោយនិរន្តរភាព ចូលរួមជំរុញការថែរក្សាគម្របព្រៃឈើឱ្យបានល្អប្រសើរព្រមទាំងលើកកម្ពស់ជីវភាព និងការចូលរួមរបស់សហគមន៍ព្រៃឈើ ព្រមទាំងជំរុញការស្តារព្រៃឈើឡើងវិញ និងបន្តអនុវត្តនូវវិធានការចាំបាច់នានា ដើម្បីចូលរួមចំណែកធ្វើឱ្យប្រព័ន្ធអេកូឡូស៊ីមានចីរភាព។ វិធានការជាយុទ្ធសាស្ត្រដែលត្រូវអនុវត្តរួមមាន៖

- **ការពង្រឹងការគ្រប់គ្រង និងសេវាគាំទ្រ**
  - សម្របសម្រួលរៀបចំធ្វើបច្ចុប្បន្នភាពកម្មវិធីព្រៃឈើជាតិ ការធ្វើវិសោធនកម្មច្បាប់ស្តីពីព្រៃឈើ និងលិខិតបទដ្ឋានគតិយុទ្ធផ្សេងៗ ឆ្លើយតបនឹងស្ថានភាពក្នុងបរិបទកំណែទម្រង់បច្ចុប្បន្ន សំដៅធានាបានស្ថិរភាពរឹងមាំលើការអភិវឌ្ឍវិស័យព្រៃឈើ
  - រៀបចំកសាងនិងជំរុញការអនុវត្តគម្រោងផែនការសកម្មភាពទាំងអស់ ដែលមានគ្រោងក្នុងឯកសារ យុទ្ធសាស្ត្រ និងផែនការសកម្មផ្សេងៗទៀតដែលទាក់ទងដល់ផ្នែកព្រៃឈើ ការលើកកម្ពស់សមត្ថភាពធនធានមនុស្ស ការគ្រប់គ្រងថវិកា (ចំណូល និងចំណាយ) និងសេវាគាំទ្រ។

កាត់បន្ថយផលប៉ះពាល់ និងបន្សាំជាមួយនឹងការប្រែប្រួលអាកាសធាតុ កម្មវិធីសកម្មភាពជាតិ ដើម្បីប្រយុទ្ធប្រឆាំងនឹងការធ្លាក់ចុះនៃគុណភាពដី ការបញ្ជ្រាបយេនឌ័រក្នុងអនុវិស័យ ព្រៃឈើ។

- **ការគ្រប់គ្រងព្រៃឈើ**
  - គ្រប់គ្រងព្រៃឈើ និងសហគមន៍ព្រៃឈើឱ្យមានប្រសិទ្ធភាពខ្ពស់ និងធ្វើការជំរុញចុះបញ្ជិកា ដីស្ថានីយ ចម្ការឈើដាំ និងដីព្រៃសហគមន៍ដើម្បីធានាបាននូវសុវត្ថិភាពនៃការប្រើប្រាស់ដីធ្លី
  - អភិវឌ្ឍសហគមន៍ព្រៃឈើ និងគ្រប់គ្រងផល អនុផលព្រៃឈើ ពិសេសត្រូវបន្តពង្រឹងពង្រីកសហគមន៍ព្រៃឈើ
  - ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ បង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើឱ្យមានប្រសិទ្ធភាព ដោយសហការជាមួយគណៈកម្មាធិការជាតិទប់ស្កាត់បទល្មើសធនធានធម្មជាតិ គណៈបញ្ជាការឯកភាពរាជធានី ខេត្ត
- **ការអភិវឌ្ឍ និងស្រាវជ្រាវព្រៃឈើ និងសត្វព្រៃ**
  - ធ្វើការអភិវឌ្ឍចម្ការឈើដាំ និងការងាររុក្ខវប្បកម្ម ក្នុងគោលដៅពង្រីកគម្របព្រៃឈើ ដោយត្រូវបន្តជំរុញការស្តារដាំដុះព្រៃឈើឡើងវិញនៅលើដីព្រៃរេចរិល ដីព្រៃរងការធ្វើអាជីវកម្ម ដីទំនេររបស់រដ្ឋ និងដីព្រៃ ដែលបានដកហូតពីសម្បទានដីសេដ្ឋកិច្ច ដោយសហការជាមួយផ្នែកឯកជន ដៃគូអភិវឌ្ឍន៍ព្រមទាំងបង្កើន ការបណ្តុះកូនឈើគ្រប់ប្រភេទនៅតាមស្ថានីយ សម្រាប់ចែកចាយជូនប្រជាពលរដ្ឋ
  - ចុះត្រួតពិនិត្យតំបន់សម្បទានដីសេដ្ឋកិច្ច ដើម្បីធានាថាដំណើរការនៃការអនុវត្តប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់
  - លើកកម្ពស់ជីវភាពប្រជាពលរដ្ឋជនបទឱ្យបង្កើនប្រាក់ចំណូលតាមរយៈប្រព័ន្ធកសិ-រុក្ខកម្ម និងចិញ្ចឹមសត្វក្នុងតំបន់ដែលគ្រប់គ្រងដោយសហគមន៍ព្រៃឈើ
  - ជំរុញការគ្រប់គ្រង និងអភិវឌ្ឍឧស្សាហកម្មព្រៃឈើ ពាណិជ្ជកម្ម និងបង្កើនកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងការអភិវឌ្ឍវិស័យព្រៃឈើ
  - សង្គ្រោះ ថែរក្សាសត្វព្រៃ និងអប់រំផ្សព្វផ្សាយ ដើម្បីចូលរួមចំណែកទប់ស្កាត់ការផុតពូជធនធានសត្វព្រៃ និងជីវចម្រុះ

- ពិនិត្យឱ្យបានហ្មត់ចត់លើទីតាំងថែរក្សាសត្វព្រៃ និងកសិដ្ឋានចិញ្ចឹមសត្វព្រៃ និងជំរុញឱ្យមានការចុះបញ្ជិកាបានត្រឹមត្រូវ ព្រមទាំងធ្វើឱ្យការសិក្សានិងចងក្រងឯកសារសត្វព្រៃ និងជីវចម្រុះ និងសម្រប សម្រួលបង្កើតសេវាកម្មទេសចរណ៍ធម្មជាតិ ដើម្បីបង្កើនប្រាក់ចំណូលដល់សហគមន៍ព្រៃឈើមូលដ្ឋាន
- សិក្សាស្រាវជ្រាវការស្តារព្រៃឈើរេចរឹល ជំរុញការអនុវត្តកសិ-រុក្ខកម្មទប់ស្កាត់ការហូរច្រោះដី និងពង្រឹងសមត្ថភាពក្នុងការគ្រប់គ្រងតំបន់ស្តារ និងអភិវឌ្ឍន៍ព្រៃឈើ សំដៅចូលរួមចំណែកដោះស្រាយផលប៉ះពាល់ ពីការប្រែប្រួលអាកាសធាតុ
- រៀបចំបង្កើតសួនរុក្ខសាស្ត្រ (Botanical Garden) នៅតាមតំបន់អេកូឡូស៊ីរុក្ខជាតិក្នុងគោលបំណងអប់រំ បណ្តុះបណ្តាល និងផ្សព្វផ្សាយនូវប្រភេទរុក្ខជាតិមានដោយកម្រ និងជិតផុតពូជ ព្រមទាំងដាក់តាំងបង្ហាញនូវសំណាកប្រភេទរុក្ខជាតិសំខាន់ៗ និងអំបូរដទៃទៀត។

កម្មវិធីនេះ ត្រូវបានគាំទ្រដោយអនុកម្មវិធីចំនួន៤ និងអនុវត្តដោយរដ្ឋបាលព្រៃឈើ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានីខេត្ត។

### កម្មវិធីទី-៥៖ ការគ្រប់គ្រងស្ថាប័ន និងការអភិវឌ្ឍធនធានមនុស្ស

<u>**គោលបំណងកម្មវិធីទី៥៖**</u> "បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងស្ថាប័ន ការផ្តល់សេវាគាំទ្រ និងពង្រឹងសមត្ថភាពផ្នែកអប់រំនិងបណ្តុះបណ្តាល សម្រាប់ការអភិវឌ្ឍវិស័យកសិកម្មប្រកបដោយនិរន្តរភាព"។

ការបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងស្ថាប័ន ការផ្តល់សេវាគាំទ្រ និងការពង្រឹងសមត្ថភាពផ្នែកអប់រំ និងបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិស័យកសិកម្មប្រកបដោយនិរន្តរភាព គឺជាគ្រឹះដ៏រឹងមាំដើម្បីឈានទៅសម្រេចបាននូវគោលដៅគោលនយោបាយដែលបានដាក់ចេញ។ ដើម្បីសម្រេចបាននូវគោលបំណងនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ផ្តោតការអនុវត្តដោយផ្អែកលើអភិក្រមចំនួន៣ជាសំខាន់គឺ៖

- **ការពង្រឹងស្ថាប័ន**៖ ជំរុញការគ្រប់គ្រងអង្គភាពជំនាញក្រោមឱវាទក្រសួង ឱ្យមានសមត្ថភាពគ្រប់គ្រាន់ ក្នុងការអនុវត្តគោលនយោបាយ សម្រាប់អភិវឌ្ឍវិស័យកសិកម្មប្រកបដោយចីរភាព។
- **ការបង្កើនប្រសិទ្ធភាពសេវាគាំទ្រ**៖ បង្កើនសមត្ថភាពកសាង និងអនុវត្តផែនការយុទ្ធសាស្ត្រ ពង្រឹងប្រព័ន្ធព័ត៌មាន និងទីផ្សារកសិកម្ម ការគ្រប់គ្រងគម្រោងវិនិយោគ សាធារណៈនិងឯកជន ធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាព ភាពស័ក្តិសិទ្ធក្នុងការអនុវត្តថវិកាកម្មវិធីពេញលេញ ការធ្វើអធិការកិច្ច សវនកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ និងសេវាគាំទ្រពាក់Pព័ន្ធផ្សេងទៀតប្រកបដោយប្រសិទ្ធភាព។
- **ការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យកសិកម្ម៖** បង្កើនចំណេះដឹងផ្នែកបច្ចេកទេស និងជំនាញកសិកម្មពាក់ព័ន្ធនានា ស្រាវជ្រាវបន្ថែមនូវបច្ចេកវិទ្យានិងរបកគំហើញថ្មីៗ សំដៅពង្រឹងនិងពង្រីកធនធានមនុស្សក្នុងវិស័យកសិកម្ម ដើម្បីឆ្លើយតបតាមតម្រូវការទីផ្សារ ការងារ និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។
- បន្តពង្រឹងនិងជំរុញការងារផ្សព្វផ្សាយកសិកម្ម ការប្រើប្រាស់យន្តការផ្សព្វផ្សាយតាមលក្ខណៈពហុនិយមលើការផ្ទេរបច្ចេកវិទ្យា ការផ្សព្វផ្សាយតាមប្រព័ន្ធព័ត៌មានវិទ្យាដល់អ្នកប្រើប្រាស់បានទាន់ពេលវេលា និងសមស្របទៅតាមតម្រូវការ

កម្មវិធីនេះ ត្រូវបានគាំទ្រដោយអនុកម្មវិធីចំនួន១៣ និងអនុវត្តដោយ(១)នាយកដ្ឋានផែនការនិងស្ថិតិ (២)នាយកដ្ឋានគណនេយ្យហិរញ្ញវត្ថុ (៣)នាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស (៤)នាយកដ្ឋានសវនកម្មផ្ទៃក្នុង (៥)នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ (៦)នាយកដ្ឋាននីតិកម្មកសិកម្ម (៧) នាយកដ្ឋានកិច្ចការរដ្ឋបាល (៨)មជ្ឈមណ្ឌលឯកសារនិងព័ត៌មានកសិកម្ម (៩)អគ្គាធិការដ្ឋាន (១០)សាកលវិទ្យាល័យភូមិន្ទកសិកម្ម (១១)វិទ្យាស្ថានជាតិ

កសិកម្មព្រែកលៀប (១២)វិទ្យាស្ថានជាតិកសិកម្មកំពង់ចាម (១៣)នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង(១៤) មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានីខេត្ត។

កម្មវិធីទាំង៥របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបានគាំទ្រដោយអនុកម្មវិធីសរុបចំនួន៣៥ ក្នុងនោះអង្គភាពថ្នាក់កណ្តាលមានអនុកម្មវិធីចំនួន៣០ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានអនុកម្មវិធី ចំនួន៥។

| កម្មវិធី អនុកម្មវិធី អ្នកគ្រប់គ្រង និង អង្គភាពទទួលខុសត្រូវ | | | | | | |
|---|---|---|---|---|---|---|
| ឈ្មោះគោលបំណងគោលនយោបាយ | ឈ្មោះ កម្មវិធី និង អនុកម្មវិធី | អ្នកគ្រប់គ្រង | អង្គភាពទទួលខុសត្រូវ | | | |
| | | | ឈ្មោះអង្គភាព | (១) | (២) | (៣) |
| "ជំរុញកំណើនកសិកម្ម តាមរយៈការបង្កើនផលិតភាព ការធ្វើពាណិជ្ជូបនីយកម្ម ពិពិធកម្មកសិកម្ម និងជំរុញឧីជីថលូបនីយកម្ម ប្រកបដោយភាពប្រកួតប្រជែង បរិយាបន្ន ដែលផ្តល់នូវផលិតផលមានគុណភាពខ្ពស់ មានសុវត្ថិភាព និងធានាបាននូវសន្តិសុខស្បៀង ដោយត្រូវគិតគូរខ្ពស់ដល់ការគ្រប់គ្រងដីធ្លី ទឹក ធនធានព្រៃឈើ និងជលផល" | កម្មវិធីទី-១៖<br>ការបង្កើនផលិតភាព ពិពិធកម្មដំណាំកសិកម្ម និងកសិធុរកិច្ច | ឯកឧត្តម ងិន ឆាយ | អគ្គនាយកដ្ឋានកសិកម្ម | | √ | |
| | | | អគ្គនាយកដ្ឋានកៅស៊ូ | | √ | |
| | | | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | √ | | |
| | | | នាយកដ្ឋានកសិ-ឧស្សាកម្ម | | √ | |
| | | | វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា | √ | | |
| | អនុកម្មវិធីទី-១.១៖ ការជំរុញផលិតកម្មដំណាំនិងការនាំចេញ | ឯកឧត្តម ងិន ឆាយ | អគ្គនាយកដ្ឋានកសិកម្ម | | √ | |
| | អនុកម្មវិធីទី-១.២៖ ការសិក្សា ពិសោធន៍ វាយតម្លៃប្រភេទពូជនិងអភិវឌ្ឍន៍បច្ចេកទេសផលិតកម្មដំណាំ | ឯកឧត្តម ងិន ឆាយ | អគ្គនាយកដ្ឋានកសិកម្ម | | √ | |
| | អនុកម្មវិធីទី-១.៣៖ ការពង្រឹងសមត្ថភាពស្ថាប័ន និងការផ្តល់សេវាគាំទ្រ | ឯកឧត្តម ងិន ឆាយ | អគ្គនាយកដ្ឋានកសិកម្ម | | √ | |
| | អនុកម្មវិធីទី-១.៤៖ លើកកម្ពស់និងពង្រីកខ្សែច្រវាក់តម្លៃកៅស៊ូ | ឯកឧត្តម ហ៊ឹម អូន | អគ្គនាយកដ្ឋានកៅស៊ូ | | √ | |

| | | | | | | |
|---|---|---|---|---|---|---|
| | អនុកម្មវិធីទី-១.៥៖ លើកកម្ពស់គុណភាពការងារពិសោធន៍ និងស្រាវជ្រាវកៅស៊ូ | លោក លិម ខាន់ទីវ៉ា | វិទ្យាស្ថានស្រាវជ្រាវ កៅស៊ូកម្ពុជា (IRCC) | √ | | |
| | អនុកម្មវិធីទី-១.៦ ៖ ការលើកកម្ពស់ការអភិវឌ្ឍកសិ-ឧស្សាហកម្ម | លោក ចាយ ជីម | នាយកដ្ឋានកសិ-ឧស្សាហកម្ម | | √ | |
| | អនុកម្មវិធីទី-១.៧៖ ការស្រាវជ្រាវដើម្បីលើកកម្ពស់ប្រសិទ្ធភាពសេដ្ឋកិច្ចនៃដំណាំស្បៀង | លោក ឡោ ប៊ុណ្ណា | វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (កាឌី) | √ | | |
| | អនុកម្មវិធីទី-១.៨៖ ការជំរុញផលិតកម្មដំណាំកសិកម្ម និងកសិធុរកិច្ចរាជធានី-ខេត្ត | | ២៥ អង្គភាពថវិកា (មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ) | √ | | |
| | **កម្មវិធីទី២: ការលើកកម្ពស់សុខភាពសត្វ និងផលិតកម្មសត្វ** | **ឯកឧត្តម តាន់ ផាន់ណារ៉ា** | អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ | | √ | |
| | អនុកម្មវិធីទី-២.១៖ ការលើកកម្ពស់ផលិតកម្មសត្វ | លោកស្រី ហេង ម៉ូរ៉ានី លោកបណ្ឌិត ស៊ីន សាន | អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ | | √ | |
| | អនុកម្មវិធីទី-២.២៖ ការលើកកម្ពស់សុខភាពសត្វ | លោកបណ្ឌិត សួន សុជឿន លោកបណ្ឌិត ស៊ីន សាន | អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ | | √ | |
| | អនុកម្មវិធីទី-២.៣៖ ការពង្រឹងសមត្ថភាពនិ ងសេវាគាំទ្រអង្គភាព | លោក នូ យុត្តិកា លោក គឹម សារឿន | អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ | | √ | |
| | អនុកម្មវិធីទី-២.៤៖ ការការជំរុញផលិតកម្មសត្វ និងសុខភាពសត្វ រាជធានីខេត្ត | | | √ | | |
| | **កម្មវិធីទី-៣៖ ការគ្រប់គ្រងធនធានជលផល និងការអភិវឌ្ឍវារីវប្បកម្ម** | **ឯកឧត្តម ពុំ សុថា** | **រដ្ឋបាលជលផល** | | √ | |

| | | | | | | |
|---|---|---|---|---|---|---|
| | អនុកម្មវិធីទី-៣.១៖ ពង្រឹងការគ្រប់គ្រង និងអភិវឌ្ឍន៍សហគមន៍នេសាទ | លោក អ៊ុក វិបុល | | | √ | |
| | អនុកម្មវិធីទី-៣.២៖ ការអភិវឌ្ឍវារីវប្បកម្ម និងខ្សែច្រវាក់តម្លៃជលផល | លោក ថាយ សុមុន្នី | | | √ | |
| | អនុកម្មវិធីទី-៣.៣៖ ការពង្រឹងសមត្ថភាព និងសេវាគាំទ្រអង្គភាព | លោក ធ សែនសិរីវឌ្ឍន៍ | | | √ | |
| | អនុកម្មវិធីទី-៣.៤៖ ការពង្រឹងការគ្រប់គ្រងធនធានជលផល និងការជំរុញវារីវប្បកម្ម រាជធានី-ខេត្ត | | | √ | | |
| | កម្មវិធីទី-៤៖ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានព្រៃឈើនិងសត្វព្រៃ | ឯកឧត្តម កែវ អូម៉ាលីស្ស | រដ្ឋបាលព្រៃឈើ | | √ | |
| | អនុកម្មវិធីទី-៤.១៖ ការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ | លោក សួន សុវណ្ណ | | | √ | |
| | អនុកម្មវិធីទី-៤.២៖ ការអភិវឌ្ឍព្រៃឈើ | លោក ច័ន្ទ ប៉ុណ្ណិកា | | | √ | |
| | អនុកម្មវិធីទី-៤.៣៖ ការពង្រឹងការគ្រប់គ្រងនិងសេវាគាំទ្រ | លោក វង សុក្រសិរី | | | √ | |
| | អនុកម្មវិធីទី៤.៤៖ ការពង្រឹងសហគមន៍ព្រៃឈើ | លោក ឈាង ដានី | | | √ | |
| | អនុកម្មវិធីទី៤.៥៖ ការគ្រប់គ្រងសត្វព្រៃ និងសម្បទានដីសេដ្ឋកិច្ច | លោក សៀ រ៉ា | | | √ | |
| | អនុកម្មវិធីទី-៤.៦៖ ការពង្រឹងការគ្រប់គ្រង និង ការអភិវឌ្ឍធនធានព្រៃឈើនិងសត្វព្រៃ រាជធានី-ខេត្ត | | | √ | | |

| | | | | | | |
|---|---|---|---|---|---|---|
| | កម្មវិធីទី-៥៖ ការគ្រប់គ្រងស្ថាប័ន និងការអភិវឌ្ឍធនធានមនុស្ស | ឯកឧត្តម ស្រី វុឌ្ឍី | ១៣ អង្គភាព | | √ | |
| | អនុកម្មវិធីទី-៥.១៖ ការកសាងផែនការគោលនយោបាយ និងប្រព័ន្ធស្ថិតិកសិកម្ម | លោក ម៉ក់ ម៉ូនី | ន.ផែនការនិងស្ថិតិ | | √ | |
| | អនុកម្មវិធីទី-៥.២៖ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណប្រកបដោយប្រសិទ្ធភាព | លោក ម៉ុង ឡេង | ន.គណនេយ្យ ហិរញ្ញវត្ថុ | | √ | |
| | អនុកម្មវិធីទី-៥.៣៖ ពង្រឹងការគ្រប់គ្រងស្ថាប័ន និងអភិវឌ្ឍន៍ធនធានមនុស្ស | លោក ទី ចាន់ណា | ន.បុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស | | √ | |
| | អនុកម្មវិធីទី-៥.៤៖ ការជំរុញសវនកម្មផ្ទៃក្នុង | លោកស្រី ង៉ិន សូនាថ | ន.សវនកម្មផ្ទៃក្នុង | | √ | |
| | អនុកម្មវិធីទី-៥.៥៖ បង្កើនសមត្ថភាព និងប្រសិទ្ធភាពការងារសហប្រតិបត្តិការអន្តរជាតិ | ឯ.ឧ បណ្ឌិត ព្រុំ សុម៉ានី | ន.សហប្រតិបត្តិការអន្តរជាតិ | | √ | |
| | អនុកម្មវិធីទី-៥.៦៖ ពង្រឹងការអនុវត្តច្បាប់ក្នុងវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | លោក ប៉ែន វុទ្ធី | ន.នីតិកម្មកសិកម្ម | | √ | |
| | អនុកម្មវិធីទី-៥.៧៖ ពង្រឹងគាំទ្រសេវារដ្ឋបាល | លោក ជា ច័ន្ទវាសនា | ន.កិច្ចការរដ្ឋបាល | | √ | |
| | អនុកម្មវិធីទី-៥.៨៖ ការបង្កើនប្រសិទ្ធភាពការងារអធិការកិច្ច | ឯ.ឧ គង់ វ៉ាញ | អគ្គាធិការដ្ឋាន | | √ | |
| | អនុកម្មវិធីទី-៥.៩៖ ការរៀបចំបង្កើត គ្រប់គ្រង និងជំរុញការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានឌីជីថល (AIDOC) | លោក យៅ វេន | AIDOC | | √ | |

| | | | | | | |
|---|---|---|---|---|---|---|
| | អនុកម្មវិធីទី-៥.១០៖ កែទម្រង់គុណភាពអប់រំ និងគុណភាពស្រាវជ្រាវកសិកម្មនៅសាកលវិទ្យាល័យភូមិន្ទកសិកម្មកសិកម្ម | ឯ.ឧ ង៉ោ ប៊ុនថាន | សាកលវិទ្យាល័យភូមិន្ទកសិកម្ម | √ | | |
| | អនុកម្មវិធីទី-៥.១១៖ លើកកម្ពស់ គុណភាពអប់រំ និងបណ្តុះបណ្តាលបច្ចេកទេសកសិកម្មនៅវិទ្យាស្ថានជាតិកសិកម្មព្រែកលៀប | ឯ.ឧ ធន់ វឌ្ឍនា | វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប | √ | | |
| | អនុកម្មវិធីទី-៥.១២៖ ពង្រឹងគុណភាពប្រព័ន្ធអប់រំ និងបណ្តុះបណ្តាលធនធានមនុស្សក្នុងវិស័យកសិកម្មរបស់វិទ្យាស្ថានជាតិកសិកម្ម កំពង់ចាម | ឯ.ឧ ហែម វិរៈ | វិទ្យាស្ថានជាតិកសិកម្មកំពង់ចាម | √ | | |
| | អនុកម្មវិធីទី-៥.១៣៖ ៖ការលើកកម្ពស់ការងារផ្សព្វផ្សាយ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | លោកបណ្ឌិត ម៉ៅ មីនា | នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | | √ | |
| | អនុកម្មវិធីទី-៥.១៤៖ ការបង្កើនប្រសិទ្ធភាពសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស រាជធានី-ខេត្ត | | ២៥អង្គភាពថវិកា (មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ) | √ | | |

(*) *ជាគោលការណ៍ ចំនួនគោលបំណងគោលនយោបាយ មិនត្រូវមានលើសពី ២ ឡើយ។ ក្នុងករណី ក្រសួង-ស្ថាប័នដែលមានមុខងារច្រើន អាចត្រូវបានអនុញ្ញាតឱ្យមាន គោលបំណងគោលនយោបាយលើសពី ២ ប៉ុន្តែជាកម្មវត្ថុនៃការពិភាក្សា និងឯកភាពជាមុនពី កសហវ ។*

(**) *ជាគោលការណ៍ ចំនួនកម្មវិធី មិនត្រូវមានលើសពី ៥ ឡើយ។ ក្នុងករណី ក្រសួង-ស្ថាប័នធំៗ ដែលមានមុខងារច្រើន អាចត្រូវបានអនុញ្ញាតឱ្យមានកម្មវិធីលើសពី ៥ ប៉ុន្តែជាកម្មវត្ថុនៃការពិភាក្សា និងឯកភាព ជាមុនពីកសហវ។*

(***) *សូមធីក(√) ដូចតទៅ÷(១) អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ(២) អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញ និង(៣) មិនមែនជាអង្គភាពថវិកា។*

## IV. ការកំណត់រចនាសម្ព័ន្ធថវិកាសមិទ្ធកម្ម

### ក. ការកំណត់សូចនាករសមិទ្ធកម្ម និងគោលដៅ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានកំណត់នូវសូចនាករ និងគោលដៅសូចនាករ ដើម្បីតាមដានវឌ្ឍនភាពនិងសមិទ្ធផលនៃការអនុវត្តកម្មវិធី អនុកម្មវិធី និងគោលបំណងគោលនយោបាយនីមួយៗ ដូចខាងក្រោម៖

តារាង ១ "ក"

| ការកំណត់សូចនាករសមិទ្ធកម្ម និងគោលដៅ នៃកម្មវិធី និងអនុកម្មវិធី | | | | | | | |
|---|---|---|---|---|---|---|---|
| សេចក្តីពណ៌នា (បន្ថែមជួរដេកមួយសម្រាប់សូចនាករចុងក្រោយ និងសូចនាករលទ្ធផលក្នុងឆ្នាំនីមួយៗ) | គម្រោងថវិកា ឆ្នាំ២០២៤ (លានរៀល) | គោលដៅសូចនាករសមិទ្ធកម្ម | | | | | |
| | | ឆ្នាំមុន (២០២២) | ឆ្នាំបច្ចុប្បន្ន (ឆ្នាំ ២០២៣) | ឆ្នាំគ្រោងថវិកា (២០២៤) | | ឆ្នាំគ្រោងថវិកា (២០២៥) | ឆ្នាំគ្រោងថវិកា (២០២៦) |
| | | | | គោលដៅ | មូលហេតុនៃការផ្លាស់ប្តូរ (ធៀបនឹងគោលដៅឆ្នាំ ២០២២) | | |
| គោលបំណងគ.ប ៖<br>"ជំរុញកំណើនកសិកម្ម តាមរយៈការបង្កើនផលិតភាព ការធ្វើពាណិជ្ជូបនីយកម្មពិពិធកម្មកសិកម្ម និងជំរុញឌីជីថលូបនីយកម្ម ប្រកបដោយភាពប្រកួតប្រជែង បរិយាប័ន្ន ដែលផ្តល់នូវផលិតផលមានគុណភាពខ្ពស់ មានសុវត្ថិភាព និងធានាបាននូវសន្តិសុខស្បៀង ដោយត្រូវ គិតគូរខ្ពស់ ដល់ការគ្រប់គ្រងដីធ្លី ទឹក ធនធានព្រៃឈើ និងជលផល" | | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| **កម្មវិធីទី-១÷ ការបង្កើនផលិតភាព ពិពិធកម្មដំណាំកសិកម្ម និងកសិធុរកិច្ច** | ២៥ ២៦៦,៤ | | | | | | |
| សូចនាករលទ្ធផលចុងក្រោយទី១.ក៖ ផលិតផលកសិកម្មសរុប (លានតោន) | | ៣៥,០៩ | ៣៧,១៤ | ៣៩,០៧ | កំណើនផលិតកម្មដំណាំគ្រប់ប្រភេទ ៥% | ៣៩,០៧ | ៤១,០២ |
| សូចនាករលទ្ធផលចុងក្រោយទី១.ខ៖ ផលិតផលដំណាំកសិកម្មនាំចេញ (លានតោន) | | ៨,៦១ | ៩,៥៩ | ១០,៤២ | កំណើនផលិតផលដំណាំកសិកម្មនាំចេញ ៧% | ១០,៩៥ | ១១,៧១ |
| **អនុកម្មវិធីទី-១.១៖ ការបង្កើនផលិតភាពដំណាំមានសក្តានុពលនិងការនាំចេញ** | ៦ ៣៦៧,៦ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំទី ១.១.ក៖ របាយការណ៍អំពីតម្រូវការនិងការផ្គត់ផ្គង់ដំណាំ (របាយការណ៍) | | NA | NA | ៥ | | ៦ | ៧ |
| សូចនាករលទ្ធផលក្នុងឆ្នាំទី ១.១.ខ៖ អ្នកទទួលបានចំណេះដឹងអំពីផលិតកម្មដំណាំ (នាក់) | | | ៥.៦២២ | ៤.៤៩២ | | ៥.២៩២ | ៥.៥៩៥ |
| **អនុកម្មវិធីទី-១.២៖ ការសិក្សានិងវាយតម្លៃប្រភេទពូជដំណាំនិងបច្ចេកទេសផលិតកម្មដំណាំ** | ៣ ៣៧៧,១ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ១.២.ក៖ ប្រភេទពូជដំណាំត្រូវវាយតម្លៃ និងចុះបញ្ជី (ប្រភេទពូជ) | | | ៥ | ២៩ | | ៣៤ | ៣៩ |
| សូចនាករលទ្ធផលក្នុងឆ្នាំ១.២.ខ៖ បច្ចេកទេស និងរបាយការណ៍អំពីផលិតកម្មដំណាំត្រូវរៀបចំ (ឯកសារ) | | | ៤ | ១៦ | | ១៦ | ១៦ |
| **អនុកម្មវិធីទី-១.៣៖ ការពង្រឹងសមត្ថភាពស្ថាប័ននិងការផ្តល់សេវាគាំទ្រ** | ៤ ៧៩៦,៤ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំទី ១.៣.ក៖ អនុបាតនៃការអនុវត្តថវិកា (%) | | ៩៥ | ៩៥ | ៩៥ | ការចំណាយថវិកាធៀបនឹងផែនការ | ៩៥ | ៩៥ |
| សូចនាករលទ្ធផលក្នុងឆ្នាំទី ១.៣.ខ៖ ចំណូលទទួលបានការផ្តល់សេវាសាធារណៈ (លានរៀល) | | | ៦ ៦៩៤ | ៧ ៦៥៥ | | ៧ ៨៨៤ | ៨ ១២១ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| **អនុកម្មវិធីទី-១.៤៖ លើកកម្ពស់និងពង្រីកខ្សែច្រវាក់តម្លៃកៅស៊ូ** | ១ ១២០,១ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំទី១.៤.ក៖ ផលិតផលកៅស៊ូ (តោន) | | ៣៨២ ០០០ | ៣៩០.០០០ | ៣៩៤.០០០ | | ៣៩៨.០០០ | ៤០០.០០០ |
| **អនុកម្មវិធីទី១.៥៖ លើកកម្ពស់គុណភាពពិសោធន៍និងស្រាវជ្រាវកៅស៊ូ** | ២ ៤៥៧,០ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំទី ១.៥.ក : ក្លូនកៅស៊ូត្រូវបានបង្កើតនិងអភិរក្ស (ចំនួន) | | ២ | ២ | ២ | | ២ | ២ |
| សូចនាករលទ្ធផលក្នុងឆ្នាំទី ១.៥.ខ : រោងចក្រកែច្នៃកៅស៊ូដែលត្រូវចុះបញ្ជិការទទួលស្គាល់កើនឡើង (ចំនួន) | | ២ | ២ | ២ | | ២ | ២ |
| **អនុកម្មវិធីទី-១.៦៖ ការលើកកម្ពស់ការអភិវឌ្ឍកសិ-ឧស្សាហកម្ម** | ១ ៥៥៣,៧ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំទី១.៦.ក៖ ចំនួនអ្នកទទួលបានការបណ្តុះបណ្តាលបច្ចេកទេសកសិ-ឧស្សាហកម្ម | | ៣ ២២៧ | ៣ ២២០ | ៣ ៩៦០ | | ៣ ០០០ | ៣ ០០០ |
| សូចនាករលទ្ធផលក្នុងឆ្នាំទី១.៦.ខ៖ ចំនួនកសិផលិតផលគំរូផ្សារភ្ជាប់ទីផ្សារ (គំរូកសិផលិតផល) | | ០ | ០ | ៤ | | ៤ | ៤ |
| **អនុកម្មវិធីទី១.៧៖ ការស្រាវជ្រាវដើម្បីលើកកម្ពស់ប្រសិទ្ធភាពសេដ្ឋកិច្ចនៃដំណាំស្បៀង** | ៥ ៥៩៤,៥ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំទី១.៧.ក៖ គ្រាប់ពូជស្រូវនៃចំណាត់ថ្នាក់គ្រាប់ពូជគ្រឹះ គ្រាប់ពូជចុះបញ្ជី និងគ្រាប់ពូជវិញ្ញាបនបត្រ ផលិត និងលក់ផ្សព្វផ្សាយ(តោន) | | | | ៧០ | | ៧៤ | ៨០ |
| សូចនាករលទ្ធផលក្នុងឆ្នាំទី១.៧.ខ៖ ប្រសិទ្ធភាពសេដ្ឋកិច្ចដោយការប្រើប្រាស់បច្ចេកវិទ្យាកើនឡើង (%) | | | | ៥ | | ៥ | ៥ |
| សូចនាករលទ្ធផលក្នុងឆ្នាំទី១.៧.គ៖ បង្ហុំបច្ចេកវិទ្យាបង្កើតបាន | | | | ១ | | ១ | ១ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| **អនុកម្មវិធីទី៨៖ ការជំរុញផលិតកម្មដំណាំកសិកម្ម និងកសិ-ធុរកិច្ច រាជធានី-ខេត្ត** | | | | | | | |
| **កម្មវិធីទី២÷ ការលើកកម្ពស់ផលិតកម្មសត្វ និងសុខភាពសត្វ** | ១២ ០៩៦,៥ | | | | | | |
| សូចនាករលទ្ធផលចុងក្រោយទី២.ក៖ តម្លៃនៃការនាំចេញសត្វនិងផលិតផលសត្វសរុបប្រចាំឆ្នាំ (ពាន់លានរៀល) | | ២៥០ | ២៧៥ | ៣០២ | កំណើន (១០%) | ៣៣២ | ៣៦៥ |
| សូចនាករលទ្ធផលចុងក្រោយទី២.ខ៖ អត្រានៃការចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្មកើនឡើង (ភាគរយ) | | ៤១ | ៤៣ | ៤៥ | | ៤៧ | ៤៩ |
| សូចនាករលទ្ធផលចុងក្រោយទី២.គ៖ កាត់បន្ថយអត្រាជំងឺឆ្លងសត្វឱ្យនៅត្រឹម៥% | | ២,២១% | ៥% | ៥% | | ៥% | ៥% |
| **អនុកម្មវិធីទី២.២៖ ការលើកកម្ពស់ផលិតកម្មសត្វ** | ១ ៤៣៦,៦ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំទី ២.២.ក៖ ផលិតកម្មសត្វលក្ខណៈពាណិជ្ជកម្មកើនឡើង២% (លានក្បាល) | | ២៦,៥៦ | ២៧,៣៥ | ២៨,០០ | កំណើន២% | ២៩,៥០ | ៣០,០០ |
| សូចនាករលទ្ធផលក្នុងឆ្នាំទី ២.២.ខ៖ គោកូនកាត់មានផលិតភាពខ្ពស់ត្រូវបានបង្កាត់ (ក្បាល) | | ១ ០៨៩ | ១ ៣៩០ | ១ ៤៦០ | កំណើន៥% | ១ ៥៣០ | ១ ៦០០ |
| **អនុកម្មវិធីទី២.៣៖ ការលើកកម្ពស់សុខភាពសត្វ** | ៧ ៦៦០,០ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំទី ២.៣.ក៖ អត្រាគោ ក្របីបានចាក់វ៉ាក់សាំង (%) | | ៣៦,៣២ | ៥៥ | ៣៦ | | ៣៦ | ៣៦ |
| សូចនាករលទ្ធផលក្នុងឆ្នាំទី ២.៣.ខ៖ ចំនួនសត្តឃាតដ្ឋានដែលអនុវត្តអនាម័យល្អ | | ១០០ | ១២៥ | ១៥០ | កំណើន៥% | ១៧៥ | ២០០ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| **អនុកម្មវិធីទី២.៣៖ ការពង្រឹងសមត្ថភាព និងសេវាគាំទ្រអង្គភាព** | ២ ៩៩៩,៩ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំទី២.៣.ក៖ ប្រសិទ្ធភាពនៃការអនុវត្តថវិកា(%) | | ៩៤ | ៩៥ | ៩៥ | | ៩៥ | ៩៥ |
| សូចនាករលទ្ធផលក្នុងឆ្នាំទី២.៣.ខ៖ ចំនួនមន្ត្រីរាជការ និងអ្នកពាក់ព័ន្ធទទួលបានការផ្សព្វផ្សាយបណ្តុះបណ្តាលបច្ចេកទេស និងលិខិតបទដ្ឋានគតិយុត្ត (នាក់/ឆ្នាំ) | | ២ ២២៧ | ២ ៧០០ | ៦ ៤៤៥ | | ៧ ០០០ | ៨ ០០០ |
| **អនុកម្មវិធីទី២.៤៖ ការជំរុញផលិតកម្មសត្វ និងសុខភាពសត្វរាជធានី-ខេត្ត** | | | | | | | |
| **កម្មវិធីទី៣៖ ការគ្រប់គ្រងធនធាន ជលផល និងការអភិវឌ្ឍវារីវប្បកម្ម** | ១១ ៥៦៤,៨ | | | | | | |
| សូចនាករលទ្ធផលចុងក្រោយទី១.ក៖ ផលចាប់ពីធម្មជាតិ | | ៤៥៨,៨ | ៦០០ | ៦០០ | | ៥៨០ | ៥៨០ |
| សូចនាករលទ្ធផលចុងក្រោយទី២៖ អត្រាផលវារីវប្បកម្មធៀបនឹងផល ផលិតផលជលសរុប | | ៤០ | ៤៤ | ៤៩ | កំណើនវារីវប្បកម្ម២០% រៀងរាល់ឆ្នាំ | ៤០ | ៤០ |
| **អនុកម្មវិធីទី-៣.១៖ ការគ្រប់គ្រង និងការអភិរក្សធនធានជលផល** | ៤ ៥០០,០ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំទី៣.១.ក៖ ផលនេសាទចាប់ពីទឹកសាប (ពាន់តោន) | | ៥០០ | ៥០០ | ៤៥០ | | ៤៥០ | ៤៥០ |
| សូចនាករលទ្ធផលក្នុងឆ្នាំទី៣.១.ខ៖ ផលនេសាទចាប់ពីសមុទ្រ (ពាន់តោន) | | ១០០ | ១០០ | ១៣០ | | ១៣០ | ១៣០ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| **អនុកម្មវិធីទី-៣.២៖ ការអភិវឌ្ឍវារីវប្បកម្ម និងខ្សែច្រវាក់តម្លៃផលផល** | ២ ៦៤០,០ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំទី៣.២.ក៖ ផលិតផលវារីវប្បកម្មទឹកសាប (ពាន់តោន) | | ៤៣៨ | ៥២៥ | ៣៥០ | បង្កើនការស្រាវជ្រាវមេពូជថ្មីៗ និងបង្កើនផលិតកូនពូជមាន គុណភាពល្អ | ៣៥០ | ៣៥០ |
| សូចនាករលទ្ធផលក្នុងឆ្នាំទី៣.២.ខ៖ ផលិតផលវារីវប្បកម្មសមុទ្រ (ពាន់តោន) | | ៤៣ | ៥២ | ៤៩ | បង្កើនការបណ្តុះបណ្តាល និង គាំទ្រដល់កសិករផលិតកូនពូជ | ៥០ | ៥០ |
| សូចនាករលទ្ធផលក្នុងឆ្នាំទី៣.២.គ៖ ចំនួនទួនកន្លែងកែច្នៃផលផល បានអនុវត្តលក្ខខណ្ឌ អនាម័យល្អ | | ៥ | ៥ | ៥ | | ៥ | ៥ |
| **អនុកម្មវិធីទី-៣.៣៖ ការពង្រឹងសមត្ថភាព និងសេវាគាំទ្រអង្គភាព** | ៤ ៤២៤,៨ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំទី៣.៣.ក៖ ការអនុវត្តផែនការសកម្មភាពអនុវិស័យជលផល(ភាគរយ) | | ៩៥ | ៩៦ | ៩៦ | | ៩៦ | ៩៦ |
| សូចនាករលទ្ធផលក្នុងឆ្នាំទី៣.៣.ខ៖ អត្រាមន្ត្រីរដ្ឋបាលជលផល ទទួលចំណេះដឹងច្បាប់ស្តីពីជលផល និងលិខិតបទដ្ឋានគតិយុត្ត (%) | | ២.៥ | ២.៥ | ៥ | | ៥ | ៥ |
| សូចនាករលទ្ធផលក្នុងឆ្នាំទី៣.៣.គ៖ អត្រាមន្ត្រីរដ្ឋបាលជលផលត្រូវបានបណ្តុះបណ្តាលដើម្បីពង្រឹងសមត្ថភាព (%) | | ៤ | ៤ | ៤ | | ៤ | ៤ |
| **អនុកម្មវិធីទី៣.៤៖ ការពង្រឹងការគ្រប់គ្រងធនធានជលផល និងការជំរុញវារីវប្បកម្ម រាជធានី-ខេត្ត** | | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| **កម្មវិធីទី៤÷ ការគ្រប់គ្រងនិងអភិវឌ្ឍន៍ធនធានព្រៃឈើ និងសត្វព្រៃ** | ៩ ១០២,៨ | | | | | | |
| សូចនាករលទ្ធផលចុងក្រោយទី៤.កៈ ដីព្រៃឈើត្រូវបានដកហូតជាសម្បត្តិរដ្ឋ | | | ៥០០ ហិកតា | ៥០០ ហិកតា | | ៥០០ ហិកតា | ៥០០ ហិកតា |
| សូចនាករលទ្ធផលចុងក្រោយទី៤.ខ ៖ ទំហំផ្ទៃដីត្រូវបានដាំឈើជាចម្ការនិងដាំឈើក្នុងពិធីរុក្ខទិវា | | | ១៤៥ ហិកតា | ១៤៥ ហិកតា | | ១៤៥ ហិកតា | ១៤៥ ហិកតា |
| សូចនាករលទ្ធផលចុងក្រោយទី ៤.គ ៖ ចំនួន សហគមន៍ព្រៃឈើត្រូវបានអនុវត្តកសិ-រុក្ខកម្ម | | | ៨ សហគមន៍ | ៨ សហគមន៍ | | ៨ សហគមន៍ | ៨ សហគមន៍ |
| សូចនាករលទ្ធផលចុងក្រោយទី ៤.ឃ ៖ ចំនួន សត្វព្រៃត្រូវបានថែរក្សា និងព្យាបាលក្នុងសួនសត្វ | | | ៣ ០០០ក្បាល | ៣ ០០០ក្បាល | | ៣ ០០០ក្បាល | ៣ ០០០ ក្បាល |
| **អនុកម្មវិធីទី៤.១៖ ការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ** | ៤២០,៤ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ៤.១.ក: ដីព្រៃឈើត្រូវបានដកហូតជាសម្បត្តិរដ្ឋ | | | ៥០០ ហិកតា | ៥០០ ហិកតា | | ៥០០ ហិកតា | ៥០០ ហិកតា |
| **អនុកម្មវិធីទី៤.២៖ ការគ្រប់គ្រងព្រៃឈើ** | ៣ ២៩៧,៤ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ៤.២.ក: ទំហំផ្ទៃដីត្រូវបានដាំឈើជាចម្ការ និងដាំឈើក្នុងពិធីរុក្ខទិវា | | | ១៤៥ ហិកតា | ១៤៥ ហិកតា | | ១៤៥ ហិកតា | ៣០០ពាន់ហ.ត |
| សូចនាករលទ្ធផលក្នុងឆ្នាំ ៤.២.ខ: ផ្ទៃដីស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើ និងដីព្រៃសហគមន៍ត្រូវបានចុះបញ្ជីដីរដ្ឋ | | | ២០០ ហិកតា | ២០០ ហិកតា | | ២០០ ហិកតា | ១០% |
| | | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| **អនុកម្មវិធីទី៤.៣ ៖ ការពង្រឹងសហគមន៍ព្រៃឈើ** | ៣៣២,៨ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំទី៤.៣.ក៖ ចំនួនសហគមន៍ព្រៃឈើត្រូវបានបង្កើនប្រាក់ចំណូល | | ៨សហគមន៍ | ៨សហគមន៍ | ៨សហគមន៍ | | ៨ សហគមន៍ | ៨ សហគមន៍ |
| **អនុកម្មវិធីទី៤.៤ ៖ ការគ្រប់គ្រងសត្វព្រៃ និងសម្បទានដីសេដ្ឋកិច្ច** | ១ ៧១៣,៣ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ៤.៤.ក: ចំនួនក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចត្រូវបានចុះត្រួតពិនិត្យ និងវាយតម្លៃ | | | ៥០ ក្រុមហ៊ុន | ៥០ ក្រុមហ៊ុន | | ៥០ ក្រុមហ៊ុន | ៥០ ក្រុមហ៊ុន |
| សូចនាករលទ្ធផលក្នុងឆ្នាំ ៤.៤.ខ: ចំនួនសត្វព្រៃត្រូវបានថែរក្សា និងព្យាបាលក្នុងសួនសត្វ | | | ៣ ០០០ក្បាល | ៣ ០០០ក្បាល | | ៣ ០០០ក្បាល | ៣ ០០០ ក្បាល |
| **អនុកម្មវិធីទី៤.៥.៖ ការពង្រឹងការគ្រប់គ្រង និងសេវាគាំទ្រ** | ៣ ៣៣៨,៩ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំទី៤.៥.ក៖ លទ្ធផលនៃការអនុវត្តផែនការថវិកា | | ៩២% | ៩២% | ៩២% | | ៩៤% | ៩៥% |
| សូចនាករលទ្ធផលក្នុងឆ្នាំទី៤.៥.ខ៖ លទ្ធផលនៃការអនុវត្តផែនការសកម្មភាព | | ៩២% | ៩២% | ៩២% | | ៩៤% | ៩៥% |
| **អនុកម្មវិធីទី៤.៦៖ ការពង្រឹងការគ្រប់គ្រង និងការអភិវឌ្ឍធនធានព្រៃឈើនិងសត្វព្រៃ រាជធានី-ខេត្ត** | | | | | | | |
| **កម្មវិធីទី-៥-៖ ការគ្រប់គ្រងស្ថាប័ន និងការអភិវឌ្ឍធនធានមនុស្ស** | ១២២ ៦៨៨,៤ | | | | | | |
| សូចនាករលទ្ធផលចុងក្រោយទី៥.ក៖ អនុបាត (%) នៃការអនុវត្តថវិកាកម្មវិធី | | ៩៦ | ៩៥ | ៩៦ | | ៩៧ | ៩៧ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| សូចនាករលទ្ធផលចុងក្រោយទី៥.ខ៖ ចំនួននិស្សិតបានក្រោយបញ្ចប់ការសិក្សា | | ១ ០៨៦ | ១ ១០០ | ១ ១០០ | | ១ ១៥០ | ១ ២០០ |
| **អនុកម្មវិធីទី-៥.១៖ ការកសាងផែនការ គោលនយោបាយ និងប្រព័ន្ធស្ថិតិកសិកម្ម** | ១ ៩៦៦,៣ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំទី៥.១.ក៖ អនុបាត នៃការអនុវត្តសកម្មថវិកាកម្មវិធី (%) | | ៩៥ | ៩៥ | ៩៥ | | ៩៦ | ៩៧ |
| សូចនាករលទ្ធផលក្នុងឆ្នាំទី៥.១.ខ៖ ចំនួនសំណាកនៃការអង្កេតស្ទង់ទិន្នផល (សំណាក) | | ១២ ៥០០ | ១៣ ០០០ | ១៣ ០០០ | ផ្ទេរសកម្មភាពពីអង្គភាពជំនាញមកអនុវត្តនៅDPS | ១៣ ០០០ | ១៣ ០០០ |
| **អនុកម្មវិធីទី-៥.២៖ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណប្រកបដោយប្រសិទ្ធភាព** | ១ ២៨៣,៣ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំទី៥.២.ក៖ អត្រានៃការអនុវត្តថវិកាធៀបនឹងច្បាប់ហិរញ្ញវត្ថុសម្រេចបានក្នុងរង្វង់ (+/-) ៥% | | ៩៦ | ៩៥ | ៩៥ | | ៩៥ | ៩៥ |
| សូចនាករលទ្ធផលក្នុងឆ្នាំទី៥.២.ខ៖ ចំនួនទ្រព្យសម្បត្តិរដ្ឋរបស់អង្គភាពប្រើប្រាស់ត្រូវបានត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ | | ៤៦ | ៤៦ | ៤៦ | | ៤៦ | ៤៦ |
| **អនុកម្មវិធីទី-៥.៣៖ ពង្រឹងការគ្រប់គ្រងស្ថាប័ន និងអភិវឌ្ឍន៍ធនធានមនុស្ស** | ៩៦ ០៥៦,២ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំទី៥.៣.ក៖ចំនួនអង្គភាព/មន្ទីរ ត្រូវបានចុះសិក្សា ត្រួតពិនិត្យ និងកែលម្អ លើការងារគ្រប់ គ្រងមន្ត្រីរាជការ | | ២០ | ៣១ | ២០ | | ២២ | ២៣ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| សូចនាករលទ្ធផលក្នុងឆ្នាំទី៥.៣.ខ៖ ចំនួននៃវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងផ្សព្វផ្សាយ ពង្រឹងសមត្ថភាពមន្ត្រីរាជការ | | ១១ | ០៨ | ០៨ | | ០៩ | ១០ |
| សូចនាករលទ្ធផលក្នុងឆ្នាំទី៥.៣.គ៖ ចំនួនមន្ត្រី កសិកម្ម ទទួលបានការបណ្តុះបណ្តាលក្នុង និងក្រៅប្រទេស | | ៣០០០ | ៣០០០ | ៤៣០ | | ៥០០ | ៥០០ |
| **អនុកម្មវិធីទី-៥.៤៖ ការជំរុញសវនកម្មផ្ទៃក្នុង (នសវក)** | ២២៨,១ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំទី៥.៤.ក៖ អត្រា(%)នៃការអនុវត្តអនុសាសន៍ | | ៥៦ | ៥៨ | ៦០ | | ៦២ | ៦៤ |
| **អនុកម្មវិធីទី៥.៥ ៖ បង្កើនសមត្ថភាព និងប្រសិទ្ធភាពការងារសហប្រតិបត្តិការអន្តរជាតិ (នសហ)** | ២ ៣៦៨,៤ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំទី៥.៥.ក៖ ចំនួនគម្រោង កិច្ចព្រមព្រៀង ពិធីសារ និងអនុស្សរណៈ ក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការ | | ២០ | ២០ | ២០ | | ២០ | ២០ |
| សូចនាករលទ្ធផលក្នុងឆ្នាំទី ៥.៥.ខ៖ ចំនួនវគ្គបណ្តុះបណ្តាលសិក្ខាសាលា ប្រជុំ សន្និសិទ្ធ ក្នុង ក្រៅប្រទេស | | ៨៣ | ៧៨ | ១១០ | ដោយសារកិច្ចប្រជុំមួយចំនួនត្រូវប្តូរវេន | ១១០ | ១០០ |
| សូចនាករលទ្ធផលក្នុងឆ្នាំទី ៥.៥.គ៖ ចំនួនចុះតាមដាន និងវាយតម្លៃការអនុវត្តគម្រោង ឥណទាន និងNGO | | ២០ | ២០ | ២០ | | ២០ | ២០ |
| **អនុកម្មវិធីទី៥.៦៖ ពង្រឹងការអនុវត្តច្បាប់ក្នុងវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** | ២៦៧,៩ | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
